# ព្រឹទ្ធសភា
SENATE MAGAZINE

ទស្សនាវដ្ដីខែមករា








លេខ ៣០៣ ឆ្នាំទី២៦ ព.ស.២៥៦៩ គ.ស.២០២៦
Issue 303 Volume 26 B.E.2569 C.E.2026

# មាតិកា








**គ្របមុខ**

- *សម្តេចតេជោ **ហ៊ុន សែន** និងសម្តេចកិត្តិព្រឹទ្ធបណ្ឌិត អញ្ជើញជាអធិបតីក្នុងពិធីក្រុងពាលី និងចម្រើនព្រះបរិត្ត ឡើងអគារវិមានសាមគ្គីភាព។*
- *ឯកឧត្តម **អ៊ុច បូរិទ្ធ** អនុប្រធានទី១ព្រឹទ្ធសភា អញ្ជើញជួបសំណេះសំណាល និងសួរសុខទុក្ខប្រជាពលរដ្ឋភៀសសឹកនិងគ្រួសារវីរយុទ្ធជន នៅខេត្តកំពង់ចាម។*
- *ឯកឧត្តមបណ្ឌិត **ធន់ ខឡុនា** អនុប្រធានទី២ព្រឹទ្ធសភា អញ្ជើញថតរូបអនុស្សាវរីយ៍ជាមួយសមាជិកក្រុមប្រឹក្សាសង្កាត់ អាជ្ញាធរពាក់ព័ន្ធ នៅវិមានព្រឹទ្ធសភា។*

**អ្នកគ្រប់គ្រងទូទៅ**

ឯកឧត្តម ឡាយ សំកុល

**អ្នកសម្រួលខ្លឹមសារ និងអក្ខរាវិរុទ្ធ**

ឯកឧត្តម ខេង សិទ្ធិគុណ

ឯកឧត្តម ជាម សុផលមករា

ឯកឧត្តម ជួន ណា

លោក ជួន សុខជី

លោក ទេព មករា

លោក កុក វ៉ៃ

លោក សុង សុខភាក្តែ

**អ្នកគ្រប់គ្រងផ្ទាល់**

លោក ទេព មករា

**ក្រុមអ្នកយកព័ត៌មាន**

ការិយាល័យព័ត៌មាន

**ភារីកុំព្យូទ័រ**

លោក ជុំ ច័ន្ទតេនា

លោកស្រី សុខ សុជាតា

## សកម្មភាពថ្នាក់ដឹកនាំព្រឹទ្ធសភា ( ១-២៧ )


- សម្តេចតេជោ **ហ៊ុន សែន** សម្រក់ទឹកភ្នែកដោយក្តីរំភើបពេលឃើញទិដ្ឋភាពស្វាគមន៍វីរកងទ័ពកម្ពុជាទាំង១៨នាក់......... ១
- សម្តេចតេជោ **ហ៊ុន សែន** និងសម្តេចកិត្តិព្រឹទ្ធបណ្ឌិត អញ្ជើញជាអធិបតីក្នុងពិធីក្រុងពាលី និងចម្រើនព្រះបរិត្តឡើងវិមានសាមគ្គីភាពនៃព្រឹទ្ធសភា ......... ២
- អ្នកវិនិយោគអារ៉ាប៊ីសាអូឌីតកំពុងស្វែងរកឱកាសវិនិយោគនៅកម្ពុជា......... ៥
- ឯកឧត្តម **អ៊ុច បូរិទ្ធ** អញ្ជើញដឹកនាំកិច្ចប្រជុំគណៈកម្មាធិការអចិន្ត្រៃយ៍ព្រឹទ្ធសភា ដើម្បីពិនិត្យសម្រេចលើរបៀបវារៈចំនួន៦ ......... ៦
- ឯកឧត្តម **អ៊ុច បូរិទ្ធ** អញ្ជើញដឹកនាំកិច្ចប្រជុំគណៈកម្មាធិការអចិន្ត្រៃយ៍ព្រឹទ្ធសភា ដើម្បីពិនិត្យសម្រេចលើរបៀបវារៈសម្រាប់សម័យប្រជុំលើកទី៤ព្រឹទ្ធសភា នីតិកាលទី៥......... ៨
- ព្រឹទ្ធសភាប្រកាសទទួលស្គាល់សមាជិកថ្មីនិងឯកភាពទាំងស្រុងលើសេចក្តីព្រាងច្បាប់ចំនួន៤ ពាក់ព័ន្ធនឹងវិស័យអាកាសចរណ៍......... ១០
- ព្រឹទ្ធសភាបើកកិច្ចប្រជុំគណៈកម្មាធិការអចិន្ត្រៃយ៍ ដើម្បីពិនិត្យសម្រេចលើរបៀបវារៈចំនួន៣ ......... ១៤
- គណៈកម្មាធិការអចិន្ត្រៃយ៍ព្រឹទ្ធសភា ពិនិត្យសម្រេចលើរបៀបវារៈសម្រាប់ប្រជុំព្រឹទ្ធសភាជាវិសាមញ្ញ នីតិកាលទី៥......... ១៥
- ព្រឹទ្ធសភាឯកភាពទាំងស្រុងលើសេចក្តីព្រាងច្បាប់សមុទ្រ និងបោះឆ្នោតជ្រើសរើសបំពេញសមាជិកគណៈកម្មការទី៥ព្រឹទ្ធសភា......... ១៦
- ឯកឧត្តមអនុប្រធានទី១ព្រឹទ្ធសភា អញ្ជើញសួរសុខទុក្ខវីរកងទ័ពការពារប្រាសាទតាមាន់ ប្រាសាទតាក្របី និងប្រាសាទខ្នា និងប្រជាពលរដ្ឋភៀសសឹកនៅស្រុកក្រឡាញ់......... ១៩
- ឯកឧត្តម **អ៊ុច បូរិទ្ធ៖** ការលំបាកនិងការឈឺចាប់របស់ពលរដ្ឋភៀសសឹកត្រូវបានប្រែក្លាយជាកម្លាំងចលករដ៏ខ្លាំងក្លា ជំរុញនិងពង្រឹងឱ្យកាន់តែរឹងមាំថែមទៀតនូវចំណងសាមគ្គីភាព ......... ២១
- ឯកឧត្តមបណ្ឌិត **ធន់ ខឡុនា៖** អាជ្ញាធរសង្កាត់មានតួនាទីសំខាន់ខ្លាំង ក្នុងការតាមដាន និងលុបបំបាត់ការឆបោកអនឡាញ......... ២៣
- សកម្មភាពថ្នាក់ដឹកនាំព្រឹទ្ធសភាចូលរួមពិធីផ្សេងៗ ......... ២៤


## សកម្មភាពគណៈកម្មការនានារបស់ព្រឹទ្ធសភា ( ២៨-៥៥ )


- គណៈប្រតិភូគណៈកម្មការទី៨ និងក្រុមសមាជិកាព្រឹទ្ធសភា អញ្ជើញចុះសួរសុខទុក្ខវីរកងទ័ព ដែលកំពុងសម្រាកព្យាបាលជំងឺ នៅមណ្ឌលសុខភាពគូលែន និងមន្ទីរពេទ្យបង្អែកខេត្ត ១៦មករា ......... ២៨
- ឯកឧត្តម **ម៉ម ប៊ុននាង** អញ្ជើញនាំយកអំណោយដ៏ថ្លៃថ្លារបស់សម្តេចតេជោ **ហ៊ុន សែន** និងមូលនិធិចែករំលែកសង្គ្រោះជីវិតសកលនៃសាធារណរដ្ឋកូរ៉េ ប្រគល់ជូនរដ្ឋបាលខេត្តកំពង់ស្ពឺ......... ៣០
- ក្រុមសមាជិកព្រឹទ្ធសភាប្រចាំភូមិភាគទី៣ អញ្ជើញសំណេះសំណាលជាមួយអាជ្ញាធរស្រុកលើកដែក និងស្រុកកៀនស្វាយ ខេត្តកណ្តាល ......... ៣២
- ក្រុមសមាជិកព្រឹទ្ធសភា អញ្ជើញជួបសំណេះសំណាល និងនាំយកចង្ក្រានសន្សំសំចៃថាមពលចែកជូនប្រជាពលរដ្ឋ ក្នុងស្រុកបរិបូណ៌......... ៣៤
- កិច្ចប្រជុំគណៈកម្មការទាំង១០ ក្រុមភូមិភាគ និងក្រុមនានានៃព្រឹទ្ធសភា......... ៣៦
- សមាជិក សមាជិកាព្រឹទ្ធសភាបំពេញការងារនៅតាមបណ្តាភូមិភាគទាំង៨ ......... ៤៣
- សមាជិក សមាជិកាព្រឹទ្ធសភាចូលរួមពិធីផ្សេងៗ ......... ៥២
- សមាជិក សមាជិកាព្រឹទ្ធសភាបំពេញបេសកកម្មក្រៅប្រទេស......... ៥៥
- ការទទួលពាក្យបណ្តឹង......... ៥៥


## សកម្មភាពអគ្គលេខាធិការដ្ឋាន ( ៥៦-៦១ )


- ឯកឧត្តម **ឡាយ សំកុល** អំពាវនាវមន្ត្រីរាជការរួបរួមសាមគ្គីគ្នា ដើម្បីបុព្វហេតុជាតិមាតុភូមិ «សាមគ្គីរស់ បែកបាក់សាមគ្គីស្លាប់» ......... ៥៦
- សកម្មភាពថ្នាក់ដឹកនាំអគ្គលេខាធិការដ្ឋានព្រឹទ្ធសភាចូលរួមពិធីផ្សេងៗ......... ៥៨

# សម្តេចតេជោ ហ៊ុន សែន សម្រក់ទឹកភ្នែកដោយក្តីរំភើប ពេលឃើញទិដ្ឋភាពស្វាគមន៍វីរកងទ័ពកម្ពុជាទាំង១៨នាក់



សម្តេចតេជោ ហ៊ុន សែន ប្រធានព្រឹទ្ធសភា

សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** ប្រធានព្រឹទ្ធសភា នៃព្រះរាជាណាចក្រកម្ពុជា បានបង្ហាញអារម្មណ៍រំភើបរហូតដល់ស្រក់ទឹកភ្នែក នៅពេលបានឃើញនូវការស្វាគមន៍យ៉ាងកក់ក្តៅពីសំណាក់បងប្អូនប្រជាជនកម្ពុជា នៅតាមដងផ្លូវ ចំពោះវីរយុទ្ធជនរបស់កម្ពុជាទាំង១៨នាក់ ដែលភាគីថៃយល់ព្រមដោះលែង ក្រោយពីបានចាប់ខ្លួនបន្ទាប់ពីបទឈប់បាញ់ កាលពីថ្ងៃទី២៩ ខែកក្កដា ឆ្នាំ២០២៥។ សម្តេចតេជោ **ហ៊ុន សែន** បានមានប្រសាសន៍បែបនេះ ក្នុងឱកាសជួបសំណេះសំណាល និងសួរសុខទុក្ខបងប្អូនវីរកងទ័ពទាំង១៨នាក់ និងក្រុមគ្រួសារ នៅវិមាន៧មករា នៅព្រឹកថ្ងៃព្រហស្បតិ៍ ទី១ ខែមករា ឆ្នាំ២០២៦។

**សម្តេចតេជោ** បានសម្តែងនូវក្តីរីករាយ និងស្វាគមន៍វីរយុទ្ធជនទាំង១៨នាក់ ដែលបាននិវត្តន៍មកកាន់មាតុប្រទេស និងបានជួបជុំជាមួយក្រុមគ្រួសារឡើងវិញ។ **សម្តេច**យល់អំពីអារម្មណ៍របស់វីរយុទ្ធជន ក៏ដូចជាក្រុមគ្រួសារនូវការលំបាកនៃការព្រាត់ប្រាស់គ្នា ពីព្រោះសម្តេចផ្ទាល់ ធ្លាប់បានឆ្លងកាត់នូវបទពិសោធដ៏ជូរចត់នេះ កាលពីពេលដែល**សម្តេច**យកជីវិតធ្វើជាដើមទុន ដើម្បីរំដោះប្រទេសជាតិចេញពីរបបប្រល័យពូជសាសន៍ ប៉ុល ពត។

ជាមួយគ្នានោះ **សម្តេចតេជោ** បានអរគុណដល់រាជរដ្ឋាភិបាលកម្ពុជា ដែលបានយកចិត្តទុកដាក់ជានិច្ចចំពោះសុខទុក្ខ និងអាយុជីវិតរបស់វីរយុទ្ធជនយើង ហើយ**សម្តេច**ក៏បានយកចិត្តទុកដាក់ និងបានតាមដានជាប្រចាំអំពីស្ថានភាពរបស់វីរយុទ្ធជន ជាពិសេសបំផុតនោះគឺ ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ **នរោត្តម សីហមុនី** ព្រះមហាក្សត្រនៃព្រះរាជាណាចក្រកម្ពុជា និងសម្តេចវររាជមាតាជាតិខ្មែរ ព្រះអង្គទាំងទ្វេ ក៏បានយកព្រះទ័យទុកដាក់យ៉ាងខ្លាំងចំពោះវីរយុទ្ធជនយើងទាំង១៨នាក់ រួមទាំងវីរកងទ័ពទាំងអស់របស់យើងនៅតាមព្រំដែន ដែលនេះជាការយកចិត្តដាក់ពីថ្នាក់ដឹកនាំគ្រប់លំដាប់ថ្នាក់របស់កម្ពុជា។ **សម្តេច**បានបញ្ជាក់ថា នេះជាស្មារតីនៃការសាមគ្គីរបស់ប្រជាជនខ្មែរដ៏ធំបំផុត សម្រាប់វីរយុទ្ធជនទាំង១៨នាក់ និងវីរយុទ្ធជនយើងនៅសមរភូមិមុខ។

**សម្តេចតេជោ** បានជូនពរដល់វីរយុទ្ធជនទាំង១៨នាក់ និងក្រុមគ្រួសារ ជួបប្រទះតែសេចក្តីសុខសេចក្តីចម្រើន និងបានរស់នៅជាមួយនឹងក្រុមគ្រួសារ នៅក្នុងទឹកដីកំណើតឡើងវិញប្រកបដោយភាពសុខសាន្ត៕

ប្រភព៖ Telegram Channel សម្តេចតេជោ

រូបភាព៖ នាយកដ្ឋានព័ត៌មាន





ទិដ្ឋភាពសម្តេចតេជោ ហ៊ុន សែន ស្វាគមន៍សំណេះសំណាល និងសួរសុខទុក្ខវីរកងទ័ពកម្ពុជាទាំង១៨នាក់

# សម្តេចតេជោ ហ៊ុន សែន និងសម្តេចកិត្តិព្រឹទ្ធបណ្ឌិត អញ្ជើញជាអធិបតី ក្នុងពិធីក្រុងពាលី និងចម្រើនព្រះបរិត្តឡើងវិមានសាមគ្គីភាព នៃព្រឹទ្ធសភា





*សម្តេចតេជោ ហ៊ុន សែន និងសម្តេចកិត្តិព្រឹទ្ធបណ្ឌិត អញ្ជើញជាអធិបតីក្នុងពិធីក្រុងពាលី និងចម្រើនព្រះបរិត្តឡើងវិមានសាមគ្គីភាព*

នៅព្រឹកថ្ងៃទី២៣ ខែមករា ឆ្នាំ២០២៦ វិមានសាមគ្គីភាព ត្រូវបានប្រារព្ធពិធីក្រុងពាលីចម្រើនព្រះបរិត្ត តាមទំនៀមទម្លាប់ប្រពៃណីព្រះពុទ្ធសាសនា ដើម្បីសុំសេចក្តីសុខ សេចក្តីចម្រើន ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់របស់សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** ប្រធានព្រឹទ្ធសភា នៃព្រះរាជាណាចក្រកម្ពុជា និងសម្តេចកិត្តិព្រឹទ្ធបណ្ឌិត **ប៊ុន រ៉ានី ហ៊ុនសែន**។

ក្នុងឱកាសដ៏មហោឡារិកនេះ ក៏មានការអញ្ជើញចូលរួមពីសម្តេចមហារដ្ឋសភាធិការធិបតី **ឃួន សុដារី** ប្រធានរដ្ឋសភា សម្តេចកិត្តិសង្គហបណ្ឌិត **ម៉ែន សំអន** ឧត្តមប្រឹក្សាផ្ទាល់ព្រះមហាក្សត្រ ឯកឧត្តម **ប្រាក់ សុខុន** ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីការបរទេសនិងសហប្រតិបត្តិការអន្តរជាតិនិងលោកជំទាវ ឯកឧត្តម **អ៊ុច បូររិទ្ធ** អនុប្រធានទី១ ឯកឧត្តមបណ្ឌិត **ឆន់ ខន្ធុនា** អនុប្រធានទី២ព្រឹទ្ធសភា សមាជិកសមាជិកាព្រឹទ្ធសភា ថ្នាក់ដឹកនាំអគ្គលេខាធិការដ្ឋានព្រឹទ្ធសភាខុទ្ទកាល័យថ្នាក់ដឹកនាំព្រឹទ្ធសភាទាំងបី និងលោកអ្នកឧកញ៉ាអ្នកឧកញ៉ា ដែលជាសប្បុរសជន។

សូមជម្រាបថា ឆ្លងកាត់ពេលវេលាជាច្រើនទសវត្សរ៍



*ទិដ្ឋភាពក្នុងពិធីក្រុងពាលី និងចម្រើនព្រះបរិត្តឡើងវិមានសាមគ្គីភាព*

កន្លងទៅនេះ វិមានរដ្ឋចំការមនបានបន្តកែលំអ និងវិវឌ្ឍន៍ខ្លួនតម្រូវតាមការអភិវឌ្ឍរបស់ប្រទេស ព្រមទាំងបានផ្តល់ជារដ្ឋមណ្ឌលដ៏សមប្រកបជូនថ្នាក់ដឹកនាំជាបន្តបន្ទាប់។ មានជាអាទិ៍ អគារជាច្រើននៅក្នុងទីតាំងវិមានរដ្ឋចំការមនបានចាប់ផ្តើមនិងបន្តសាងសង់ ពីជំនាន់មួយទៅជំនាន់មួយ ដោយរក្សានិងបង្ហាញសក្ខីកម្មនៃការវិវឌ្ឍស្ថាបត្យកម្មខ្មែរបុរាណ រួមជាមួយនឹងសហសម័យ ដើម្បីឆ្លុះបញ្ចាំងឱ្យឃើញពីអារ្យធម៌ខ្មែរ និងស្មារតីថែរក្សាកេរ្តិ៍មរតកស្ថាបត្យកម្មប្រាសាទដ៏ចំណាស់បំផុតនៃចក្រភពខ្មែរផង។ ក្នុងចំណោមសំណង់ស្ថាបត្យកម្មថ្មីៗនេះ អគារដ៏ប្រណីតនិងស្ដឹមស្ដែសមសួនមួយ បានទើបប្រតិដ្ឋ ស្របនឹងមហាវិថីព្រះនរោត្តម។ អគារថ្មីនេះ មានឈ្មោះថា «វិមានសាមគ្គីភាព» ដែលត្រូវបានផ្តួចផ្តើមសាងសង់ និងទទួលការប្រសិទ្ធនាមដោយសម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** ប្រធានព្រឹទ្ធសភានៃព្រះរាជាណាចក្រកម្ពុជា នានីតិកាលទី៥។

នាមនៃអគារព្រឹទ្ធសភាថ្មីនេះ «វិមានសាមគ្គីភាព» ដែលសម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** ផ្តល់ជូនជាមហាកិត្តិយសនេះ គឺក្នុងស្មារតីនៃតួនាទីរបស់ព្រឹទ្ធសភាដែលជារដ្ឋមណ្ឌល នៃតំណាងប្រជាជន ដែលមានគណបក្សនយោបាយចូលរួមបោះឆ្នោតឃុំ-សង្កាត់។ វិមាននេះ បានសម្រិតសម្រាំងកសាងឡើងតាមរយៈថវិកាចូលរួមពីសប្បុរសជន ដែលជាភស្តុតាងនៃស្មារតីសាមគ្គីភាពជាតិ។ បើក្រឡេកមើលឆ្ងាយបន្តិច យើងមានវិមានមិត្តភាព និងវិមានសន្តិភាព ក៏ជាស្នាដៃរបស់សម្តេចតេជោបានសាងសង់នៅទីស្តីការគណៈរដ្ឋមន្ត្រី នោះយើងនឹងមើលឃើញប្រៀបដូចនឹង «ត្រៃឋាន»។ បើគួបផ្សំទាំងបីចូលគ្នា បង្កើតបានជាម៉ុចង្ក្រានសន្តិភាព និងការអភិវឌ្ឍយូរអង្វែង។

ស្របតាមអត្ថន័យដ៏ជ្រាលជ្រៅនេះ វិមានសាមគ្គីភាពដែលជាអគារប្រវត្តិសាស្ត្រដ៏ប្រណីត បានរៀបចំតាក់តែងលម្អដោយក្បាច់ចម្លាក់ខ្មែរសមស័ក្ត ដើម្បីបម្រើជាមណ្ឌលនិងវិមានប្រមុខថ្នាក់ដឹកនាំព្រឹទ្ធសភា ក្នុងការបំពេញមុខងារជាប្រមុខរដ្ឋស្តីទី ការទទួលសារតាំងប្រធានស្ថានតំណាងបរទេសប្រចាំកម្ពុជា និងការបំពេញតួនាទីផ្សេងៗទៀត មានតួយ៉ាង៖ ការទទួលបដិសណ្ឋារកិច្ច និងលៀងសាយភោជនជូនឥស្សរជនជាន់ខ្ពស់បរទេស និងការរៀបចំកម្មវិធីនានារបស់ព្រឹទ្ធសភា។

បួនខែក្រោយបន្ទាប់ពីការយាងបើកសម័យប្រជុំព្រឹទ្ធសភាលើកដំបូងសម្រាប់នីតិកាលទី៥ របស់ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ **នរោត្តម សីហមុនី** ព្រះមហាក្សត្រ នៃព្រះរាជាណាចក្រកម្ពុជាមក វិមានសាមគ្គីភាពត្រូវបានបញ្ចុះបឋមសិលាបើកការដ្ឋានដំណើរការសាងសង់ជាផ្លូវការនៅថ្ងៃទី៩ ខែសីហា ឆ្នាំ២០២៤ ក្រោមអធិបតីភាព



*ថ្នាក់ដឹកនាំព្រឹទ្ធសភា, រដ្ឋសភា, ឥស្សរជនជាន់ខ្ពស់ និងសប្បុរសជននានា ចូលរួមក្នុងពិធីក្រុងពាលី និងចម្រើនព្រះបរិត្ត*

របស់ឯកឧត្តម **ប្រាក់ សុខុន** តំណាងដ៏ខ្ពង់ខ្ពស់របស់សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** ប្រធានព្រឹទ្ធសភា និងជាអនុប្រធានទី១ព្រឹទ្ធសភា ពេលនោះ។ ការសាងសង់បានចប់សព្វគ្រប់ក្នុង រយៈពេល១៦ខែ ហើយត្រូវបានដាក់ឱ្យប្រើប្រាស់ នៅថ្ងៃទី២៣ ខែមករា ឆ្នាំ២០២៦។

ប្រតិស្ឋាននៅបរិវេណចន្លោះអគារក្រហម និងមហាវិថីព្រះនរោត្តម វិមានសាមគ្គីភាព មានវិមាត្រ បណ្តោយ ៧៩ ម៉ែត្រ x ទទឹង ៤៧ ម៉ែត្រ x កម្ពស់ ៣៥ ម៉ែត្រ និងរៀបចំជា ៤ ជាន់កន្លះ ដោយប្រើដំបូលរាបស្មើ។ ជាក់ស្តែង ទំហំនៃវិមានសាមគ្គីភាព ស្តែងឱ្យឃើញនូវការចងចាំរបស់ប្រជាជនកម្ពុជា ថ្ងៃទី៧ ខែមករា ឆ្នាំ១៩៧៩ ដែលជាថ្ងៃមហាជ័យជម្នះរបស់ប្រជាជនកម្ពុជាលើរបបប្រល័យពូជសាសន៍ ប៉ុល ពត និងការបើកទំព័រសករាជថ្មី នៃសករាជ «ឯករាជ្យ សន្តិភាព សេរីភាព ប្រជាធិបតេយ្យ អព្យាក្រឹត និងវឌ្ឍនភាពសង្គម» និងជាថ្ងៃកំណើតទី២ របស់ប្រជាជនកម្ពុជា ព្រមជាមួយនឹងខួបលើកទី៤៧ ទិវាអបអរសាទរជ័យជម្នះ កំណើតទី២ ក្នុងឆ្នាំ២០២៦ នេះផងដែរ។

វិមានសាមគ្គីភាព ត្រូវបានសាងសង់ឡើងជាប្រភេទសំណង់បេតុងខ្សែកាប និងបេតុងអារម៉េ ដែលផ្តល់ភាពរឹងមាំ និងទំនើប ព្រមទាំងបង្ហាញពីស្ថាបត្យកម្ម និងរចនាបថខ្មែរ សហសម័យ។ ក្បាច់ខ្មែរ ជាទម្រង់ផ្កាច័ន្ទ និងបាំងខ្លែង ដែលដកស្រង់ពីប្រាសាទបុរាណ ត្រូវបានយកមកលម្អនៅតាមការិយាល័យ និងជញ្ជាំង នៃវិមានសាមគ្គីភាព ដើម្បីលើកកម្ពស់វប្បធម៌ អត្តសញ្ញាណជាតិខ្មែរ និងស្របទៅនឹងតួនាទីនៃវិមានស្ថាប័នកំពូលនីតិប្បញ្ញត្តិនេះ។ លំហខាងក្នុងវិមានត្រូវបានគិតគូរ និងរចនាឱ្យមានទំហំទូលាយ តាមរយៈការប្រើប្រាស់បច្ចេកទេសធ្នឹមខ្សែកាប ដែលអនុញ្ញាតឱ្យយើងសាងសង់សសរមានគម្លាតឆ្ងាយពីគ្នា និងងាយស្រួលក្នុងការប្រើប្រាស់ និងរៀបចំពិធី។ ម្យ៉ាងទៀត ការទទួលយកពន្លឺធម្មជាតិ និងខ្យល់ចូលបានគ្រប់គ្រាន់ គឺជាលក្ខខណ្ឌចាំបាច់ក្នុងការរចនា លម្អបន្ថែមដោយចង្កៀងព្យួរ ចង្កៀងជញ្ជាំង និងសន្ទិយា៕

អត្ថបទនិងរូបភាព៖ នាយកដ្ឋានព័ត៌មាន





*សមាជិក សមាជិកាព្រឹទ្ធសភា និងថ្នាក់ដឹកនាំអគ្គលេខាធិការដ្ឋានព្រឹទ្ធសភា ចូលរួមក្នុងពិធីក្រុងពាលី និងចម្រើនព្រះបរិត្ត*

# អ្នកវិនិយោគអារ៉ាប៊ីសាអូឌីត កំពុងស្វែងរកឱកាសវិនិយោគនៅកម្ពុជា



*ឯកឧត្តម Mohammed Ismaeil A. Dahlwy និងសម្តេចតេជោ ហ៊ុន សែន*

ក្នុងឱកាសចូលជួបសម្តែងការគួរសមនិងជម្រាបលាសម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** ប្រធានព្រឹទ្ធសភានៃព្រះរាជាណាចក្រកម្ពុជា នាព្រឹកថ្ងៃទី៦ ខែមករា ឆ្នាំ២០២៦ នៅវិមានព្រឹទ្ធសភា ឯកឧត្តម Mohammed Ismaeil A. Dahlwy ឯកអគ្គរាជទូតវិសាមញ្ញនិងពេញសមត្ថភាព នៃព្រះរាជាណាចក្រអារ៉ាប៊ីសាអូឌីត ប្រចាំព្រះរាជាណាចក្រកម្ពុជា បានជម្រាបថា នៅឆ្នាំ២០២៦នេះ អ្នកវិនិយោគរបស់អារ៉ាប៊ីសាអូឌីត នឹងមកបំពេញទស្សនកិច្ចនៅកម្ពុជា ដើម្បីស្វែងរកនូវឱកាសវិនិយោគផ្សេងៗ តាមរយៈសភាពាណិជ្ជកម្មរបស់អារ៉ាប៊ីសាអូឌីត។

**ឯកឧត្តមឯកអគ្គរាជទូត** បានកោតសរសើរចំពោះភាពរីកចម្រើន ជាពិសេសការអភិវឌ្ឍលើគ្រប់វិស័យរបស់កម្ពុជា ហើយឯកឧត្តមសង្ឃឹមថា ប្រទេសកម្ពុជានឹងក្លាយទៅជាប្រទេសមួយមានភាពរីកចម្រើននៅក្នុងតំបន់អាស៊ាន។ ទន្ទឹមនឹងនេះ ឯកឧត្តមក៏បានបញ្ជាក់ថា តាមរយៈការផ្លាស់ប្តូរទស្សនកិច្ចទៅវិញទៅមករបស់ថ្នាក់ដឹកនាំនៃប្រទេសទាំងពីរ បានធ្វើឱ្យទំនាក់ទំនងរវាងប្រទេសទាំងពីរកាន់តែរឹងមាំ និងរីកចម្រើន។

**សម្តេចតេជោ** មានសេចក្តីរីករាយចំពោះការលើកឡើងរបស់**ឯកឧត្តមឯកអគ្គរាជទូត** ដែលជាស្នូលនៃកិច្ចសហការពាណិជ្ជកម្ម ក៏ដូចជាការវិនិយោគរវាងប្រទេសទាំងពីរឱ្យមានភាពរីកចម្រើន។ **សម្តេច**ស្វាគមន៍ប្រតិភូនៃសភាពាណិជ្ជកម្មអារ៉ាប៊ីសាអូឌីត ដែលនឹងមកស្វែងរកឱកាសវិនិយោគនៅកម្ពុជានិងរំពឹងថា សហប្រតិបត្តិការពាណិជ្ជកម្ម វិនិយោគ និងទំនាក់ទំនងប្រជាជនរវាងប្រទេសទាំងពីរ នឹងវិវត្តខ្ពស់ថែមមួយកម្រិតទៀត។

បន្ថែមពីនេះ **សម្តេចតេជោ**បានសម្តែងការពេញចិត្តចំពោះបេសកកម្មរបស់**ឯកឧត្តមឯកអគ្គរាជទូត** ដែលបានរួមចំណែកលើកកម្ពស់ទំនាក់ទំនងនិងសហប្រតិបត្តិការរវាងប្រទេសទាំងពីរ ជាពិសេសការសម្របសម្រួលដំណើរទស្សនកិច្ចរបស់ **សម្តេចតេជោ** អញ្ជើញទៅអារ៉ាប៊ីសាអូឌីត កាលពីកន្លងទៅ។

ជាចុងក្រោយ សម្តេចតេជោ **ហ៊ុន សែន** បានជូនពរ **ឯកឧត្តមឯកអគ្គរាជទូត** ទទួលបាននូវភាពជោគជ័យក្នុងបេសកកម្មការងារជាបន្តបន្ទាប់ទៀត៕



*ទិដ្ឋភាពក្នុងជំនួបសម្តែងការគួរសមនិងជម្រាបលា*

ប្រភព៖ Telegram Channel សម្តេចតេជោ

រូបភាព, សម្រួលខ្លឹមសារ៖ នាយកដ្ឋានព័ត៌មាន

# ឯកឧត្តម អ៊ុច បូរិទ្ធ អញ្ជើញដឹកនាំកិច្ចប្រជុំគណៈកម្មាធិការអចិន្ត្រៃយ៍ព្រឹទ្ធសភា ដើម្បីពិនិត្យសម្រេចលើរបៀបវារៈចំនួន៦

នាព្រឹកថ្ងៃអង្គារ ទី៣០ ខែធ្នូ ឆ្នាំ២០២៥ នៅវិមានព្រឹទ្ធសភា ឯកឧត្តម **អ៊ុច បូរិទ្ធ** អនុប្រធានទី១ព្រឹទ្ធសភា បានអញ្ជើញដឹកនាំកិច្ចប្រជុំគណៈកម្មាធិការអចិន្ត្រៃយ៍ព្រឹទ្ធសភានីតិកាលទី៥ដើម្បីពិនិត្យសម្រេចលើរបៀបវារៈចំនួន៦ រួមមាន៖



*ឯកឧត្តម អ៊ុច បូរិទ្ធ ដឹកនាំកិច្ចប្រជុំគណៈកម្មាធិការអចិន្ត្រៃយ៍ព្រឹទ្ធសភា*

១-ពិនិត្យសំណើរបស់រដ្ឋសភា សុំពិនិត្យហើយឱ្យយោបល់លើសេចក្តីព្រាងច្បាប់ស្តីពី អាកាសចរណ៍ស៊ីវិល នៃព្រះរាជាណាចក្រកម្ពុជា។

២-ពិនិត្យសំណើរបស់រដ្ឋសភា សុំពិនិត្យហើយឱ្យយោបល់លើសេចក្តីព្រាងច្បាប់ស្តីពី ការអនុម័តយល់ព្រមលើកិច្ចព្រមព្រៀងគ្រប់ជ្រុងជ្រោយ ស្តីពីការដឹកជញ្ជូនតាមផ្លូវអាកាស រវាងរដ្ឋសមាជិកសមាគមប្រជាជាតិអាស៊ីអាគ្នេយ៍និងសហភាពអឺរ៉ុប និងរដ្ឋសមាជិករបស់ខ្លួន។

៣-ពិនិត្យសំណើរបស់រដ្ឋសភា សុំពិនិត្យហើយឱ្យយោបល់លើសេចក្តីព្រាងច្បាប់ស្តីពី ការអនុម័តយល់ព្រមលើពិធីសារទី៣ ស្តីពីការពង្រីកសិទ្ធិហោះហើរទី៥ រវាងភាគីចុះកិច្ចព្រមព្រៀងក្រោមកិច្ចព្រមព្រៀងដឹកជញ្ជូនតាមផ្លូវអាកាស រវាងរដ្ឋាភិបាល នៃរដ្ឋសមាជិកសមាគមប្រជាជាតិអាស៊ីអាគ្នេយ៍ និងរដ្ឋាភិបាល នៃសាធារណរដ្ឋប្រជាមានិតចិន។

៤-ពិនិត្យសំណើរបស់រដ្ឋសភា សុំពិនិត្យហើយឱ្យយោបល់លើសេចក្តីព្រាងច្បាប់ស្តីពី ការអនុម័តយល់ព្រមលើពិធីសារអនុវត្តកញ្ចប់កិច្ចសន្យាទី១១ និងទី១២ នៃសេវាកម្មដឹកជញ្ជូនតាមផ្លូវអាកាសក្រោមកិច្ចព្រមព្រៀងក្របខ័ណ្ឌអាស៊ាន ស្តីពីសេវាកម្ម។

៥-ពិនិត្យនិងសម្រេចលើសំណើរបស់គណបក្សប្រជាជនកម្ពុជាលេខ ០១៩/១២២៥/លគ.គក ចុះថ្ងៃទី២៦ ខែធ្នូ ឆ្នាំ២០២៥។

៦-ផ្សេងៗ។



*ទិដ្ឋភាពក្នុងកិច្ចប្រជុំគណៈកម្មាធិការអចិន្ត្រៃយ៍ព្រឹទ្ធសភា*

បន្ទាប់ពីបានពិនិត្យនិងពិភាក្សារួចមក គណៈកម្មាធិការអចិន្ត្រៃយ៍ព្រឹទ្ធសភា បានសម្រេច ដូចខាងក្រោម៖

១-ប្រគល់ភារកិច្ចជូនគណៈកម្មការសាធារណការ ដឹកជញ្ជូន អាកាសចរណ៍ស៊ីវិល ប្រៃសណីយ៍ ទូរគមនាគមន៍ ឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា នវានុវត្តន៍ រ៉ែ ថាមពល ពាណិជ្ជកម្ម រៀបចំដែនដី នគរូបនីយកម្ម និងសំណង់ នៃព្រឹទ្ធសភា ដើម្បីពិនិត្យសិក្សាលើសេចក្តីព្រាងច្បាប់ស្តីពីអាកាសចរណ៍ស៊ីវិល នៃព្រះរាជាណាចក្រកម្ពុជា។

២-ប្រគល់ភារកិច្ចជូនគណៈកម្មការកិច្ចការបរទេស សហប្រតិបត្តិការអន្តរជាតិ និងព័ត៌មាន ដោយសហការជាមួយគណៈកម្មការសាធារណការ ដឹកជញ្ជូន អាកាសចរណ៍ស៊ីវិល ប្រៃសណីយ៍ ទូរគមនាគមន៍ ឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា នវានុវត្តន៍ រ៉ែ ថាមពល ពាណិជ្ជកម្ម រៀបចំដែនដី នគរូបនីយកម្ម និងសំណង់ នៃព្រឹទ្ធសភា ដើម្បីពិនិត្យសិក្សាលើសេចក្តីព្រាងច្បាប់ស្តីពី ការអនុម័តយល់ព្រមលើកិច្ចព្រមព្រៀងគ្រប់ជ្រុងជ្រោយ ស្តីពីការដឹកជញ្ជូនតាមផ្លូវអាកាស រវាងរដ្ឋសមាជិកសមាគមប្រជាជាតិអាស៊ីអាគ្នេយ៍ និងសហភាពអឺរ៉ុបនិងរដ្ឋសមាជិករបស់ខ្លួន។

៣-ប្រគល់ភារកិច្ចជូនគណៈកម្មការកិច្ចការបរទេស សហប្រតិបត្តិការអន្តរជាតិ និងព័ត៌មាន ដោយសហការជាមួយគណៈកម្មការសាធារណការ ដឹកជញ្ជូន អាកាសចរណ៍ស៊ីវិល ប្រៃសណីយ៍ ទូរគមនាគមន៍ ឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា នវានុវត្តន៍ រ៉ែ ថាមពល ពាណិជ្ជកម្ម រៀបចំដែនដី នគរូបនីយកម្ម និងសំណង់ នៃព្រឹទ្ធសភា ដើម្បីពិនិត្យសិក្សាលើសេចក្តីព្រាងច្បាប់ស្តីពី ការអនុម័តយល់ព្រមលើពិធីសារទី៣ ស្តីពីការពង្រីកសិទ្ធិហោះហើរទី៥រវាងភាគីចុះកិច្ចព្រមព្រៀង ក្រោមកិច្ចព្រមព្រៀងដឹកជញ្ជូនតាមផ្លូវអាកាស រវាងរដ្ឋាភិបាល នៃរដ្ឋសមាជិកសមាគមប្រជាជាតិអាស៊ីអាគ្នេយ៍ និងរដ្ឋាភិបាល នៃសាធារណរដ្ឋប្រជាមានិតចិន។

៤-ប្រគល់ភារកិច្ចជូនគណៈកម្មការកិច្ចការបរទេស សហប្រតិបត្តិការអន្តរជាតិ និងព័ត៌មាន ដោយសហការជាមួយគណៈកម្មការសាធារណការ ដឹកជញ្ជូន អាកាសចរណ៍ស៊ីវិល ប្រៃសណីយ៍ ទូរគមនាគមន៍ ឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា នវានុវត្តន៍ រ៉ែ ថាមពល ពាណិជ្ជកម្ម រៀបចំដែនដី នគរូបនីយកម្ម និងសំណង់ នៃព្រឹទ្ធសភា ដើម្បីពិនិត្យសិក្សា លើសេចក្តីព្រាងច្បាប់ស្តីពី ការអនុម័តយល់ព្រមលើពិធីសារអនុវត្តកញ្ចប់កិច្ចសន្យាទី១១ និងទី១២នៃសេវាកម្មដឹកជញ្ជូនតាមផ្លូវអាកាស ក្រោមកិច្ចព្រមព្រៀងក្របខ័ណ្ឌអាស៊ានស្តីពីសេវាកម្ម។

៥-ទទួលយកសំណើរបស់គណបក្សប្រជាជនកម្ពុជា ដើម្បីប្រកាសទទួលស្គាល់សមាជិក ព្រឹទ្ធសភាថ្មី។

អត្ថបទ និងរូបភាព៖ នាយកដ្ឋានព័ត៌មាន



*ទិដ្ឋភាពក្នុងកិច្ចប្រជុំគណៈកម្មាធិការអចិន្ត្រៃយ៍ព្រឹទ្ធសភា*

# ឯកឧត្តម អ៊ុច បូររិទ្ធ អញ្ជើញដឹកនាំកិច្ចប្រជុំគណៈកម្មាធិការអចិន្ត្រៃយ៍ព្រឹទ្ធសភា ដើម្បីពិនិត្យសម្រេចលើរបៀបវារៈសម្រាប់សម័យប្រជុំលើកទី៤ព្រឹទ្ធសភា នីតិកាលទី៥



*ឯកឧត្តម អ៊ុច បូររិទ្ធ ដឹកនាំកិច្ចប្រជុំគណៈកម្មាធិការអចិន្ត្រៃយ៍ព្រឹទ្ធសភា*

នាព្រឹកថ្ងៃចន្ទ ២រោច ខែបុស្ស ឆ្នាំម្សាញ់ សប្តស័ក ពុទ្ធសករាជ២៥៦៩ ត្រូវនឹងថ្ងៃទី៥ ខែមករា ឆ្នាំ២០២៦ វេលាម៉ោង៨:០០នាទី ឯកឧត្តម **អ៊ុច បូររិទ្ធ** អនុប្រធានទី១ព្រឹទ្ធសភា បានអញ្ជើញដឹកនាំកិច្ចប្រជុំគណៈកម្មាធិការអចិន្ត្រៃយ៍ព្រឹទ្ធសភា នីតិកាលទី៥ ដើម្បីពិនិត្យសម្រេចលើរបៀបវារៈចំនួន៦ មានដូចខាងក្រោម៖

១-ពិនិត្យនិងសម្រេចលើសំណើរបស់គណៈកម្មការសាធារណការ ដឹកជញ្ជូន អាកាសចរណ៍ស៊ីវិល ប្រៃសណីយ៍ ទូរគមនាគមន៍ ឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា នវានុវត្តន៍ រ៉ែ ថាមពល ពាណិជ្ជកម្ម រៀបចំដែនដី នគរូបនីយកម្ម និងសំណង់ នៃព្រឹទ្ធសភា ( គណៈកម្មការទី៩ ) សុំដាក់សេចក្តីព្រាងច្បាប់ស្តីពី អាកាសចរណ៍ស៊ីវិល នៃព្រះរាជាណាចក្រកម្ពុជា ទៅក្នុងរបៀបវារៈសម័យប្រជុំលើកទី៤ព្រឹទ្ធសភានីតិកាលទី៥។

២-ពិនិត្យនិងសម្រេចលើសំណើរបស់គណៈកម្មការកិច្ចការបរទេស សហប្រតិបត្តិការអន្តរជាតិ និងព័ត៌មាន នៃព្រឹទ្ធសភា ( គណៈកម្មការទី៥ ) សុំដាក់សេចក្តីព្រាងច្បាប់ស្តីពី ការអនុម័តយល់ព្រមលើកិច្ចព្រមព្រៀងគ្រប់ជ្រុងជ្រោយស្តីពីការដឹកជញ្ជូនតាមផ្លូវអាកាស រវាងរដ្ឋសមាជិកសមាគមប្រជាជាតិអាស៊ីអាគ្នេយ៍និងសហភាពអឺរ៉ុប និងរដ្ឋសមាជិករបស់ខ្លួន ទៅក្នុងរបៀបវារៈសម័យប្រជុំលើកទី៤ព្រឹទ្ធសភានីតិកាលទី៥។

៣-ពិនិត្យនិងសម្រេចលើសំណើរបស់គណៈកម្មការកិច្ចការបរទេស សហប្រតិបត្តិការអន្តរជាតិ និងព័ត៌មាននៃព្រឹទ្ធសភា ( គណៈកម្មការទី៥ ) សុំដាក់សេចក្តីព្រាងច្បាប់ស្តីពីការអនុម័តយល់ព្រមលើពិធីសារទី៣ ស្តីពីការពង្រីកសិទ្ធិហោះហើរទី៥ រវាងភាគីចុះកិច្ចព្រមព្រៀងក្រោមកិច្ចព្រមព្រៀង



*ទិដ្ឋភាពក្នុងកិច្ចប្រជុំគណៈកម្មាធិការអចិន្ត្រៃយ៍ព្រឹទ្ធសភា*



*ទិដ្ឋភាពក្នុងកិច្ចប្រជុំគណៈកម្មាធិការអចិន្ត្រៃយ៍ព្រឹទ្ធសភា*

ដឹកជញ្ជូនតាមផ្លូវអាកាស រវាងរដ្ឋាភិបាល នៃរដ្ឋសមាជិកសមាគមប្រជាជាតិអាស៊ីអាគ្នេយ៍ និងរដ្ឋាភិបាល នៃសាធារណរដ្ឋប្រជាមានិតចិន ទៅក្នុងរបៀបវារៈសម័យប្រជុំលើកទី៤ ព្រឹទ្ធសភានីតិកាលទី៥។

៤-ពិនិត្យនិងសម្រេចលើសំណើរបស់គណៈកម្មការកិច្ចការបរទេស សហប្រតិបត្តិការអន្តរជាតិ និងព័ត៌មាន នៃព្រឹទ្ធសភា (គណៈកម្មការទី៥) សុំដាក់សេចក្តីព្រាងច្បាប់ស្តីពីការអនុម័តយល់ព្រមលើពិធីសារអនុវត្តកញ្ចប់កិច្ចសន្យាទី១១ និងទី១២ នៃសេវាកម្មដឹកជញ្ជូនតាមផ្លូវអាកាស ក្រោមកិច្ចព្រមព្រៀងក្របខ័ណ្ឌអាស៊ានស្តីពីសេវាកម្ម ទៅក្នុងរបៀបវារៈសម័យប្រជុំលើកទី៤ ព្រឹទ្ធសភានីតិកាលទី៥។

៥-កំណត់កាលបរិច្ឆេទ និងរបៀបវារៈបន្តសម័យប្រជុំលើកទី៤ ព្រឹទ្ធសភានីតិកាលទី៥។

៦-ផ្សេងៗ។

បន្ទាប់ពីបានពិនិត្យនិងពិភាក្សារួចមក គណៈកម្មាធិការអចិន្ត្រៃយ៍ព្រឹទ្ធសភា បានកំណត់យកថ្ងៃដដែល វេលាម៉ោង៩:០០នាទី ដើម្បីបន្តសម័យប្រជុំលើកទី៤ព្រឹទ្ធសភានីតិកាលទី៥ ដោយមានរបៀបវារៈចំនួន៥ដូចខាងក្រោម៖

១-ប្រកាសទទួលស្គាល់សមាជិកព្រឹទ្ធសភាថ្មី។

២-ពិនិត្យហើយឱ្យយោបល់លើសេចក្តីព្រាងច្បាប់ស្តីពី អាកាសចរណ៍ស៊ីវិលនៃព្រះរាជាណាចក្រកម្ពុជា។

៣-ពិនិត្យហើយឱ្យយោបល់លើសេចក្តីព្រាងច្បាប់ស្តីពី ការអនុម័តយល់ព្រមលើកិច្ចព្រមព្រៀងគ្រប់ជ្រុងជ្រោយស្តីពីការដឹកជញ្ជូនតាមផ្លូវអាកាស រវាងរដ្ឋសមាជិកសមាគមប្រជាជាតិអាស៊ីអាគ្នេយ៍និងសហភាពអឺរ៉ុបនិងរដ្ឋសមាជិករបស់ខ្លួន។

៤-ពិនិត្យហើយឱ្យយោបល់លើសេចក្តីព្រាងច្បាប់ស្តីពី ការអនុម័តយល់ព្រមលើពិធីសារទី៣ ស្តីពីការពង្រីកសិទ្ធិហោះហើរទី៥ រវាងភាគីចុះកិច្ចព្រមព្រៀងក្រោមកិច្ចព្រមព្រៀងដឹកជញ្ជូនតាមផ្លូវអាកាស រវាងរដ្ឋាភិបាល នៃរដ្ឋសមាជិកសមាគមប្រជាជាតិអាស៊ីអាគ្នេយ៍ និងរដ្ឋាភិបាលនៃសាធារណរដ្ឋប្រជាមានិតចិន។

៥-ពិនិត្យហើយឱ្យយោបល់លើសេចក្តីព្រាងច្បាប់ស្តីពី ការអនុម័តយល់ព្រមលើពិធីសារអនុវត្តកញ្ចប់កិច្ចសន្យាទី១១ និងទី១២នៃសេវាកម្មដឹកជញ្ជូនតាមផ្លូវអាកាស ក្រោមកិច្ចព្រមព្រៀងក្របខ័ណ្ឌអាស៊ានស្តីពីសេវាកម្ម៕

អត្ថបទ និងរូបភាព៖ នាយកដ្ឋានព័ត៌មាន

# ព្រឹទ្ធសភាប្រកាសទទួលស្គាល់សមាជិកថ្មីនិងឯកភាពទាំងស្រុងលើសេចក្តីព្រាងច្បាប់ចំនួន៤ ពាក់ព័ន្ធនឹងវិស័យអាកាសចរណ៍




*ឯកឧត្តម អ៊ុច បូររិទ្ធ អនុប្រធានទី១ព្រឹទ្ធសភា និងឯកឧត្តមបណ្ឌិត ជន់ វ្លៃនា អនុប្រធានទី២ព្រឹទ្ធសភា*

នាព្រឹកថ្ងៃចន្ទ ទី៥ ខែមករា ឆ្នាំ២០២៦ វេលាម៉ោង ៩:០០នាទី ព្រឹទ្ធសភា នៃព្រះរាជាណាចក្រកម្ពុជា បានបន្តសម័យប្រជុំលើកទី៤ ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់របស់ ឯកឧត្តម **អ៊ុច បូររិទ្ធ** អនុប្រធានទី១ព្រឹទ្ធសភានៃព្រះរាជាណាចក្រកម្ពុជា ដែលមានវត្តមានសមាជិកព្រឹទ្ធសភាចូលរួមចំនួន៥៦រូប។

អង្គប្រជុំបានដំណើរការដោយមានរបៀបវារៈចំនួន៥ដូចខាងក្រោម៖

**របៀបវារៈទី១៖ ប្រកាសទទួលស្គាល់សមាជិកព្រឹទ្ធសភាថ្មី។**



*ឯកឧត្តម ឡាយ សំកុល អញ្ជើញឡើងអានសេចក្តីសម្រេច ប្រកាសទទួលស្គាល់សមាជិកព្រឹទ្ធសភា*



*ឯកឧត្តម ឈើវ យីស៊ាង សមាជិកព្រឹទ្ធសភាថ្មី ជំនួសឯកឧត្តម ចែម វីឡ៉ា*

យោងតាមស្មារតីអង្គប្រជុំគណៈកម្មាធិការអចិន្ត្រៃយ៍ព្រឹទ្ធសភា នាថ្ងៃទី៥ ខែមករា ឆ្នាំ២០២៦ ក្នុងសម័យប្រជុំលើកទី៤ ព្រឹទ្ធសភានីតិកាលទី៥ នាព្រឹកថ្ងៃទី៥ ខែមករា ឆ្នាំ២០២៦ ឯកឧត្តម **ឈីវ យីស៊ាង** មណ្ឌលភូមិភាគទី១ (រាជធានីភ្នំពេញ) ត្រូវបានប្រកាសទទួលស្គាល់ជាសមាជិកព្រឹទ្ធសភាថ្មី ជំនួសឯកឧត្តម **ចែម វីឡ៉ា** ដែលត្រូវទៅបំពេញភារកិច្ចថ្មី។ សមាជិកថ្មីរូបនេះ ត្រូវធ្វើសច្ចាប្រណិធានមុនចូលកាន់តំណែង។

**របៀបវារៈទី២៖ ពិនិត្យហើយឱ្យយោបល់លើសេចក្តីព្រាងច្បាប់ស្តីពី អាកាសចរណ៍ស៊ីវិល នៃព្រះរាជាណាចក្រកម្ពុជា។**

សេចក្តីព្រាងច្បាប់នេះរៀបចំឡើងក្នុងគោលបំណងដើម្បីធានាសុវត្ថិភាព សន្តិសុខ សណ្តាប់ធ្នាប់ ប្រតិបត្តិការអាកាសចរណ៍ស៊ីវិល ជំរុញអភិវឌ្ឍការដឹកជញ្ជូនតាមផ្លូវអាកាសប្រកបដោយចីរភាព កាលានុវត្តភាព វិនិយោគ ការប្រកួតប្រជែង និងរួមចំណែកការពារបរិស្ថាន ព្រមទាំងលើក

កម្ពស់ផលប្រយោជន៍សមស្របរបស់អ្នកប្រើប្រាស់សេវាកម្មដឹកជញ្ជូនតាមផ្លូវអាកាសនៅក្នុងព្រះរាជាណាចក្រកម្ពុជា។

សេចក្តីព្រាងច្បាប់នេះ តាក់តែងឡើងក្នុងបរិបទនៃការរីកចម្រើនផ្នែកបច្ចេកវិទ្យា និងនវានុវត្តន៍ក្នុងវិស័យអាកាសចរណ៍សកល ហើយដែលច្បាប់ស្តីពី អាកាសចរណ៍ស៊ីវិលនៃព្រះរាជាណាចក្រកម្ពុជាក្នុងឆ្នាំ២០០៨ នៅពុំទាន់បានគ្របដណ្តប់គ្រប់សកម្មភាពនៅឡើយសម្រាប់អាកាសចរណ៍ស៊ីវិលថ្មីៗ ដែលកំពុងមានការវិវត្តរីកចម្រើនយ៉ាងខ្លាំងនៅក្នុងពិភពលោកដូចជា សកម្មភាពអាកាសយានគ្មានមនុស្សបើក ការងារពីលើអាកាស ការបណ្តុះបណ្តាលជំនាញបច្ចេកទេសអាកាសចរណ៍ ការងារឧត្តុនិយមអាកាសចរណ៍ រោងចក្រផលិតនិងអង្គភាពថែទាំបច្ចេកទេស អាកាសយាន ការបង្កើត និងការអនុវត្តផែនការ កម្មវិធីសុវត្ថិភាព និងសន្តិសុខអាកាសចរណ៍ស៊ីវិល ការទទួលខុសត្រូវនិងធានារ៉ាប់រង និងការការពារបរិស្ថាន។

សេចក្តីព្រាងច្បាប់នេះ រៀបចំឡើងមាន២៥ជំពូក និង ១០៤មាត្រា ត្រូវបានរដ្ឋសភា នៃព្រះរាជាណាចក្រកម្ពុជា អនុម័តយល់ព្រមលើកដំបូងចំនួន៩៧សំឡេង នៃចំនួនសមាជិករដ្ឋសភាទាំងមូល កាលពីថ្ងៃទី២៥ ខែធ្នូ ឆ្នាំ២០២៥ នាសម័យប្រជុំរដ្ឋសភាលើកទី៥ នីតិកាលទី៧។



*ឯកឧត្តម អ៊ុំ សារឹទ្ធ ឡើងអានរបាយការណ៍*

សេចក្តីព្រាងច្បាប់នេះ ត្រូវបានឯកឧត្តម **អ៊ុំ សារឹទ្ធ** ប្រធានគណៈកម្មការសាធារណការ ដឹកជញ្ជូន អាកាសចរណ៍ស៊ីវិល ប្រៃសណីយ៍ ទូរគមនាគមន៍ ឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា នវានុវត្តន៍ រ៉ែ ថាមពល ពាណិជ្ជកម្ម រៀបចំដែនដី នគរូបនីយកម្ម និងសំណង់ នៃព្រឹទ្ធសភា (គណៈកម្មការទី៩) អញ្ជើញឡើងរាយការណ៍ជូនអង្គប្រជុំអំពី លទ្ធផលនៃការពិនិត្យសិក្សាលើសេចក្តីព្រាងច្បាប់ ហើយមានសមាជិកព្រឹទ្ធសភាចំនួន៤រូប ឡើងមានយោបល់។

**របៀបវារៈទី៣៖ ពិនិត្យហើយឱ្យយោបល់លើសេចក្តីព្រាងច្បាប់ស្តីពី ការអនុម័តយល់ព្រមលើកិច្ចព្រមព្រៀងគ្រប់ជ្រុងជ្រោយ ស្តីពីការដឹកជញ្ជូនតាមផ្លូវអាកាស រវាងរដ្ឋសមាជិកសមាគមប្រជាជាតិអាស៊ីអាគ្នេយ៍និងសហភាពអឺរ៉ុប និងរដ្ឋសមាជិករបស់ខ្លួន។**

កិច្ចព្រមព្រៀងនេះ ត្រូវបានផ្តួចផ្តើមនិងរៀបចំឡើងដោយស្ថាប័នទទួលបន្ទុកវិស័យអាកាសចរណ៍ស៊ីវិល នៃរដ្ឋសមាជិកសមាគមប្រជាជាតិអាស៊ីអាគ្នេយ៍ និងសហភាពអឺរ៉ុប ចាប់តាំងពីឆ្នាំ២០១៦ ដើម្បីបម្រើសេវាកម្មដឹកជញ្ជូនតាមផ្លូវអាកាសអន្តរជាតិ។

កិច្ចព្រមព្រៀងនេះ នឹងផ្តល់នូវអត្ថប្រយោជន៍ឱ្យព្រះរាជាណាចក្រកម្ពុជា ដូចជា៖

**១.បង្ហាញពីសុច្ឆន្ទៈល្អនិងបង្កើនកិច្ចសហប្រតិបត្តិការរបស់កម្ពុជា ជាមួយរដ្ឋសមាជិកអាស៊ាននិងរដ្ឋសមាជិកនៃសហភាពអឺរ៉ុបក្នុងវិស័យអាកាសចរណ៍ស៊ីវិល។**

**២.ជំរុញការទាក់ទាញការវិនិយោគផ្នែកសេដ្ឋកិច្ចទេសចរណ៍ ការងារ និងផ្លាស់ប្តូរវប្បធម៌រវាងប្រជាជន និងប្រជាជននៃតំបន់ទាំងពីរជាពិសេសរវាងព្រះរាជាណាចក្រកម្ពុជា ជាមួយរដ្ឋសមាជិកនៃសហភាពអឺរ៉ុប។**

**៣.ជំរុញក្រុមហ៊ុនអាកាសចរណ៍ជាតិនិងអន្តរជាតិដើម្បីរៀបចំផែនការហោះហើររបស់ខ្លួនលើដំណាក់ផ្លូវរវាងព្រះរាជាណាចក្រកម្ពុជានិងរដ្ឋជាសមាជិកនៃសហភាពអឺរ៉ុប តាមរយៈជើងហោះហើរដោយអនុវត្តសិទ្ធិហោះហើរទី៣ និងទី៤។**

**៤.បង្ហាញការធានាបានសុវត្ថិភាព និងសន្តិសុខអាកាសចរណ៍កម្រិតខ្ពស់បំផុតនៅព្រះរាជាណាចក្រកម្ពុជាជាមួយនឹងប្រទេសជាដៃគូរបស់ខ្លួន។**

**៥.ធានាបានតម្លាភាពក្នុងការប្រកួតប្រជែងស្មើភាពជូនដល់ក្រុមហ៊ុនអាកាសចរណ៍កម្ពុជានិងក្រុមហ៊ុនអាកាសចរណ៍មកពីតំបន់អាស៊ាននិងសហភាពអឺរ៉ុប។**

**៦.បង្កើនកិច្ចសម្រួលការធ្វើដំណើរតាមផ្លូវអាកាសអន្តរជាតិប្រកបដោយសន្តិសុខ សុវត្ថិភាព ផាសុខភាពប្រើប្រាស់រយៈពេលខ្លី និងចំណាយតិច រវាងព្រះរាជាណាចក្រកម្ពុជាជាមួយតំបន់អាស៊ាននិង**

តំបន់សហភាពអឺរ៉ុប។

សេចក្តីព្រាងច្បាប់នេះ រៀបចំឡើងមាន២មាត្រា ត្រូវបានរដ្ឋសភានៃព្រះរាជាណាចក្រកម្ពុជា អនុម័តយល់ព្រមលើកដំបូងចំនួន៩៧សំឡេង នៃចំនួនសមាជិករដ្ឋសភាទាំងមូល កាលពីថ្ងៃទី២៥ ខែធ្នូ ឆ្នាំ២០២៥ នាសម័យប្រជុំរដ្ឋសភាលើកទី៥ នីតិកាលទី៧។

**របៀបវារៈទី៤៖ ពិនិត្យហើយឱ្យយោបល់លើសេចក្តីព្រាងច្បាប់ស្តីពី ការអនុម័តយល់ព្រមលើពិធីសារទី៣ ស្តីពីការពង្រីកសិទ្ធិហោះហើរទី៥ រវាងភាគីចុះកិច្ចព្រមព្រៀងក្រោមកិច្ចព្រមព្រៀងដឹកជញ្ជូនតាមផ្លូវអាកាស រវាងរដ្ឋាភិបាលនៃរដ្ឋសមាជិកសមាគមប្រជាជាតិអាស៊ីអាគ្នេយ៍ និងរដ្ឋាភិបាល នៃសាធារណរដ្ឋប្រជាមានិតចិន។**

ពិធីសារទី៣នេះ គឺជាពិធីសារបន្ថែមលើកិច្ចព្រមព្រៀងដឹកជញ្ជូនតាមផ្លូវអាកាសរវាងរដ្ឋាភិបាល នៃរដ្ឋសមាជិកសមាគមប្រជាជាតិអាស៊ីអាគ្នេយ៍ និងរដ្ឋាភិបាល នៃសាធារណរដ្ឋប្រជាមានិតចិន រួមទាំងពិធីសារទី១ និងពិធីសារទី២ ដែលព្រះរាជាណាចក្រកម្ពុជាបានផ្តល់សច្ចាប័ន កាលពីថ្ងៃទី១៧ ខែតុលា ឆ្នាំ២០១៦។

ពិធីសារទី៣នេះ នឹងផ្តល់នូវអត្ថប្រយោជន៍ឱ្យព្រះរាជាណាចក្រកម្ពុជា រួមមាន៖

**១.ជំរុញការទាក់ទាញការដឹកជញ្ជូនតាមផ្លូវអាកាសអន្តរជាតិ វិនិយោគ សេដ្ឋកិច្ច ទេសចរណ៍ ការងារ និងផ្លាស់ប្តូរវប្បធម៌ រវាងប្រជាជនកម្ពុជានិងប្រជាជនចិន រួមទាំងអាស៊ាន និងចិន។**

**២.ជំរុញក្រុមហ៊ុនទេសចរណ៍កម្ពុជានិងចិន ដើម្បីរៀបចំផែនការហោះហើររបស់ខ្លួនបន្ថែមទៀតលើការអនុវត្តសិទ្ធិហោះហើរទី៥ រវាងកម្ពុជានិងចិន ដោយឆ្លងកាត់តំបន់អាស៊ាន ក្នុងការដឹកជញ្ជូនអ្នកដំណើរនិងទំនិញតាមផ្លូវអាកាសអន្តរជាតិ។**

**៣.បង្កើនជម្រើសកាន់តែច្រើនថែមទៀតដល់អ្នកដំណើរតាមផ្លូវអាកាសអន្តរជាតិរវាងកម្ពុជានិងចិន ប្រកបដោយសន្តិសុខ សុវត្ថិភាព និងផាសុខភាព។**

**៤.ទទួលបានការទាក់ទាញលើការកសាង និងការតភ្ជាប់ហេដ្ឋារចនាសម្ព័ន្ធអាកាសចរណ៍ស៊ីវិល រវាងកម្ពុជានិងចិនដែលកម្ពុជាទទួលបានលទ្ធផលផ្លែផ្កាល្អរួចមកហើយ តាមរយៈការអនុវត្តគម្រោងលើគំនិតផ្តួចផ្តើមខ្សែក្រវាត់ និងផ្លូវរបស់សាធារណរដ្ឋប្រជាមានិតចិន។**

**៥.រួមចំណែកដល់ការអនុវត្តយុទ្ធសាស្ត្រគ្រប់ជ្រុងជ្រោយកម្ពុជានិងចិន ក្រោមទិដ្ឋភាពការអនុវត្តកិច្ចព្រមព្រៀងដឹកជញ្ជូនតាមផ្លូវអាកាសអាស៊ាន-ចិន រួមទាំងពិធីសារទី១ ទី២ និងទី៣។**

សេចក្តីព្រាងច្បាប់នេះ រៀបចំឡើងមាន២មាត្រា ត្រូវបានរដ្ឋសភា នៃព្រះរាជាណាចក្រកម្ពុជា អនុម័តយល់ព្រមលើកដំបូងចំនួន៩៧សំឡេង នៃចំនួនសមាជិករដ្ឋសភាទាំងមូល កាលពីថ្ងៃទី២៥ ខែធ្នូ ឆ្នាំ២០២៥ នាសម័យប្រជុំរដ្ឋសភាលើកទី៥ នីតិកាលទី៧។

**របៀបវារៈទី៥៖ ពិនិត្យហើយឱ្យយោបល់លើសេចក្តីព្រាងច្បាប់ស្តីពី ការអនុម័តយល់ព្រមលើពិធីសារអនុវត្តកញ្ចប់កិច្ចសន្យាទី១១ និងទី១២ នៃសេវាកម្មដឹកជញ្ជូនតាមផ្លូវអាកាស ក្រោមកិច្ចព្រមព្រៀងក្របខ័ណ្ឌអាស៊ាន ស្តីពីសេវាកម្ម។**

ពិធីសារទី១១និងទី១២នេះ ត្រូវបានផ្តួចផ្តើមនិងរៀបចំឡើងដោយស្ថាប័នទទួលបន្ទុក វិស័យអាកាសចរណ៍ស៊ីវិល នៃរដ្ឋសមាជិកសមាគមប្រជាជាតិអាស៊ីអាគ្នេយ៍។ ពិធីសារ



*ទិដ្ឋភាពក្នុងសម័យប្រជុំលើកទី៤ព្រឹទ្ធសភា នីតិកាលទី៥*



ឯកឧត្តម ខ៊ាន់ ចំរើន ឡើងអានរបាយការណ៍



ឯកឧត្តម ម៉ៅ ហាវណ្ណាល់ ឡើងការពារសេចក្តីព្រាងច្បាប់

នេះ គឺជាពិធីសារបន្ថែមលើពិធីសារទី១ដល់ទី១០ ដែលព្រះរាជាណាចក្រកម្ពុជាបានផ្តល់សច្ចាប័នរួច។

ពិធីសារទី១១ និងទី១២នេះ នឹងផ្តល់នូវអត្ថប្រយោជន៍ឱ្យព្រះរាជាណាចក្រកម្ពុជា មានជាអាទិ៍៖

**១.បំពេញកាតព្វកិច្ច ក្នុងនាមរដ្ឋសមាជិកអាស៊ាន ដើម្បីសម្រេចបាននូវចក្ខុវិស័យនៃសហគមន៍សេដ្ឋកិច្ចអាស៊ានតែមួយ តាមរយៈការកសាងទីផ្សារអាកាសចរណ៍អាស៊ានតែមួយ។**

**២.ជំរុញឱ្យកាន់តែល្អប្រសើរលើសកម្មភាពការងារសមាហរណកម្មនៅក្នុងតំបន់អាស៊ាននៃវិស័យអាកាសចរណ៍ស៊ីវិលតាមរយៈការបើកចំហទីផ្សារបន្ថែម នៃសេវាកម្មដឹកជញ្ជូនតាមផ្លូវអាកាសអន្តរជាតិ។**

**៣.ទាក់ទាញបន្ថែមទៀតនៃការវិនិយោគលើផ្នែកសេវាកម្មដឹកជញ្ជូនតាមផ្លូវអាកាសនៅកម្ពុជា ពីបណ្តាប្រទេសសមាជិកអាស៊ាន។**

សេចក្តីព្រាងច្បាប់នេះ រៀបចំឡើងមាន ២មាត្រា ត្រូវបានរដ្ឋសភា នៃព្រះរាជាណាចក្រកម្ពុជា អនុម័តយល់ព្រមលើកដំបូងចំនួន៩៧សំឡេង នៃចំនួនសមាជិករដ្ឋសភាទាំងមូល កាលពីថ្ងៃទី២៥ ខែធ្នូ ឆ្នាំ២០២៥ នាសម័យប្រជុំរដ្ឋសភាលើកទី៥ នីតិកាលទី៧។

សេចក្តីព្រាងច្បាប់ទាំង៣ខាងលើនេះ ត្រូវបានឯកឧត្តម **ខ៊ាន់ ចំរើន** ប្រធានស្តីទីគណៈកម្មការកិច្ចការបរទេស សហប្រតិបត្តិការអន្តរជាតិនិងព័ត៌មាន នៃព្រឹទ្ធសភា (គណៈកម្មការទី៥) អញ្ជើញឡើងរាយការណ៍ជូនអង្គប្រជុំអំពីលទ្ធផលនៃការពិនិត្យសិក្សាលើសេចក្តីព្រាងច្បាប់ និងមានសមាជិកព្រឹទ្ធសភាចំនួន១រូប ឡើងមានយោបល់។

សូមជម្រាបថា ឯកឧត្តម **ម៉ៅ ហាវណ្ណាល់** រដ្ឋមន្ត្រីទទួលបន្ទុករដ្ឋលេខាធិការដ្ឋានអាកាសចរណ៍ស៊ីវិល បានអញ្ជើញឆ្លើយបំភ្លឺជូនអង្គប្រជុំព្រឹទ្ធសភាលើសេចក្តីព្រាងច្បាប់នីមួយៗខាងលើ។

អង្គប្រជុំព្រឹទ្ធសភាបានពិនិត្យហើយឱ្យយោបល់ឯកភាពទាំងស្រុងលើសេចក្តីព្រាងច្បាប់ទាំង៤ខាងលើ ដោយឥតកែប្រែចំនួន៥៦សំឡេងនៃចំនួនសមាជិកព្រឹទ្ធសភាទាំងមូល៕

អត្ថបទ និងរូបភាព៖ នាយកដ្ឋានព័ត៌មាន





ទិដ្ឋភាពសមាជិក សមាជិកាព្រឹទ្ធសភា លើកដៃអនុម័តច្បាប់

# ព្រឹទ្ធសភាបើកកិច្ចប្រជុំគណៈកម្មាធិការអចិន្ត្រៃយ៍ ដើម្បីពិនិត្យសម្រេចលើរបៀបវារៈចំនួន៣

នាព្រឹកថ្ងៃចន្ទ ទី១៩ ខែមករា ឆ្នាំ២០២៦ ឯកឧត្តម **អ៊ុច បូររិទ្ធ** អនុប្រធានទី១ ព្រឹទ្ធសភា បានអញ្ជើញដឹកនាំកិច្ចប្រជុំគណៈកម្មាធិការអចិន្ត្រៃយ៍ព្រឹទ្ធសភា នីតិកាលទី៥ ដើម្បីពិនិត្យសម្រេចលើរបៀបវារៈចំនួន៣ មានដូចខាងក្រោម៖



*ឯកឧត្តម អ៊ុច បូររិទ្ធ ដឹកនាំកិច្ចប្រជុំគណៈកម្មាធិការអចិន្ត្រៃយ៍ព្រឹទ្ធសភា*

**១-ពិនិត្យសំណើរបស់រដ្ឋសភា សុំពិនិត្យហើយឱ្យយោបល់លើសេចក្តីព្រាងច្បាប់ស្តីពី ការអនុម័តយល់ព្រមលើអនុសញ្ញាអង្គការសហប្រជាជាតិស្តីពីនីតិសមុទ្រ។**

**២-ពិនិត្យនិងសម្រេចអំពីនីតិវិធីបោះឆ្នោតជ្រើសរើសបំពេញសមាជិកគណៈកម្មការ កិច្ចការបរទេស សហប្រតិបត្តិការអន្តរជាតិ និងព័ត៌មាន នៃព្រឹទ្ធ-សភា ទៅក្នុងរបៀបវារៈ សម័យប្រជុំព្រឹទ្ធសភាជាវិសាមញ្ញ នីតិកាលទី៥។**

**៣-ផ្សេងៗ។**



*ទិដ្ឋភាពក្នុងកិច្ចប្រជុំគណៈកម្មាធិការអចិន្ត្រៃយ៍ព្រឹទ្ធសភា*

ឆ្លងតាមការពិនិត្យនិងពិភាក្សារួចមក គណៈកម្មាធិការអចិន្ត្រៃយ៍ព្រឹទ្ធសភា បានសម្រេចដូចខាងក្រោម៖

**១-បញ្ជូនសេចក្តីព្រាងច្បាប់ស្តីពី ការអនុម័តយល់ព្រមលើអនុសញ្ញាអង្គការសហប្រជាជាតិស្តីពី នីតិសមុទ្រ ទៅឱ្យគណៈកម្មការនីតិកម្ម និងយុត្តិធម៌ សហការជាមួយគណៈកម្មការកិច្ចការបរទេស សហប្រតិបត្តិការអន្តរជាតិ និងព័ត៌មាន និងគណៈ-កម្មការមហាផ្ទៃ ការពារជាតិ មុខងារសាធារណៈ និងកិច្ចការព្រំដែន នៃព្រឹទ្ធសភា ដើម្បីពិនិត្យសិក្សា និងនាំយកយោបល់ជូនគណៈកម្មាធិការអចិន្ត្រៃយ៍ និងសម័យប្រជុំពេញអង្គព្រឹទ្ធសភា។**

**២-ការបោះឆ្នោតជ្រើសរើសបំពេញសមាជិកគណៈ-កម្មការកិច្ចការបរទេស សហប្រតិបត្តិការអន្តរជាតិ និងព័ត៌មាន នៃព្រឹទ្ធសភា ទៅក្នុងរបៀបវារៈសម័យប្រជុំព្រឹទ្ធសភាជាវិសាមញ្ញ នីតិកាលទី៥។**

អត្ថបទ និងរូបភាព៖ នាយកដ្ឋានព័ត៌មាន

# គណៈកម្មាធិការអចិន្ត្រៃយ៍ព្រឹទ្ធសភា ពិនិត្យសម្រេចលើរបៀបវារៈ សម្រាប់ប្រជុំព្រឹទ្ធសភាជាវិសាមញ្ញ នីតិកាលទី៥



ឯកឧត្តម អ៊ុច បូរិទ្ធ ដឹកនាំកិច្ចប្រជុំគណៈកម្មាធិការអចិន្ត្រៃយ៍ព្រឹទ្ធសភា

នៅព្រឹកថ្ងៃពុធ ទី២១ ខែមករា ឆ្នាំ២០២៦ វេលាម៉ោង៨:០០នាទី ឯកឧត្តម **អ៊ុច បូរិទ្ធ** អនុប្រធានទី១ព្រឹទ្ធសភា បានអញ្ជើញដឹកនាំកិច្ចប្រជុំគណៈកម្មាធិការអចិន្ត្រៃយ៍ព្រឹទ្ធសភា ដើម្បីពិនិត្យសម្រេចលើរបៀបវារៈចំនួន៣ មានដូចខាងក្រោម៖

**១-ពិនិត្យ និងសម្រេចលើសំណើរបស់គណៈកម្មការនីតិកម្មនិងយុត្តិធម៌ សុំដាក់សេចក្តីព្រាងច្បាប់ ស្តីពី ការអនុម័តយល់ព្រមលើអនុសញ្ញាអង្គការសហប្រជាជាតិស្តីពី នីតិសមុទ្រ ទៅក្នុងរបៀបវារៈសម័យប្រជុំព្រឹទ្ធសភាជាវិសាមញ្ញ នីតិកាលទី៥។**

**២-កំណត់កាលបរិច្ឆេទ របៀបវារៈ និងសមាសភាពលេខាធិការសម័យប្រជុំព្រឹទ្ធសភាជាវិសាមញ្ញ នីតិកាលទី៥។**

**៣-ផ្សេងៗ។**

ឆ្លងតាមរយៈការពិនិត្យនិងពិភាក្សារួចមក គណៈកម្មាធិការអចិន្ត្រៃយ៍ព្រឹទ្ធសភាបានកំណត់យកថ្ងៃពុធ ទី២១ ខែមករា ឆ្នាំ២០២៦ នាវេលាម៉ោង៩:០០នាទីព្រឹក ដើម្បីបើកសម័យប្រជុំព្រឹទ្ធសភាជាវិសាមញ្ញ នីតិកាលទី៥ ដោយមានរបៀបវារៈចំនួន២៖

**១-ពិនិត្យ ហើយឱ្យយោបល់លើសេចក្តីព្រាងច្បាប់ ស្តីពី ការអនុម័តយល់ព្រមលើអនុសញ្ញាអង្គការសហប្រជាជាតិស្តីពី នីតិសមុទ្រ។**

**២-បោះឆ្នោតជ្រើសរើសបំពេញសមាជិកគណៈកម្មការកិច្ចការបរទេស សហប្រតិបត្តិការអន្តរជាតិ និងព័ត៌មាន នៃព្រឹទ្ធសភានីតិកាលទី៥៕**

អត្ថបទ និងរូបភាព៖ នាយកដ្ឋានព័ត៌មាន


ទិដ្ឋភាពក្នុងកិច្ចប្រជុំគណៈកម្មាធិការអចិន្ត្រៃយ៍ព្រឹទ្ធសភា

# ព្រឹទ្ធសភាឯកភាពទាំងស្រុងលើសេចក្តីព្រាងច្បាប់សមុទ្រ និងបោះឆ្នោតជ្រើសរើសបំពេញសមាជិកគណៈកម្មការទី៥ព្រឹទ្ធសភា



*ឯកឧត្តម អ៊ុច បូរិទ្ធ អនុប្រធានទី១ព្រឹទ្ធសភា និងឯកឧត្តមបណ្ឌិត ធន់ វឌ្ឍនា អនុប្រធានទី២ព្រឹទ្ធសភា*

ផ្អែកតាមស្មារតីនៃកិច្ចប្រជុំគណៈកម្មាធិការអចិន្ត្រៃយ៍ព្រឹទ្ធសភា នាព្រឹកថ្ងៃទី២១ ខែមករា ឆ្នាំ២០២៦ នៅព្រឹកថ្ងៃដដែលនេះ វេលាម៉ោង៩:០០នាទី ឯកឧត្តម **អ៊ុច បូរិទ្ធ** អនុប្រធានទី១ព្រឹទ្ធសភា បានអញ្ជើញដឹកនាំសម័យប្រជុំព្រឹទ្ធសភាជាវិសាមញ្ញ នីតិកាលទី៥ ដោយមានវត្តមានសមាជិកព្រឹទ្ធសភាចូលរួមចំនួន៥៨រូប។ អង្គប្រជុំបានដំណើរការដោយមានរបៀបវារៈចំនួន២ ដូចខាងក្រោម៖

**របៀបវារៈទី១៖ ពិនិត្យ ហើយឱ្យយោបល់លើសេចក្តីព្រាងច្បាប់ស្តីពី ការអនុម័តយល់ព្រមលើអនុសញ្ញាអង្គការសហប្រជាជាតិស្តីពី នីតិសមុទ្រ។**

អនុសញ្ញាអង្គការសហប្រជាជាតិស្តីពីនីតិសមុទ្រ (ហៅកាត់ថា UNCLOS) គឺជាឧបករណ៍គតិយុត្តអន្តរជាតិដ៏សំខាន់និងមានលក្ខណៈសកល ដែលកំណត់ព្រំដែនសមុទ្រ សេរីភាពផ្នែកនាវាចរណ៍តាមផ្លូវសមុទ្រ, សិទ្ធិ និងកាតព្វកិច្ចរបស់រដ្ឋភាគីក្នុងការប្រើប្រាស់លម្ហសមុទ្រ, សេចក្តីណែនាំនានាសម្រាប់ការធ្វើធុរកិច្ច កិច្ចការពារបរិស្ថាន ការគ្រប់គ្រងធនធានធម្មជាតិសមុទ្រ និងបទប្បញ្ញត្តិពាក់ព័ន្ធនឹងអាជ្ញាធរបាតសមុទ្រអន្តរជាតិ ព្រមទាំងយន្តការដោះស្រាយវិវាទ



*ទិដ្ឋភាពក្នុងសម័យប្រជុំលើកទី៤ព្រឹទ្ធសភា នីតិកាលទី៥*

នីតិសមុទ្រ។

អនុសញ្ញានេះ នឹងផ្តល់អត្ថប្រយោជន៍ដល់ព្រះរាជាណាចក្រកម្ពុជារួមមាន៖

- ទទួលបាននូវក្របខ័ណ្ឌច្បាប់សមុទ្រមួយពេញលេញ សម្រាប់កិច្ចការសមុទ្រក្នុងនាមជាប្រទេសជាប់សមុទ្រ
- ទទួលបានការការពារតាមច្បាប់សមុទ្រអន្តរជាតិ ដែល ទាក់ទងនឹងការគ្រប់គ្រងសមុទ្ររបស់កម្ពុជា ដូចជា ការគ្រប់គ្រងនិងការអភិរក្សបរិស្ថានសមុទ្រ ការធ្វើអាជីវកម្មលើធនធានសមុទ្រ និងការស្រាវជ្រាវវិទ្យាសាស្ត្រសមុទ្រជាដើម
- ពង្រឹងតួនាទីកម្ពុជាលើឆាកអន្តរជាតិ តាមរយៈការពង្រីកកិច្ចសហប្រតិបត្តិការដោយស្មើមុខ ក្នុងការគ្រប់គ្រងសមុទ្រនិងការដោះស្រាយបញ្ហាសមុទ្រ ជាមួយបណ្តាប្រទេសនានា និងមានសិទ្ធិចូលរួមបោះឆ្នោតជ្រើសរើសសមាសភាពអាជ្ញាធរ បាតសមុទ្រអន្តរជាតិ ក៏ដូចជាចៅក្រមតុលាការអន្តរជាតិនីតិសមុទ្រផងដែរ
- ទទួលបាននូវកិច្ចសហប្រតិបត្តិការនិងជំនួយបច្ចេកទេស រួមទាំងជំនួយផ្នែកច្បាប់អន្តរជាតិ ពាក់ព័ន្ធនឹងការការពារនិងការអភិរក្សបរិស្ថានសមុទ្រ និងការផ្ទេរបច្ចេកវិទ្យាពីរដ្ឋភាគីនិងស្ថាប័នអន្តរជាតិនានា ពាក់ព័ន្ធនឹងអនុសញ្ញានេះ។

បច្ចុប្បន្ន អនុសញ្ញាអង្គការសហប្រជាជាតិស្តីពី នីតិសមុទ្រ មានប្រទេសចំនួន១៧១ និងក្នុងក្របខ័ណ្ឌអាស៊ាន មានប្រទេសចំនួន១០ បានចូលជាភាគីនៃអនុសញ្ញានេះរួចហើយ នៅតែកម្ពុជាដែលមិនទាន់ចូលជាភាគីនៅឡើយ។ កម្ពុជាបានចុះហត្ថលេខាលើអនុសញ្ញានេះ កាលពីថ្ងៃទី១ ខែកក្កដា ឆ្នាំ១៩៨៣ ហើយនៅក្នុងអំឡុងឆ្នាំ២០១៤ រាជរដ្ឋាភិបាលបានសម្រេចជាគោលការណ៍ឱ្យកម្ពុជារៀបចំនីតិវិធីដើម្បីផ្តល់សច្ចាប័ន។

សេចក្តីព្រាងច្បាប់នេះ រៀបចំឡើងមាន៣មាត្រា ត្រូវបានរដ្ឋសភា នៃព្រះរាជាណាចក្រកម្ពុជា អនុម័តយល់ព្រមលើកដំបូងចំនួន១១៤សំឡេង នៃចំនួនសមាជិករដ្ឋសភាទាំងមូល កាលពីថ្ងៃទី១៦ ខែមករា ឆ្នាំ២០២៦ នាសម័យប្រជុំរដ្ឋសភាលើកទី៥ នីតិកាលទី៧។

លោកជំទាវបណ្ឌិត **ចាន់ សុទ្ធាវី** ប្រធានគណៈកម្មការនីតិកម្ម និងយុត្តិធម៌ នៃព្រឹទ្ធសភា បានអញ្ជើញឡើងរាយការណ៍ជូនអង្គប្រជុំអំពី លទ្ធផលនៃការពិនិត្យ


*លោកជំទាវបណ្ឌិត ចាន់ សុទ្ធាវី ឡើងអានរបាយការណ៍*


*ឯកឧត្តម ប្រាក់ សុខុន ឡើងការពារសេចក្តីព្រាងច្បាប់*



*ទិដ្ឋភាពសមាជិក សមាជិកាព្រឹទ្ធសភា លើកដៃអនុម័តច្បាប់*

សិក្សាលើសេចក្តីព្រាងច្បាប់នេះ និងមានសមាជិកព្រឹទ្ធសភា ចំនួន២រូប ឡើងមានយោបល់ ព្រមទាំងមានការឆ្លើយបំភ្លឺពី ឯកឧត្តម **ប្រាក់ សុខុន** ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ។

អង្គប្រជុំព្រឹទ្ធសភាបានពិនិត្យ ហើយឱ្យយោបល់ឯកភាពទាំងស្រុងលើសេចក្តីព្រាងច្បាប់នេះដោយឥតកែប្រែចំនួន៥៨ សំឡេង នៃចំនួនសមាជិកព្រឹទ្ធសភាទាំងមូល។






*ទិដ្ឋភាពការបោះឆ្នោតជ្រើសរើសបំពេញសមាជិកគណៈកម្មការកិច្ចការបរទេស សហប្រតិបត្តិការអន្តរជាតិ និងព័ត៌មាន នៃព្រឹទ្ធសភា*

**របៀបវារៈទី២៖ បោះឆ្នោតជ្រើសរើសបំពេញសមាជិកគណៈកម្មការកិច្ចការបរទេស សហប្រតិបត្តិការអន្តរជាតិ និងព័ត៌មាន នៃព្រឹទ្ធសភានីតិកាលទី៥។**

ឯកឧត្តម **ឈីវ យីសៀង** សមាជិកព្រឹទ្ធសភា ត្រូវបានសម័យប្រជុំព្រឹទ្ធសភាជាវិសាមញ្ញ នីតិកាលទី៥ បោះឆ្នោតជ្រើសរើសជាសមាជិកគណៈកម្មការកិច្ចការបរទេស សហប្រតិបត្តិការអន្តរជាតិ និងព័ត៌មាន នៃព្រឹទ្ធសភា ដោយទទួលបានសំឡេងគាំទ្រចំនួន៥៨សំឡេង នៃចំនួនសមាជិកព្រឹទ្ធសភាទាំងមូល៕

អត្ថបទ និងរូបភាព៖ នាយកដ្ឋានព័ត៌មាន

# ឯកឧត្តមអនុប្រធានទី១ព្រឹទ្ធសភា អញ្ជើញសួរសុខទុក្ខវីរកងទ័ពការពារប្រាសាទតាមាន់ ប្រាសាទតាក្របី និងប្រាសាទខ្នា និងប្រជាពលរដ្ឋភៀសសឹកនៅស្រុកក្រឡាញ់




*ឯកឧត្តម អ៊ុច បូររិទ្ធ អញ្ជើញសួរសុខទុក្ខនិងនាំយកអំណោយរបស់សម្តេចតេជោ ជូនវីរកងទ័ពការពារប្រាសាទតាមាន់ ប្រាសាទតាក្របី និងប្រាសាទខ្នា ខេត្តឧត្តរមានជ័យ*

នៅថ្ងៃសុក្រ ទី២៦ ខែធ្នូ ឆ្នាំ២០២៥ ឯកឧត្តម **អ៊ុច បូររិទ្ធ** អនុប្រធានទី១ព្រឹទ្ធសភា តំណាងដ៏ខ្ពង់ខ្ពស់របស់សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** ប្រធានព្រឹទ្ធសភា នៃព្រះរាជាណាចក្រកម្ពុជា អមដំណើរដោយឯកឧត្តម លោកជំទាវ សមាជិកព្រឹទ្ធសភា ឯកឧត្តមទេសរដ្ឋមន្ត្រី **គី តិច** ប្រធានក្រុមមេធាវីរាជរដ្ឋាភិបាលនិងជាប្រធានក្រុមមេធាវីស្ម័គ្រចិត្តសម្តេចតេជោសែន និងសហការី ថ្នាក់ដឹកនាំនិងមន្ត្រីរាជការ នៃអគ្គលេខាធិការដ្ឋានព្រឹទ្ធសភា ទីប្រឹក្សានិងសមាជិកខុទ្ទកាល័យ បានអញ្ជើញចុះសួរសុខទុក្ខ និងនាំយកអំណោយជាគ្រឿងឧបភោគបរិភោគ សម្ភារៈប្រើប្រាស់ចាំបាច់ផ្សេងៗនិងថវិកាមួយចំនួនប្រគល់ជូនដល់វីរកងទ័ពការពារប្រាសាទតាមាន់ ប្រាសាទតាក្របី និងប្រាសាទខ្នា ខេត្តឧត្តរមានជ័យ និងជូនប្រជាពលរដ្ឋភៀសសឹកចំនួន១ពាន់គ្រួសារ នៅវត្តបទុមរតនញាណស្រណាល ឃុំស្រណាល ស្រុកក្រឡាញ់ ខេត្តសៀមរាប។ នៅក្នុងឱកាសជួបសំណេះសំណាលនោះក៏មានវត្តមាន អ្នកអង្គម្ចាស់ **ស៊ីសុវត្ថិ វ៉ាវី វឌ្ឍនា មុនីពង្ស** ផងដែរ។

មានប្រសាសន៍សំណេះសំណាលដាច់ដោយឡែកពីគ្នា **ឯកឧត្តមអនុប្រធានទី១** បាននាំនូវការផ្តាំផ្ញើការសួរសុខទុក្ខ និងពរសព្ទសាធុការពីសំណាក់ សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** ប្រធានព្រឹទ្ធសភា និង**សម្តេចកិត្តិ**




*ឯកឧត្តម អ៊ុច បូររិទ្ធ អញ្ជើញសួរសុខទុក្ខនិងនាំយកអំណោយជូនប្រជាពលរដ្ឋភៀសសឹក នៅស្រុកក្រឡាញ់ ខេត្តសៀមរាប*

**ព្រឹទ្ធបណ្ឌិត** សម្តេចមហាបវរធិបតី **ហ៊ុន ម៉ាណែត** នាយករដ្ឋមន្ត្រី និង**លោកជំទាវបណ្ឌិត** ជូនដល់វីរយុទ្ធជនដែលកំពុងឈរជើងយ៉ាងរឹងមាំនៅគ្រប់ទីកន្លែង និយាយជារួមនិងនិយាយដោយឡែក ជូនដល់វីរយុទ្ធជន ដែលកំពុងឈរជើងនៅក្នុងខេត្តឧត្តរមានជ័យ និងជូនដល់បងប្អូន អ៊ំ ពូ មីង ក្មួយៗ និងចៅៗជាជនភៀសសឹកទាំងអស់ ដែលកំពុងស្នាក់នៅក្នុងបរិវេណវត្តបទុមរតនញាណស្រណាល។

គតិបណ្ឌិតនិងឈ្លាសវៃរបស់**សម្តេចតេជោ** ប្រធានព្រឹទ្ធសភា និងសម្តេចមហាបវរធិបតី **ហ៊ុន ម៉ាណែត** នាយករដ្ឋមន្ត្រី ក្នុងការចាត់វិធានការនានា ដើម្បីការពារបូរណភាពដែនដី និងដោះស្រាយវិវាទព្រំប្រទល់ជាមួយប្រទេសថៃដោយសន្តិវិធី និងផ្អែកលើច្បាប់អន្តរជាតិ ធម្មនុញ្ញអង្គការសហប្រជាជាតិ និងធម្មនុញ្ញអាស៊ាន សំដៅធានាបាននូវសន្តិភាពនិងការអភិវឌ្ឍប្រកបដោយចីរភាពជូនជាតិ





*ឯកឧត្តម អ៊ុច បូរិទ្ធ អញ្ជើញគោរពវិញ្ញាណក្ខន្ធសពលោកអនុសេនាតូចលេខ២ កេត សុភ័ត្រ្តា និងនាំយកនូវអំណោយព្រមទាំងថវិកាមួយចំនួនជូនដល់គ្រួសារសព នៅគេហដ្ឋានសព ស្ថិតក្នុងក្រុងសៀមរាប ខេត្តសៀមរាប*

ជាមួយនឹងការសម្តែងនូវការគោរពដ៏ជ្រាលជ្រៅ ចំពោះវីរភាពអង្គអាចក្លាហានរបស់វីរយុទ្ធជន ដើម្បីបុព្វហេតុការពារជាតិមាតុភូមិកម្ពុជានិងការប្រសិទ្ធពរជ័យជូនវីរយុទ្ធជនដ៏អង់អាចក្លាហាននៅតាមព្រំដែន ឱ្យជួបតែសុខសុវត្ថិភាព និងទទួលបានជ័យជម្នះលើសមរភូមិ វាយបំបាក់ឱ្យបរាជ័យរាល់ការប៉ុនប៉ងរំលោភបំពាន និងមហិច្ឆតាប្លន់ទឹកដីរបស់ពួកចោរឈ្លានពាន **ឯកឧត្តមអនុប្រធានទី១** បានសម្តែងនូវមោទនភាពជាតិខ្ពស់ចំពោះទឹកចិត្តស្នេហាជាតិ សាមគ្គីឯកភាពជាតិជាធ្លុងមួយ នៅគ្រប់ស្រទាប់វណ្ណៈក្នុងសង្គមជាតិ ជួយគាំទ្រទាំងកម្លាំងកាយ ចិត្ត និងសម្ភារៈដល់សមរភូមិមុខ ក៏ដូចជាបងប្អូនប្រជាពលរដ្ឋភៀសសឹក នៅក្នុងកាលៈទេសៈដ៏លំបាកនេះ។

ឯកឧត្តមក៏បានអំពាវនាវឱ្យបងប្អូនប្រជាពលរដ្ឋទាំងអស់ សូមមានជំនឿជឿជាក់លើការដឹកនាំប្រកបដោយ

មាតុភូមិ។

នៅថ្ងៃនោះដែរ **ឯកឧត្តមអនុប្រធានទី១** និងគណៈប្រតិភូ ក៏បានអញ្ជើញគោរពវិញ្ញាណក្ខន្ធសពលោកអនុសេនាតូចលេខ២ **កេត សុភ័ត្រ្តា** មេបញ្ជាការរងទី៣ ឈរជើងនៅប្រាសាទតាមាន់ធំ ខេត្តឧត្តរមានជ័យ ដែលបានពលីជីវិតក្នុងសមរភូមិប្រយុទ្ធតតាំងនឹងការឈ្លានពានរបស់ទ័ពថៃក្នុងបុព្វហេតុការពារអធិបតេយ្យជាតិនិងបូរណភាពទឹកដីកម្ពុជា( ជីវិតជូនជាតិ ជាតុជូនម្តាយ ) និងនាំយកនូវអំណោយព្រមទាំងថវិកាមួយចំនួនជូនដល់គ្រួសារសព នៅគេហដ្ឋានស្ថិតក្នុងភូមិសាលាកន្សែង សង្កាត់ស្វាយដង្គំ ក្រុងសៀមរាប ខេត្តសៀមរាប៕

អត្ថបទ៖ ខុទ្ទកាល័យឯកឧត្តមអនុប្រធានទី១ព្រឹទ្ធសភា

រូបភាព៖ នាយកដ្ឋានព័ត៌មាន

# ឯកឧត្តម អ៊ុច បូររិទ្ធ៖ ការលំបាកនិងការឈឺចាប់របស់ពលរដ្ឋភៀសសឹកត្រូវបានប្រែក្លាយជាកម្លាំងចលករដ៏ខ្លាំងក្លា ជំរុញនិងពង្រឹងឱ្យកាន់តែរឹងមាំថែមទៀតនូវចំណងសាមគ្គីភាព





*ឯកឧត្តម អ៊ុច បូររិទ្ធ សំណេះសំណាល និងសួរសុខទុក្ខប្រជាពលរដ្ឋភៀសសឹកនិងគ្រួសារវីរយុទ្ធជន នៅខេត្តកំពង់ចាម*

ឯកឧត្តម **អ៊ុច បូររិទ្ធ** អនុប្រធានទី១ព្រឹទ្ធសភា និងជាប្រធានក្រុមសមាជិកព្រឹទ្ធសភាភូមិភាគទី២ បានមានប្រសាសន៍ថា ការលំបាកនិងការឈឺចាប់របស់ពលរដ្ឋភៀសសឹក ត្រូវបានប្រែក្លាយជាកម្លាំងចលករដ៏ខ្លាំងក្លា ជំរុញនិងពង្រឹងឱ្យកាន់តែរឹងមាំថែមទៀត នូវចំណងសាមគ្គីភាពឯកភាពជាតិ ជាធ្លុងមួយ ទាំងក្នុងនិងក្រៅប្រទេស ក្រោមការដឹកនាំប្រកបដោយគតិបណ្ឌិត និងឈ្លាសវៃរបស់សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** ប្រធានព្រឹទ្ធសភានៃព្រះរាជាណាចក្រកម្ពុជា និងសម្តេចមហាបវរធិបតី **ហ៊ុន ម៉ាណែត** ប្រមុខរាជរដ្ឋាភិបាល ក្នុងការចាត់វិធានការនានា ដើម្បីការពារបូរណភាពដែនដី និងដោះស្រាយវិវាទព្រំដែនជាមួយប្រទេសថៃដោយសន្តិវិធី និងផ្អែកលើច្បាប់អន្តរជាតិ ធម្មនុញ្ញអង្គការសហប្រជាជាតិ និងធម្មនុញ្ញអាស៊ានសំដៅធានាបាននូវសន្តិភាពនិងការអភិវឌ្ឍប្រកបដោយចីរភាពជូនជាតិមាតុភូមិ។

**ឯកឧត្តមអនុប្រធានទី១** បានគូសបញ្ជាក់បន្ថែមថា សុឆន្ទៈរបស់កម្ពុជាក្នុងការដោះស្រាយវិវាទដោយសន្តិវិធី មិនមានន័យថាជាការដោះដូរសិទ្ធិអធិបតេយ្យក្នុងការការពារបូរណភាពដែនដីរបស់ខ្លួននោះទេ។ ថ្នាក់ដឹកនាំ ក៏ដូចជាបងប្អូនប្រជាពលរដ្ឋនៅទូទាំងប្រទេស មានការប្តេជ្ញាខ្ពស់ និងត្រៀមលក្ខណៈជាស្រេចក្នុងការការពារអធិបតេយ្យ បូរណភាពទឹកដីមាតុភូមិ មិនឱ្យបាត់បង់សូម្បីតែមួយមិល្លីម៉ែត្រ។

**ឯកឧត្តមអនុប្រធានទី១** បានលើកឡើងយ៉ាងដូច្នេះ



*ទិដ្ឋភាពក្នុងពិធីសំណេះសំណាល*

ក្នុងឱកាសឯកឧត្តមនិងក្រុមសមាជិកព្រឹទ្ធសភាប្រចាំភូមិភាគទី២ អញ្ជើញចុះសួរសុខទុក្ខ និងនាំយកអំណោយដ៏ថ្លៃថ្លារបស់សម្តេចតេជោ **ហ៊ុន សែន** ប្រធានព្រឹទ្ធសភា និងសម្តេចកិត្តិព្រឹទ្ធបណ្ឌិត **ប៊ុន រ៉ានី ហ៊ុនសែន** ចែកជូនប្រជាពលរដ្ឋភៀសសឹកនិងគ្រួសារវីរយុទ្ធជនចំនួន៣៥៣គ្រួសារ ព្រមទាំងសិស្សានុសិស្សភៀសសឹក២៩៤នាក់ ក្នុងបរិវេណសួនច្បារទល់មុខសាលាស្រុកស្រីសន្ធរ ខេត្តកំពង់ចាម នាថ្ងៃទី៩ ខែមករា ឆ្នាំ២០២៦។

ក្នុងកិច្ចសំណេះសំណាលនាឱកាសនោះ **ឯកឧត្តមអនុប្រធានទី១** បាននាំនូវការផ្តាំផ្ញើសួរសុខទុក្ខនិងក្តីនឹករលឹករបស់សម្តេចតេជោ **ហ៊ុន សែន** និង**សម្តេចកិត្តិព្រឹទ្ធបណ្ឌិត** ព្រមទាំងសម្តេចធិបតី **ហ៊ុន ម៉ាណែត** និង**លោកជំទាវបណ្ឌិត** ជូនដល់បងប្អូនប្រជាពលរដ្ឋនិងក្មួយៗសិស្សានុសិស្សភៀសសឹក ព្រមទាំងគ្រួសារវីរយុទ្ធជនទាំងអស់ដែលបានភៀសខ្លួនចេញពីលំនៅឋាន មករួមរស់នៅជាមួយបងប្អូនប្រជាពលរដ្ឋនៅក្នុងស្រុកស្រីសន្ធរ ដើម្បីជៀសផុតពីការវាយប្រហារឈ្លានពានព្រៃផ្សៃ ថោកទាបរបស់ពួកឃោជាថៃ មកលើបូរណភាពទឹកដីកម្ពុជា។

**ឯកឧត្តមអនុប្រធានទី១** បានបន្ថែមថា សម្តេចតេជោ **ហ៊ុន សែន** ជាអគ្គមគ្គុទ្ទេសក៍ជាតិដ៏ឆ្នើម និងជាស្ថាបនិកសន្តិភាពប្រទេសជាតិ ព្រមទាំង**សម្តេចធិបតី** ប្រមុខរាជរដ្ឋាភិបាល ដែលពោរពេញដោយថាមពលនិងបញ្ញាញាណឈ្លាសវៃ តែងតែយកចិត្តទុកដាក់ខ្ពស់ចំពោះសុខទុក្ខរបស់បងប្អូនប្រជាពលរដ្ឋទាំងអស់ដែលបានភៀសខ្លួនចេញពីលំនៅឋាន និងវីរយុទ្ធជនដែលបាននិងកំពុងឈរជើងយ៉ាងរឹងមាំ តស៊ូ ក្រាញននៀល ការពារទឹកដីមាតុភូមិកម្ពុជា និងបានផ្តល់អនុសាសន៍ដ៏ខ្ពង់ខ្ពស់ថ្លៃថ្លាដល់គ្រប់សមាជិក សមាជិកាព្រឹទ្ធសភា និងអាជ្ញាធរគ្រប់ជាន់ថ្នាក់ទាំងអស់ ឱ្យយកចិត្តទុកដាក់ជួយសម្រួល ដោះស្រាយការលំបាក ខ្វះខាត និងថែទាំសុខភាព ដល់បងប្អូនទាំងអស់នៅក្នុងកាលៈទេសៈដ៏លំបាកនេះ។

**ឯកឧត្តមអនុប្រធានទី១** បានសម្តែងនូវការដឹងគុណ និងគារវកិច្ចដ៏ជ្រាលជ្រៅ ចំពោះវីរភាពដ៏អង់អាចក្លាហាន មោះមុតដ៏គួរឱ្យកោតស្ញប់ស្ញែងរបស់វីរយុទ្ធជន ដើម្បីបុព្វហេតុការពារជាតិមាតុភូមិកម្ពុជា ព្រមទាំងបានបួងសួងដល់គុណបុណ្យព្រះរតនត្រ័យ គុណកែវទាំងបី សូមតាមអភិបាលបោះព្រំ ឃុំគ្រង ថែរក្សា និងប្រសិទ្ធពរជ័យជូនវីរយុទ្ធជនដ៏អង់អាចក្លាហាននៅតាមព្រំដែន ក៏ដូចជាបងប្អូនប្រជាពលរដ្ឋភៀសសឹកទាំងអស់ សូមទទួលបានសុខភាពល្អ និងអាយុវណ្ណៈ សុខៈ ពលៈ កុំបីឃ្លៀងឃ្លាតឡើយ។

បន្ទាប់ពីសំណេះសំណាលជាមួយបងប្អូនភៀសសឹករួចមក **ឯកឧត្តមអនុប្រធានទី១** គណៈប្រតិភូ និងថ្នាក់ដឹកនាំខេត្ត ក៏បានអញ្ជើញចុះពិនិត្យស្ថានភាពនៃការបាក់ច្រាំងទន្លេ និងផ្លូវថ្នល់ ស្ថិតនៅភូមិជ័យ ឃុំមានជ័យ ស្រុកស្រីសន្ធរ ខេត្តកំពង់ចាម ដើម្បីត្រៀមរៀបចំជួសជុលនៅពេលខាងមុខ៕

*អត្ថបទ៖ ខុទ្ទកាល័យឯកឧត្តមអនុប្រធានទី១ព្រឹទ្ធសភា*

*រូបភាព, សម្រួលខ្លឹមសារ៖ នាយកដ្ឋានព័ត៌មាន*





*ឯកឧត្តម អ៊ុច បូរិទ្ធ ចុះពិនិត្យស្ថានភាពនៃការបាក់ច្រាំងទន្លេ និងផ្លូវថ្នល់*

# ឯកឧត្តមបណ្ឌិត ធន់ វឌ្ឍនា៖ អាជ្ញាធរសង្កាត់មានតួនាទីសំខាន់ខ្លាំង ក្នុងការតាមដាននិងលុបបំបាត់ការឆបោកអនឡាញ

ក្រុមសមាជិកព្រឹទ្ធសភាប្រចាំភូមិភាគទី១ (រាជធានីភ្នំពេញ) ដឹកនាំដោយ ឯកឧត្តមបណ្ឌិត **ធន់ វឌ្ឍនា** អនុប្រធានទី២ព្រឹទ្ធសភា និងជាប្រធានក្រុមសមាជិកព្រឹទ្ធសភាប្រចាំភូមិភាគទី១ បានអញ្ជើញជួបសំណេះសំណាលជាមួយសមាជិកក្រុមប្រឹក្សាសង្កាត់ អាជ្ញាធរមូលដ្ឋាន និងអ្នកពាក់ព័ន្ធ មកពីសង្កាត់ក្នុងខណ្ឌបឹងកេងកងចំនួន៩៥នាក់ និងខណ្ឌដូនពេញ ចំនួន១២៥នាក់ នារសៀលថ្ងៃទី១៦ និងថ្ងៃទី២២ ខែមករា ឆ្នាំ២០២៦ នៅវិមានព្រឹទ្ធសភា។



*ឯកឧត្តមបណ្ឌិត ធន់ វឌ្ឍនា សំណេះសំណាលជាមួយសមាជិកក្រុមប្រឹក្សាសង្កាត់ អាជ្ញាធរពាក់ព័ន្ធ*

**ឯកឧត្តមបណ្ឌិត** បានកោតសរសើរថ្នាក់ដឹកនាំសង្កាត់និងខណ្ឌទាំងពីរ ដែលខិតខំផ្តល់សេវាសាធារណៈ សន្តិសុខ សុវត្ថិភាព និងទទួលបានការទុកចិត្តពីប្រជាពលរដ្ឋ។ ការខិតខំរបស់អាជ្ញាធរសង្កាត់ និងខណ្ឌ បានធ្វើឱ្យមូលដ្ឋានទាំងពីរក្លាយជាទីកន្លែងសម្បូរទៅដោយតំបន់ទីប្រជុំជន ហាងអាហារចម្រុះជាតិសាសន៍ តំបន់ទេសចរណ៍ប្រវត្តិសាស្ត្រ និងតំបន់ពាណិជ្ជកម្មជាច្រើន។

ក្នុងឱកាសនោះ **ឯកឧត្តមបណ្ឌិត** បានសង្កត់ធ្ងន់ថា អាជ្ញាធរសង្កាត់ មានតួនាទីសំខាន់ខ្លាំងក្នុងការតាមដាន និងលុបបំបាត់ការឆបោកអនឡាញ (Online Scams)។ ការឆបោកអនឡាញនេះ កើតឡើងនៅច្រើនប្រទេស ទាំងនៅអាស៊ី អាម៉េរិក អាហ្វ្រិក និងមានយូរណាស់មកហើយ។ ដូច្នេះ យើងត្រូវរួមគ្នា លុបបំបាត់អំពើឆបោកនេះ ដើម្បីផ្តល់ទំនុកចិត្តដល់ទេសចរ មកកំសាន្តនៅប្រទេសយើងច្រើនថែមទៀត។

**ឯកឧត្តមបណ្ឌិត** បានបន្ថែមថាក្នុងស្ថានភាពប្រទេសជាតិកំពុងប្រឈមនឹងបញ្ហាទាំងកត្តាខាងក្រៅ និងខាងក្នុង យើងត្រូវរួបរួមសាមគ្គីភាព និងខិតខំបំពេញតួនាទីរបស់ខ្លួនឱ្យបានល្អប្រសើរដើម្បីធានាប្រក្រតីភាពសង្គម និងការអភិវឌ្ឍប្រទេសជាតិ។ ជាពិសេសត្រូវខិតខំសម្រេចឱ្យបានតាមការសន្យាទាំង៧ចំណុច ដែលបានឃោសនាបោះឆ្នោតកន្លងមក និងមាននៅក្នុងគោលនយោបាយអភិវឌ្ឍឃុំសង្កាត់ ឆ្នាំ២០២២-២០២៧។

**ឯកឧត្តមបណ្ឌិត** បានផ្តាំផ្ញើទៅដល់សមាជិកក្រុមប្រឹក្សាសង្កាត់ និងអ្នកចូលរួម នូវ៣ចំណុចសំខាន់ៗរួមមាន៖

**១-សុខសុវត្ថិភាព៖ បន្តអនុវត្តគោលនយោបាយភូមិឃុំមានសុវត្ថិភាព ជាពិសេសលុបបំបាត់ការឆបោកអនឡាញ។**

**២-សុខភាព៖ កម្ពុជាបានឈានហួសពីដំណាក់កាលនៃការហូបដើម្បីឆ្អែត ទៅជាការហូបដើម្បីភាពមាំមួននៃរាងកាយ និងខួរក្បាល។**

**៣-សមត្ថភាព៖ ត្រូវបង្កើនសមត្ថភាពភាសាបរទេសដល់កុមារកម្ពុជា ដូចជាភាសាអង់គ្លេសជាដើម ដែលជាស្ពានចម្លងទៅឱកាសដ៏ទូលំទូលាយក្នុងពិភពលោក។**

នៅទីបញ្ចប់ **ឯកឧត្តមបណ្ឌិត** បានផ្តាំផ្ញើដល់សមាជិកក្រុមប្រឹក្សាសង្កាត់និងអ្នកចូលរួម តាមដាននិងអនុវត្តនូវការសន្យា ដែលសមាជិកក្រុមប្រឹក្សាសង្កាត់បានសន្យាក្នុងអំឡុងពេលបោះឆ្នោតកន្លងមក។

អត្ថបទ និងរូបភាព៖ នាយកដ្ឋានព័ត៌មាន



*ទិដ្ឋភាពក្នុងពិធីសំណេះសំណាល*

# សកម្មភាពថ្នាក់ដឹកនាំព្រឹទ្ធសភាចូលរួមពិធីផ្សេងៗ

❈នារសៀលថ្ងៃទី៣០ ខែធ្នូ ឆ្នាំ២០២៥ នៅស្ថានីយវិទ្យុនិងទូរទស្សន៍បាយ័ន សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** ប្រធានព្រឹទ្ធសភា នៃព្រះរាជាណាចក្រកម្ពុជា បានអញ្ជើញមកផ្តល់កម្លាំងចិត្ត និងពិនិត្យមើលសកម្មភាពវេចខ្ចប់អំណោយរបស់**សម្តេចតេជោ**និង**សម្តេចកិត្តិព្រឹទ្ធបណ្ឌិត** សម្តេចមហាបវរធិបតី **ហ៊ុន ម៉ាណែត** និង**លោកជំទាវបណ្ឌិត** ដើម្បីផ្តល់ជូនប្រជាពលរដ្ឋភៀសសឹកនៅតាមបណ្តាខេត្តជាប់ព្រំដែនកម្ពុជា-ថៃ។





❈នាព្រឹកថ្ងៃអង្គារ ទី៦ ខែមករា ឆ្នាំ២០២៦ សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** ប្រធានព្រឹទ្ធសភា នៃព្រះរាជាណាចក្រកម្ពុជា បានអញ្ជើញចុះពិនិត្យមើលការសាងសង់វិមានសាមគ្គីភាព នៃព្រឹទ្ធសភា។

❈នាព្រឹកថ្ងៃសុក្រ ទី២៦ ខែធ្នូ ឆ្នាំ២០២៥ ឯកឧត្តម **អ៊ុច បូររិទ្ធ** អនុប្រធានទី១ព្រឹទ្ធសភា បានដឹកនាំគណៈប្រតិភូព្រឹទ្ធសភា អញ្ជើញគោរពវិញ្ញាណក្ខន្ធសពលោកជំទាវនាយឧត្តមសេនីយ៍ **ម៉ី មនដារី** អគ្គមេបញ្ជាការរងនៃកងយោធពលខេមរភូមិន្ទ នៅសង្កាត់បឹងកក់ទី២ ខណ្ឌទួលគោក រាជធានីភ្នំពេញ។



# សកម្មភាពថ្នាក់ដឹកនាំព្រឹទ្ធសភាចូលរួមពិធីផ្សេងៗ



❈នារសៀលថ្ងៃពុធ ទី៧ ខែមករា ឆ្នាំ២០២៦ ក្រុមសមាជិកព្រឹទ្ធសភាប្រចាំភូមិភាគទី២ ដឹកនាំដោយ ឯកឧត្តម **អ៊ុច បូររិទ្ធ** អនុប្រធានទី១ព្រឹទ្ធសភា និងជាប្រធានក្រុម បានអញ្ជើញគោរពវិញ្ញាណក្ខន្ធសពឧបាសិកា **ស៊ន់ គា** ម្តាយបង្កើតរបស់ឯកឧត្តម **ទុយ រី** នាយកខុទ្ទកាល័យឯកឧត្តមអនុប្រធានទី១ព្រឹទ្ធសភា នៅសង្កាត់សួង ក្រុងសួង ខេត្តត្បូងឃ្មុំ។

❈នាព្រឹកថ្ងៃសុក្រ ទី៩ ខែមករា ឆ្នាំ២០២៦ ក្រុមសមាជិកព្រឹទ្ធសភាប្រចាំភូមិភាគទី២ ដឹកនាំដោយ ឯកឧត្តម **អ៊ុច បូររិទ្ធ** អនុប្រធានទី១ព្រឹទ្ធសភា និងជាប្រធានក្រុម បានអញ្ជើញគោរពវិញ្ញាណក្ខន្ធសពឧបាសិកា **ធិន ធឹម** ម្តាយបង្កើតរបស់ឯកឧត្តម **ឡោ ចាន់លី** សមាជិកគណៈកម្មាធិការអចិន្ត្រៃយ៍គណបក្សខេត្តកំពង់ចាម នៅឃុំដាលា ស្រុកបាធាយ ខេត្តកំពង់ចាម។





❈នាព្រឹកថ្ងៃចន្ទ ទី១២ ខែមករា ឆ្នាំ២០២៦ ឯកឧត្តម **អ៊ុច បូររិទ្ធ** អនុប្រធានទី១ព្រឹទ្ធសភា បានអញ្ជើញពិនិត្យការរៀបចំទីកន្លែងបំពេញការងារ នៅវិមានសាមគ្គីភាព នៃព្រឹទ្ធសភា។

# សកម្មភាពថ្នាក់ដឹកនាំព្រឹទ្ធសភាចូលរួមពិធីផ្សេងៗ

❈នាព្រឹកថ្ងៃទី២៨ ខែធ្នូ ឆ្នាំ២០២៥ ឯកឧត្តមបណ្ឌិត **ឆន់ ខន្ធូនា** អនុប្រធានទី២ព្រឹទ្ធសភា បានអញ្ជើញជាអធិបតីក្នុងពិធីបើកសិក្ខាសាលាស្តីពី «ការជំរុញការវិនិយោគលើវិស័យកាហ្វេ និងការចែករំលែកបច្ចេកទេសដាំ និងការកែច្នៃកាហ្វេ» នៅសាកលវិទ្យាល័យភូមិន្ទកសិកម្ម។



❈នាថ្ងៃចន្ទ ទី២៩ ខែធ្នូ ឆ្នាំ២០២៥ ឯកឧត្តមបណ្ឌិត **ឆន់ ខន្ធូនា** អនុប្រធានទី២ព្រឹទ្ធសភា បានអញ្ជើញដឹកនាំគណៈប្រតិភូព្រឹទ្ធសភា ថ្នាក់ដឹកនាំខេត្ត និងសប្បុរសជន ចុះសួរសុខទុក្ខវីរកងទ័ព ព្រមទាំងយកអំណោយជាគ្រឿងឧបភោគបរិភោគ ថ្នាំពេទ្យ សម្លៀកបំពាក់ និងសម្ភារៈប្រើប្រាស់មួយចំនួន ជូនវីរកងទ័ពក្នុងកងពលអន្តរាគមន៍លេខ៧ លេខ៩ និងសឹករងខេត្តព្រះវិហារ។



❈នាថ្ងៃអង្គារ ទី៣០ ខែធ្នូ ឆ្នាំ២០២៥ ឯកឧត្តមបណ្ឌិត **ឆន់ ខន្ធូនា** អនុប្រធានទី២ព្រឹទ្ធសភា បានអញ្ជើញដឹកនាំកិច្ចប្រជុំបូកសរុបលទ្ធផលការងារប្រចាំខែធ្នូ និងលើកទិសដៅការងារឆ្នាំ២០២៦ របស់ខុទ្ទកាល័យឯកឧត្តមអនុប្រធានទី២ព្រឹទ្ធសភា នៅសាលប្រជុំពិសេស៣ វិមានព្រឹទ្ធសភា។



# សកម្មភាពថ្នាក់ដឹកនាំព្រឹទ្ធសភាចូលរួមពិធីផ្សេងៗ



❈នារសៀលថ្ងៃចន្ទ ទី៥ ខែមករា ឆ្នាំ២០២៦ ឯកឧត្តមបណ្ឌិត **ឆន់ ខ្ឡ្យនា** អនុប្រធានទី២ព្រឹទ្ធសភា បានអញ្ជើញដឹកនាំកិច្ចប្រជុំប្រចាំខែធ្នូ ជាមួយគណៈកម្មការនានា និងក្រុមយន្តការរបស់ព្រឹទ្ធសភា នៅសាលប្រជុំពិសេស៣ វិមានព្រឹទ្ធសភា។

---

❈នាល្ងាចថ្ងៃទី៨ ខែមករា ឆ្នាំ២០២៦ ឯកឧត្តមបណ្ឌិត **ឆន់ ខ្ឡ្យនា** អនុប្រធានទី២ព្រឹទ្ធសភា បានអញ្ជើញជួបប្រជុំពិភាក្សាការងាររវាងគណៈកម្មការទី២ព្រឹទ្ធសភា និងសាកលវិទ្យាល័យជាតិគ្រប់គ្រង ស្តីពីការជំរុញឱ្យមានការគាំទ្រនិងកិច្ចសហប្រតិបត្តិការស្រាវជ្រាវលើការស្តារសេដ្ឋកិច្ចព្រំដែន នៅសាលប្រជុំពិសេស៣ វិមានព្រឹទ្ធសភា។



---



❈នាព្រឹកថ្ងៃពុធ ទី១៤ ខែមករា ឆ្នាំ២០២៦ ឯកឧត្តមបណ្ឌិត **ឆន់ ខ្ឡ្យនា** អនុប្រធានទី២ព្រឹទ្ធសភា បានអញ្ជើញពិនិត្យការរៀបចំទីកន្លែងបំពេញការងារ នៅវិមានសាមគ្គីភាព នៃព្រឹទ្ធសភា។

---

❈នារសៀលថ្ងៃព្រហស្បតិ៍ ទី២២ ខែមករា ឆ្នាំ២០២៦ ឯកឧត្តមបណ្ឌិត **ឆន់ ខ្ឡ្យនា** អនុប្រធានទី២ព្រឹទ្ធសភា និងលោកជំទាវ បានអញ្ជើញចូលរួមពិធីបុណ្យខួបគម្រប់ ៧ថ្ងៃ អគ្គមហាឧបាសិកាពុទ្ធសាសនូបត្ថម្ភក៏ **ឌី សានឿន** ម្តាយបង្កើតរបស់ឯកឧត្តមបណ្ឌិតសភាចារ្យ **ជូ វិជិត្ត** រដ្ឋលេខាធិការប្រចាំការ នៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ នៅវត្តបទុមវតីរាជវរារាម រាជធានីភ្នំពេញ៕



# គណៈប្រតិភូគណៈកម្មការទី៨ និងក្រុមសមាជិកាព្រឹទ្ធសភា អញ្ជើញចុះសួរសុខទុក្ខ វីរកងទ័ព ដែលកំពុងសម្រាកព្យាបាលជំងឺ នៅមណ្ឌលសុខភាពគូលែន និងមន្ទីរពេទ្យបង្អែកខេត្ត ១៦មករា





*គណៈប្រតិភូគណៈកម្មការទី៨និងក្រុមសមាជិកាព្រឹទ្ធសភា អញ្ជើញសួរសុខទុក្ខវីរកងទ័ព ដែលកំពុងសម្រាកព្យាបាលជំងឺ នៅមណ្ឌលសុខភាពគូលែន*

នាថ្ងៃព្រហស្បតិ៍ ទី៨ ខែមករា ឆ្នាំ២០២៦ គណៈប្រតិភូគណៈកម្មការសុខាភិបាល សង្គមកិច្ច អតីតយុទ្ធជន យុវនីតិសម្បទា ការងារបណ្តុះ-បណ្តាលវិជ្ជាជីវៈ និងកិច្ចការនារី នៃព្រឹទ្ធសភា និងក្រុមសមាជិកាព្រឹទ្ធសភា ដឹកនាំដោយលោកជំទាវ **មាន សំអាន** ប្រធានគណៈកម្មការ និងជាប្រធានក្រុម បានអញ្ជើញចុះសួរសុខទុក្ខ ព្រមទាំងនាំយកគ្រឿងឧបភោគ បរិភោគ សម្ភារៈប្រើប្រាស់ និងថវិកាចែកជូនវីរកងទ័ព ដែលកំពុងសម្រាកព្យាបាលនៅមណ្ឌលសុខភាពគូលែន ស្រុកគូលែន និងមន្ទីរពេទ្យបង្អែកខេត្ត១៦ មករា ក្រុងព្រះវិហារ ខេត្តព្រះវិហារ។

**លោកជំទាវប្រធានគណៈប្រតិភូ** បាននាំនូវប្រសាសន៍ផ្តាំផ្ញើសួរសុខទុក្ខប្រកបដោយក្តីបារម្ភនិងការយកចិត្តទុកដាក់ខ្ពស់បំផុតរបស់ សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** ប្រធានព្រឹទ្ធសភា សម្តេចកិត្តិព្រឹទ្ធបណ្ឌិត **ប៊ុន រ៉ានី ហ៊ុនសែន** និងសម្តេចកិត្តិសង្គហបណ្ឌិត **ម៉ែន សំអន** ជូនចំពោះវីរកងទ័ពទាំងអស់ដែលកំពុងសម្រាកទទួលការព្យាបាល ព្រមទាំងថ្លែងអំណរគុណចំពោះ






*គណៈប្រតិភូគណៈកម្មការទី៨និងក្រុមសមាជិកាព្រឹទ្ធសភា អញ្ជើញចែកសម្ភារៈប្រើប្រាស់ និងថវិកាជូនដល់វីរកងទ័ព ដែលកំពុងសម្រាកព្យាបាលជំងឺ ព្រមទាំងថតរូបអនុស្សាវរីយ៍ នៅមណ្ឌលសុខភាពគូលែន*





*គណៈប្រតិភូគណៈកម្មការទី៨និងក្រុមសមាជិកាព្រឹទ្ធសភា អញ្ជើញសួរសុខទុក្ខវីរកងទ័ព ដែលកំពុងសម្រាកព្យាបាលជំងឺ នៅមន្ទីរពេទ្យបង្អែកខេត្ត១៦ មករា ខេត្តព្រះវិហារ*

ក្រុមគ្រូពេទ្យ និងសម្តែងនូវការកោតសរសើរចំពោះវីរភាព ដ៏អង់អាចក្លាហានរបស់វីរកងទ័ពកម្ពុជា ឈរជើងការពារ ជាតិមាតុភូមិ និងការលះបង់គ្រប់បែបយ៉ាង ដើម្បីការពារ បូរណភាពទឹកដីពីការឈ្លានពានរបស់ថៃ ព្រមទាំងជូនពរ ឱ្យបងប្អូនវីរកងទ័ពទាំងអស់ឆាប់បានជាសះស្បើយពីរបួស និងជំងឺ ដើម្បីបានវិលត្រឡប់ទៅជួបជុំវីរយុទ្ធមិត្តនៅអង្គភាព និងក្រុមគ្រួសារនៅលំនៅឋានវិញ។

ក្នុងឱកាសទិវាអបអរសាទរខួបទី៤៧ នៃទិវាជ័យជម្នះ ៧មករា ដែលជាថ្ងៃកំណើតទី២ របស់យើងទាំងអស់គ្នា **លោកជំទាវប្រធាន** បានរំលឹកការចងចាំនូវវីរភាពដ៏អង់អាច ក្លាហាន តស៊ូ និងលះបង់គ្រប់បែបយ៉ាងរបស់យុទ្ធជនដែល បានពលីជីវិត ដើម្បីរំដោះប្រទេសពីរណ្តៅមរណៈនៃរបបដ៏ ខ្មៅងងឹត ៣ឆ្នាំ ៨ខែ ២០ថ្ងៃ ជាវាលពិឃាតប្រែក្លាយប្រទេស កម្ពុជាពោរពេញដោយសន្តិភាព និងការអភិវឌ្ឍ។

រួមជាមួយសម្ភារៈ ម្ហូបអាហារ ថវិកា ដែលបានចែក ជូនបងប្អូនវីរកងទ័ពគ្រប់ៗរូបកំពុងសម្រាកព្យាបាលនិង ក្រុមគ្រូពេទ្យ **លោកជំទាវប្រធាន**ក៏បានឧបត្ថម្ភថវិកាមួយ ចំនួនបន្ថែមជូនមណ្ឌលសុខភាពគូលែន និងមន្ទីរពេទ្យបង្អែក ខេត្ត១៦មករា ខេត្តព្រះវិហារ សម្រាប់ប្រើប្រាស់ផងដែរ។

អត្ថបទ និងរូបភាព៖ នាយកដ្ឋានព័ត៌មាន





*គណៈប្រតិភូគណៈកម្មការទី៨និងក្រុមសមាជិកាព្រឹទ្ធសភា អញ្ជើញចែកសម្ភារៈប្រើប្រាស់ និងថវិកាដល់វីរកងទ័ព ដែលកំពុងសម្រាកព្យាបាលជំងឺ ព្រមទាំងថតរូបអនុស្សាវរីយ៍ នៅមន្ទីរពេទ្យបង្អែកខេត្ត១៦ មករា ខេត្តព្រះវិហារ*

# ឯកឧត្តម ម៉ម ប៊ុននាង អញ្ជើញនាំយកអំណោយដ៏ថ្លៃថ្លា របស់សម្តេចតេជោ ហ៊ុន សែន និងមូលនិធិចែករំលែកសង្គ្រោះជីវិតសកល នៃសាធារណរដ្ឋកូរ៉េ ប្រគល់ជូនរដ្ឋបាលខេត្តកំពង់ស្ពឺ

នៅថ្ងៃសៅរ៍ ទី៣ ខែមករា ឆ្នាំ២០២៦ គណៈកម្មការអង្កេត បោសសម្អាត និងប្រឆាំងអំពើពុករលួយនៃព្រឹទ្ធសភា (គណៈកម្មការទី១០) ដឹកនាំដោយ ឯកឧត្តម **ម៉ម ប៊ុននាង** ប្រធានគណៈកម្មការ តំណាងដ៏ខ្ពង់ខ្ពស់របស់ឯកឧត្តម **អ៊ុច បូររិទ្ធ** អនុប្រធានទី១ ព្រឹទ្ធសភា បានអញ្ជើញដឹកនាំគណៈប្រតិភូព្រឹទ្ធសភា នាំយកអំណោយដ៏ថ្លៃថ្លារបស់សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** ប្រធានព្រឹទ្ធសភា និង**សម្តេចកិត្តិព្រឹទ្ធបណ្ឌិត** រួមជាមួយជំនួយមនុស្សធម៌របស់មូលនិធិចែករំលែកសង្គ្រោះជីវិតសកលនៃសាធារណរដ្ឋកូរ៉េ ក្នុងទំហំទឹកប្រាក់ប្រមាណជាង ពីរលានបីសែនដុល្លារអាម៉េរិក ប្រគល់ជូនរដ្ឋបាលខេត្តកំពង់ស្ពឺ ដឹកនាំដោយ ឯកឧត្តមបណ្ឌិត **ជាម ច័ន្ទសោភ័ណ** អភិបាលខេត្តកំពង់ស្ពឺ ដោយមានការអញ្ជើញចូលរួមពីក្រុមសមាជិកព្រឹទ្ធសភាប្រចាំភូមិភាគទី៧ នៅសាលាខេត្តកំពង់ស្ពឺ។

ក្នុងឱកាសនោះ ឯកឧត្តម **ម៉ម ប៊ុននាង** បាននាំនូវបណ្តាំផ្ញើសួរសុខទុក្ខ ប្រកបដោយសេចក្តីនឹករលឹកពីសំណាក់សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** ប្រធានព្រឹទ្ធសភានិងសម្តេចកិត្តិព្រឹទ្ធបណ្ឌិត ឯកឧត្តម **អ៊ុច បូររិទ្ធ** អនុប្រធានទី១និងឯកឧត្តមបណ្ឌិត **ធន់ វឌ្ឍនា** អនុប្រធានទី២ព្រឹទ្ធសភា ជូនដល់ថ្នាក់ដឹកនាំខេត្ត មន្ត្រីរាជការគ្រប់ជាន់ថ្នាក់ និងប្រជាពលរដ្ឋក្នុងខេត្តកំពង់ស្ពឺ ព្រមទាំងបានចូលរួមរំលែកការលំបាកជាមួយប្រជាជនភៀសសឹកទាំងអស់។



*ឯកឧត្តម ម៉ម ប៊ុននាង និងឯកឧត្តមបណ្ឌិត ជាម ច័ន្ទសោភ័ណ*

**ឯកឧត្តមប្រធានគណៈប្រតិភូ** បានគូសបញ្ជាក់ថា ព្រឹទ្ធសភា នីតិកាលទី៥ ក្រោមការដឹកនាំប្រកបដោយគតិបណ្ឌិតខ្ពស់របស់ សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** ប្រធានព្រឹទ្ធសភា បានយកចិត្តទុកដាក់ខ្ពស់ចំពោះសុខុមាលភាពរបស់ប្រជាពលរដ្ឋនៅទូទាំងប្រទេស និងបានកំណត់ការងារអាទិភាពចម្បងចំនួនពីរ គឺត្រូវចុះជាប់ជាមួយអាជ្ញាធរនិងប្រជាជន និងការលើកកម្ពស់ការងារការទូតសភា ខណៈពេលដែលប្រទេសជាតិយើងកំពុងប្រឈមនឹងការឈ្លានពានដែនអធិបតេយ្យពីប្រទេសថៃ ដើម្បីស្វែងរកដំណោះស្រាយបញ្ហាព្រំដែនដោយយុត្តិធម៌ ត្រឹមត្រូវ យូរអង្វែង ស្របតាមច្បាប់អន្តរជាតិ សន្ធិសញ្ញា អនុសញ្ញា និងកិច្ចព្រមព្រៀងដែលមានស្រាប់ និងប្រកាន់ជំហរជាគោលការណ៍ថា ខ្សែព្រំដែនមិនត្រូវបានផ្លាស់ប្តូរតាមរយៈការប្រើប្រាស់កម្លាំងនោះឡើយ។



*ទិដ្ឋភាពគណៈប្រតិភូព្រឹទ្ធសភា និងរដ្ឋបាលខេត្តកំពង់ស្ពឺ ចូលរួមក្នុងពិធីសំណេះសំណាល*

**ឯកឧត្តមប្រធានគណៈប្រតិភូ** បានវាយតម្លៃខ្ពស់ចំពោះកិច្ចខិតខំប្រឹងប្រែងរបស់ថ្នាក់ដឹកនាំ និងមន្ត្រីរាជការគ្រប់ជាន់ថ្នាក់ ដែលបានផ្តល់សេវាដ៏គាប់ប្រសើរជូនប្រជាពលរដ្ឋ និងធ្វើឱ្យមូលដ្ឋានមានការអភិវឌ្ឍរីកចម្រើនគួរឱ្យកត់សម្គាល់។ ទន្ទឹមនឹងនោះ ឯកឧត្តមបញ្ជាក់ប្រាប់រដ្ឋបាលខេត្តកំពង់ស្ពឺថា មូលនិធិចែករំលែកសង្គ្រោះជីវិតសកលនៃសាធារណរដ្ឋកូរ៉េ ដឹកនាំដោយឯកឧត្តម **គីម ចុងណាម** បានផ្តល់ជំនួយមនុស្សធម៌ មានដូចជា ឱសថ ឧបករណ៍វេជ្ជសាស្ត្រ និងសម្ភារៈប្រើប្រាស់ប្រចាំថ្ងៃយ៉ាងច្រើនដល់ព្រឹទ្ធសភាកម្ពុជា ដើម្បីជួយលើកកម្ពស់សុខុមាលភាពប្រជាជនកម្ពុជា ហើយកាលពីពេលថ្មីៗនេះ អំណោយទាំងអស់នោះបានជួយដល់ជនភៀសសឹក ដែលរងផលប៉ះពាល់ពីការវាយប្រហាររបស់ថៃ។

បន្ថែមពីនេះ **ឯកឧត្តមប្រធានគណៈប្រតិភូ** បានណែនាំដល់អាជ្ញាធរ សូមអំពាវនាវដល់ប្រជាពលរដ្ឋទាំងអស់ឱ្យបញ្ឈប់ការផ្សព្វផ្សាយជាបន្ទាន់នូវរាល់ព័ត៌មាន, វីដេអូ ឬរូបភាព ដែលអាចបង្ហាញពីសកម្មភាពប្រតិបត្តិការយោធា ការផ្គត់ផ្គង់សម្ភារៈបរិក្ខារ ឬស្បៀងអាហារជូនកងទ័ព និងជនភៀសសឹក នៅតាមគ្រប់បណ្តាញទំនាក់ទំនងសង្គម ឬប្រព័ន្ធផ្សព្វផ្សាយផ្សេងៗទៀតជាដាច់ខាត។

តាងនាមរដ្ឋបាលខេត្ត និងប្រជាពលរដ្ឋទូទាំងខេត្តកំពង់ស្ពឺ ឯកឧត្តមបណ្ឌិត **ជាម ច័ន្ទសោភ័ណ** បានថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅចំពោះ **សម្តេចតេជោ** ប្រធានព្រឹទ្ធសភា ថ្នាក់ដឹកនាំព្រឹទ្ធសភា ជាពិសេសគណៈកម្មការទី១០ព្រឹទ្ធសភា និងក្រុមសមាជិកព្រឹទ្ធសភាប្រចាំភូមិភាគទី៧ ព្រមទាំងមូលនិធិចែករំលែកសង្គ្រោះជីវិតសកលនៃសាធារណរដ្ឋកូរ៉េ ដែលបានយកចិត្តទុកដាក់ខ្ពស់ដល់សុខុមាលភាពរបស់ប្រជាពលរដ្ឋក្នុងខេត្តកំពង់ស្ពឺ។ **ឯកឧត្តមអភិបាលខេត្ត** បានប្តេជ្ញាថា នឹងគ្រប់គ្រង បែងចែកអំណោយទាំងអស់នេះ ឱ្យដល់ដៃអាជ្ញាធរ និងប្រជាពលរដ្ឋក្រីក្រ ជនងាយរងគ្រោះ និងជនភៀសសឹក ប្រកបដោយតម្លាភាព ប្រសិទ្ធភាព ស័ក្តិសិទ្ធភាព និងបរិយាបន្ន។ អំណោយមនុស្សធម៌របស់ព្រឹទ្ធសភា និងរបស់មូលនិធិ គឺពិតជាមានសារៈសំខាន់ ហើយត្រូវនឹងតម្រូវការចាំបាច់របស់ប្រជាពលរដ្ឋនៅមូលដ្ឋានខេត្តកំពង់ស្ពឺ៕

អត្ថបទ និងរូបភាព៖ នាយកដ្ឋានព័ត៌មាន







*ឯកឧត្តម ម៉ម ប៊ុននាង ប្រគល់អំណោយជូនរដ្ឋបាលខេត្តកំពង់ស្ពឺ*

# ក្រុមសមាជិកព្រឹទ្ធសភាប្រចាំភូមិភាគទី៣ អញ្ជើញសំណេះសំណាល ជាមួយអាជ្ញាធរស្រុកលើកដែក និងស្រុកកៀនស្វាយ ខេត្តកណ្តាល

នៅថ្ងៃសៅរ៍ ទី២៤ ខែមករា ឆ្នាំ២០២៦ ក្រុមសមាជិកព្រឹទ្ធសភាប្រចាំភូមិភាគទី៣ (ខេត្តកណ្តាល) ដឹកនាំដោយ ឯកឧត្តម **ម៉ម ប៊ុននាង** ប្រធានក្រុម បានអញ្ជើញជួបសំណេះសំណាលដាច់ដោយឡែកពីគ្នាជាមួយថ្នាក់ដឹកនាំ ក្រុមប្រឹក្សាឃុំ ស្មៀន និងនាយប៉ុស្តិ៍នគរបាលរដ្ឋបាលឃុំ នៅស្រុកលើកដែក និងស្រុកកៀនស្វាយ ខេត្តកណ្តាល សរុបចំនួន២២៣នាក់។



*ឯកឧត្តម ម៉ម ប៊ុននាង ប្រធានក្រុមសមាជិកព្រឹទ្ធសភាប្រចាំភូមិភាគទី៣ (កណ្តាល)*

ឯកឧត្តម **ម៉ម ប៊ុននាង** បាននាំនូវប្រសាសន៍ផ្តាំផ្ញើសាកសួរសុខទុក្ខពីសំណាក់ថ្នាក់ដឹកនាំព្រឹទ្ធសភា ជូនចំពោះអាជ្ញាធរគ្រប់ជាន់ថ្នាក់និងប្រជាពលរដ្ឋគ្រប់មូលដ្ឋានដោយក្តីនឹករលឹកបំផុត និងបានជម្រាបជូនអំពីគោលបំណងនៃពិធីសំណេះសំណាល គឺដើម្បីលើកកម្ពស់គុណភាពនិងប្រសិទ្ធភាពនៃការផ្តល់សេវាសាធារណៈ គោលនយោបាយភូមិឃុំ សង្កាត់មានសុវត្ថិភាព និងលើកស្ទួយជីវភាពរស់នៅរបស់ប្រជាជន ដោយផ្សារភ្ជាប់និងរួមប្រាស្រ័យទាក់ទងឱ្យកាន់តែជិតស្និទ្ធជាមួយថ្នាក់ដឹកនាំក្រុង ស្រុក ជាពិសេសអង្គបោះឆ្នោត ដែលជាសមាជិកក្រុមប្រឹក្សាឃុំ សង្កាត់ ព្រមទាំងពិភាក្សាឈ្វេងយល់អំពីបញ្ហាប្រឈម សំណូមពរ និងវឌ្ឍនភាពនៅក្នុងមូលដ្ឋាន។

ដោយភ្ជាប់នឹងគោលនយោបាយភូមិ ឃុំ សង្កាត់មានសុវត្ថិភាព **ឯកឧត្តមប្រធានក្រុម** បានលើកឡើងអំពីបទល្មើសឆបោកតាមប្រព័ន្ធបច្ចេកវិទ្យា ដោយជំរុញឱ្យអាជ្ញាធរស្រុក ឃុំ និងនាយប៉ុស្តិ៍នគរបាលរដ្ឋបាល ត្រូវរួមសហការគ្នា ធ្វើយ៉ាងណាក្តាប់ឱ្យជាប់ចំពោះមនុស្សចំណូលថ្មី ជាពិសេសជនជាតិបរទេស ដែលមកស្នាក់នៅក្នុងមូលដ្ឋានរបស់ខ្លួន ស្របពេលដែលអាជ្ញាធរទូទាំងប្រទេសបានបើកប្រតិបត្តិការបង្រ្កាបក្រុមឧក្រិដ្ឋជនពាក់ព័ន្ធបទល្មើសឆបោកតាមប្រព័ន្ធបច្ចេកវិទ្យា ដើម្បីឈានទៅបង្ក្រាបដល់ឫសគល់ និងបានទាន់ពេលវេលា។

**ឯកឧត្តមប្រធានក្រុម** បានជម្រាបជូនជុំវិញបញ្ហានៃការរំលោភបំពាន និងការឈ្លានពានយ៉ាងគឃ្លើនរបស់យោធាថៃមកលើបូរណភាពទឹកដីកម្ពុជា ក្រោយពីកិច្ចព្រមព្រៀងឈប់បាញ់បានចូលជាធរមាន កាលពីថ្ងៃទី២៧ ខែធ្នូ ឆ្នាំ២០២៥ និងការប្តឹងទៅតុលាការយុត្តិធម៌អន្តរជាតិ (ICJ)និងទៅ


*ក្រុមប្រឹក្សាឃុំ ស្មៀន និងនាយប៉ុស្តិ៍នគរបាលរដ្ឋបាលឃុំ នៅស្រុកលើកដែក ខេត្តកណ្តាល*



*ឯកឧត្តម ម៉ម ប៊ុននាង ឡើងមានប្រសាសន៍ក្នុងពិធីសំណេះសំណាល*

អង្គការសហប្រជាជាតិ (UN) របស់រាជរដ្ឋាភិបាលកម្ពុជា ដើម្បីប្រឆាំងនឹងការឈ្លានពានរបស់យោធាថៃមកលើ បូរណភាពទឹកដីកម្ពុជា។ កម្ពុជាប្រកាន់ជំហរយ៉ាងម៉ឺងម៉ាត់ និងច្បាស់លាស់ ក្នុងការការពារខ្សែព្រំដែនអន្តរជាតិកម្ពុជា-ថៃ ដែលបន្សល់ទុកដោយគណៈកម្មការព្រំដែនឥណ្ឌូចិន-សៀម ដោយគោរពគោលការណ៍ច្បាប់អន្តរជាតិ គោលការណ៍ខ្សែព្រំដែនមិនកែប្រែ, គោរពអនុសញ្ញា សន្ធិសញ្ញាបារាំង-សៀម ផែនទី និងកំណត់ហេតុបោះបង្គោលព្រំដែនរបស់គណៈ-កម្មការបោះបង្គោលព្រំដែនឥណ្ឌូចិន-សៀម។ កម្ពុជាតែងតែឈរលើយន្តការការទូតដ៏ម៉ឺងម៉ាត់បំផុតនិងផ្អែកលើច្បាប់អន្តរជាតិ ដែលជាយន្តការការទូតតាមបែបសន្តិសហវិជ្ជមាន ដើម្បីរួមរស់ជាមួយប្រទេសជិតខាង និងបណ្តាប្រទេសទាំងអស់នៅលើពិភពលោក។

ក្នុងឱកាសនោះ លោកជំទាវ **ស្នួស សារ៉ាម** សមាជិកាក្រុមសមាជិកព្រឹទ្ធសភាប្រចាំភូមិភាគទី៣ បានផ្សព្វផ្សាយអំពីសមិទ្ធផលសំខាន់ៗរបស់ព្រឹទ្ធសភាក្នុងឆ្នាំ២០២៥ ក្រោមការដឹកនាំដ៏ខ្ពង់ខ្ពស់និងប្រកបដោយគតិបណ្ឌិតរបស់សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** ប្រធានព្រឹទ្ធសភា។

បន្ទាប់ពីបានពិភាក្សាគ្នារួចមក ឯកឧត្តម **ម៉ម ប៊ុននាង** បានវាយតម្លៃខ្ពស់ចំពោះអាជ្ញាធរពាក់ព័ន្ធទាំងអស់ ដែលបានខិតខំបំពេញតួនាទី ភារកិច្ចរបស់ខ្លួនប្រកបដោយស្មារតីទទួលខុសត្រូវខ្ពស់ និងសម្រេចបានសមិទ្ធផលជាច្រើនគួរឱ្យកត់សម្គាល់។ ជាមួយគ្នានេះ ឯកឧត្តមបានលើកទឹកចិត្តដល់ក្រុមប្រឹក្សាឃុំ និងអាជ្ញាធរទាំងអស់បន្តពង្រឹងសមត្ថភាពជាប្រចាំ ដើម្បីបម្រើផលប្រយោជន៍ជូនប្រជាពលរដ្ឋឱ្យកាន់តែល្អប្រសើរ និងប្រកបដោយប្រសិទ្ធភាពខ្ពស់ និងសូមអំពាវនាវដល់អង្គពិធីទាំងមូល និងប្រជាពលរដ្ឋគ្រប់រូបបន្តសាមគ្គីភាពគ្នា ដើម្បីក្លាយជាកម្លាំងស្មារតីសាមគ្គីជាតិជាធ្លុងមួយ គាំទ្រដល់វីរកងកម្លាំងប្រដាប់អាវុធគ្រប់រូប ដែលកំពុងឈរជើងយ៉ាងអង់អាចក្លាហាន ក្នុងការការពារដែនអធិបតេយ្យ និងបូរណភាពទឹកដីរបស់កម្ពុជា ជាពិសេសសូមអំពាវនាវឱ្យកម្លាំងមហាសាមគ្គីភាពនេះ បន្តគាំទ្ររាជរដ្ឋាភិបាល ដែលកំពុងប្រយុទ្ធតាមរយៈការទូតប្រឆាំងនឹងការឈ្លានពានរបស់យោធាថៃមកលើបូរណភាពទឹកដីកម្ពុជា។ សាមគ្គីរស់! សាមគ្គីឈ្នះ!៕

អត្ថបទ និងរូបភាព៖ នាយកដ្ឋានព័ត៌មាន



*លោកជំទាវ ស្នួស សារ៉ាម សមាជិកាក្រុមសមាជិកព្រឹទ្ធសភាប្រចាំភូមិភាគ ទី៣ បានឡើងផ្សព្វផ្សាយអំពីសមិទ្ធផលសំខាន់ៗរបស់ព្រឹទ្ធសភា*



*ទិដ្ឋភាពក្រុមប្រឹក្សាឃុំ ស្មៀន និងនាយប៉ុស្តិ៍នគរបាលរដ្ឋបាលឃុំ នៅស្រុកកៀនស្វាយ ខេត្តកណ្តាល ចូលរួមក្នុងពិធីសំណេះសំណាល*

# ក្រុមសមាជិកាព្រឹទ្ធសភា អញ្ជើញជួបសំណេះសំណាល និងនាំយកចង្ក្រានសន្សំសំចៃថាមពលចែកជូនប្រជាពលរដ្ឋ ក្នុងស្រុកបរិបូណ៌





*លោកជំទាវ មាន សំអាន និងសម្តេចរាជបុត្រីព្រះអនុជ នរោត្តម អរុណរស្មី សំណេះសំណាលជាមួយប្រជាពលរដ្ឋ*

ក្រុមសមាជិកាព្រឹទ្ធសភា ដឹកនាំដោយលោកជំទាវ **មាន សំអាន** ប្រធានក្រុម និងជាអនុប្រធានសមាគមនារីកម្ពុជាដើម្បីសន្តិភាព និងអភិវឌ្ឍន៍ និងមានការយាងអញ្ជើញចូលរួមពី សម្តេចរាជបុត្រីព្រះអនុជ **នរោត្តម អរុណរស្មី** ឧត្តមប្រឹក្សាផ្ទាល់ព្រះមហាក្សត្រ នៃព្រះរាជាណាចក្រកម្ពុជា និងជាសមាជិកាព្រឹទ្ធសភា លោកជំទាវ **កែ ចន្ទមុនី** តំណាងរាស្ត្រមណ្ឌលខេត្តកំពង់ឆ្នាំង បានអញ្ជើញជួបសំណេះសំណាល សួរសុខទុក្ខ និងនាំយកចង្ក្រានសន្សំសំចៃថាមពលដែលជាអំណោយរបស់ក្រុមហ៊ុន SIPCO ជូនប្រជាពលរដ្ឋចំនួន១៣០០គ្រួសារ នៅឃុំផ្សារ ស្រុកបរិបូណ៌ ខេត្តកំពង់ឆ្នាំង នាថ្ងៃសៅរ៍ ទី២៤ ខែមករា ឆ្នាំ២០២៦។

មានប្រសាសន៍ក្នុងពេលនោះ **លោកជំទាវប្រធាន** បាននាំយកប្រសាសន៍ផ្តាំផ្ញើសួរសុខទុក្ខប្រកបដោយក្តីនឹករលឹកពីសំណាក់ សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** ប្រធានព្រឹទ្ធសភា សម្តេចកិត្តិព្រឹទ្ធបណ្ឌិត **ប៊ុន រ៉ានី ហ៊ុនសែន** សម្តេចមហាបវរធិបតី **ហ៊ុន ម៉ាណែត** និង**លោកជំទាវបណ្ឌិត** និងសម្តេចកិត្តិសង្គហបណ្ឌិត **ម៉ែន សំអន** ឧត្តមប្រឹក្សាផ្ទាល់ព្រះមហាក្សត្រ និងជាប្រធានសមាគមនារីកម្ពុជាដើម្បីសន្តិភាពនិងអភិវឌ្ឍន៍។

**លោកជំទាវប្រធាន** បានជម្រាបអំពីសភាពការណ៍



*ទិដ្ឋភាពប្រជាពលរដ្ឋចូលរួមក្នុងពិធីសំណេះសំណាល*





ព្រំដែននិងការឈ្លានពានរបស់ទាហានថៃមកលើទឹកដីកម្ពុជា ធ្វើឱ្យបងប្អូនទាំងអស់គ្នាមានការឈឺចាប់ ទុក្ខព្រួយ និងសោកស្ដាយជាទីបំផុត។ តាំងពីដើមមកកម្ពុជាមិនដែលមានគំនិត ឬបំណងណាមួយទៅឈ្លានពានប្រទេសថៃឡើយ សូម្បីតែដីមួយមិល្លីម៉ែត្រក៏មិនចង់បានដែរ។ លោកជំទាវបានអំពាវនាវដល់ពុកម៉ែបងប្អូនទាំងអស់ក្នុងខេត្តកំពង់ឆ្នាំង ត្រូវជឿទុកចិត្តលើការដឹកនាំរបស់**សម្ដេច**ទាំងទ្វេ ក្នុងការនាំនាវាកម្ពុជាឆ្ពោះទៅរកសុខសន្តិភាព និងភាពជឿនលឿន។

ទន្ទឹមនឹងនេះ **លោកជំទាវប្រធាន** បានសម្ដែងនូវការកោតសរសើរចំពោះថ្នាក់ដឹកនាំគ្រប់លំដាប់ថ្នាក់នៃស្រុកបរិបូណ៌ ដែលបានខិតខំប្រឹងប្រែងយកអស់កម្លាំងកាយចិត្តប្រាជ្ញា ស្មារតី និងទទួលខុសត្រូវក្នុងការបំពេញភារកិច្ចការងារក្នុងរយៈពេលកន្លងទៅ និងសូមបងប្អូនប្រជាពលរដ្ឋបន្តចូលរួមចំណែកគាំទ្រ ឧបត្ថម្ភ ជាសម្ភារៈ និងថវិកា ជួយជនភៀសសឹកនិងវីរកងទ័ព នៅសមរភូមិ។



*ក្រុមសមាជិកាព្រឹទ្ធសភាចែកចង្រ្កានសន្សំសំចៃថាមពល ជូនប្រជាពលរដ្ឋរស់នៅឃុំផ្សារ ស្រុកបរិបូរណ៍ ខេត្តកំពង់ឆ្នាំង*

**លោកជំទាវប្រធាន** បានបញ្ជាក់ថា ការចែកចង្រ្កានសន្សំសំចៃថាមពលជូនបងប្អូនប្រជាពលរដ្ឋនាពេលនេះ គឺដើម្បីឱ្យយើងទាំងអស់គ្នាចូលរួមការពារបរិស្ថាន រួមចំណែកការពារសុខុមាលភាពរបស់ប្រជាពលរដ្ឋក្នុងមូលដ្ឋាន និងចូលរួមចំណែកក្នុងការកាត់បន្ថយការចំណាយប្រាក់របស់បងប្អូនប្រជាពលរដ្ឋ។ អំណោយដែលបានផ្ដល់ជូនប្រជា-ពលរដ្ឋក្នុងឱកាសនោះ ក្នុង១គ្រួសារទទួលបាន៖ ចង្រ្កានសន្សំសំចៃថាមពលចំនួន១ ព្រមទាំងឧបត្ថម្ភថវិកាមួយចំនួនដល់សាលាស្រុកបរិបូណ៌។

អត្ថបទ និងរូបភាព៖ នាយកដ្ឋានព័ត៌មាន



*ក្រុមសមាជិកាព្រឹទ្ធសភា ថតរូបអនុស្សាវរីយ៍ជាមួយប្រជាពលរដ្ឋរស់នៅឃុំផ្សារ ស្រុកបរិបូរណ៍ ខេត្តកំពង់ឆ្នាំង*

# កិច្ចប្រជុំគណៈកម្មការទាំង១០ ក្រុមភូមិភាគ និងក្រុមនានានៃព្រឹទ្ធសភា

**❈កិច្ចប្រជុំផ្ទៃក្នុងគណៈកម្មការទី១ព្រឹទ្ធសភា ចំនួន១លើក**



នាថ្ងៃទី២១ ខែមករា ឆ្នាំ២០២៦ ឯកឧត្តម **ឌី ច័ន្ទ្រផល** ប្រធានគណៈកម្មការ បានដឹកនាំកិច្ចប្រជុំផ្ទៃក្នុងគណៈកម្មការ ដើម្បីពិនិត្យពិភាក្សាលើ៖

១-របាយការណ៍សកម្មភាពនិងលទ្ធផលការងារប្រចាំខែមករានិងទិសដៅការងារខែកុម្ភៈឆ្នាំ២០២៦។

២-ជំនួបពិភាក្សាការងាររវាងគណៈកម្មការទី១ និងក្រសួងអធិការកិច្ច។

៣-គម្រោងបេសកកម្មរបស់គណៈកម្មការទៅកាន់ខេត្តកែប ខេត្តកំពត និងខេត្តព្រះសីហនុ។

៤-បញ្ហាផ្សេងៗ។

**❈កិច្ចប្រជុំផ្ទៃក្នុងគណៈកម្មការទី២ព្រឹទ្ធសភា ចំនួន១លើក**



នាព្រឹកថ្ងៃចន្ទ ទី១៩ ខែមករា ឆ្នាំ២០២៦ ឯកឧត្តម **យស ផានីត្ថា** ប្រធានគណៈកម្មការ បានដឹកនាំកិច្ចប្រជុំផ្ទៃក្នុងគណៈកម្មការ ដើម្បីពិនិត្យពិភាក្សាលើ៖

១-របាយការណ៍ប្រចាំខែមករា។

២-ការចុះបេសកកម្មចន្លោះសម័យប្រជុំលើកទី៤ និងទី៥ នៅខេត្តត្បូងឃ្មុំនិងខេត្តមណ្ឌលគិរី។

៣-បញ្ហាផ្សេងៗ។

**❈កិច្ចប្រជុំផ្ទៃក្នុងក្រុមសមាជិកព្រឹទ្ធសភា (ក្រុមទី១) ចំនួន២លើក៖**



ឯកឧត្តម **យស ផានីត្ថា** ប្រធានក្រុម បានដឹកនាំកិច្ចប្រជុំដូចខាងក្រោម៖

-កិច្ចប្រជុំផ្ទៃក្នុងក្រុមសមាជិកព្រឹទ្ធសភា (ក្រុមទី១) នារសៀលថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២៥ ដើម្បីពិនិត្យនិងពិភាក្សាលើសេចក្ដីព្រាងច្បាប់ចំនួន៤ សម្រាប់ត្រៀមចូលរួមមតិក្នុងអង្គប្រជុំព្រឹទ្ធសភា។



-កិច្ចប្រជុំផ្ទៃក្នុងក្រុមសមាជិកព្រឹទ្ធសភា (ក្រុមទី១) នារសៀលថ្ងៃទី២០ ខែមករា ឆ្នាំ២០២៦ ដើម្បីពិនិត្យពិភាក្សានិងត្រៀមមានយោបល់លើសេចក្ដីព្រាងច្បាប់ស្ដីពី ការអនុម័តយល់ព្រមលើអនុញ្ញាអង្គការសហប្រជាជាតិស្ដីពីនីតិសមុទ្រ។

**❈កិច្ចប្រជុំផ្ទៃក្នុងក្រុមសមាជិកព្រឹទ្ធសភាប្រចាំភូមិភាគទី៧ ចំនួន១លើក**



នាព្រឹកថ្ងៃទី១៤ ខែមករា ឆ្នាំ២០២៦ ឯកឧត្តមបណ្ឌិត **ម៉ុង ឫទ្ធី** ប្រធានក្រុម បានដឹកនាំកិច្ចប្រជុំផ្ទៃក្នុងក្រុមសមាជិកព្រឹទ្ធសភាប្រចាំភូមិភាគទី៧ ដើម្បីពិនិត្យ ពិភាក្សាលើ៖

១-គោលបំណង និងកាលបរិច្ឆេទ ដើម្បីត្រៀមជួបសំណេះសំណាលជាមួយក្រុមប្រឹក្សាឃុំ សង្កាត់ ស្មៀន និងនាយប៉ុស្តិ៍នគរបាលរដ្ឋបាលទាំងអស់ ក្នុងខេត្តព្រះសីហនុ និងខេត្តកំពង់ស្ពឺ។

២-បញ្ហាផ្សេងៗ។

### ❈កិច្ចប្រជុំផ្ទៃក្នុងក្រុមសមាជិកព្រឹទ្ធសភា (ក្រុមទី២) ចំនួន២លើក៖

ឯកឧត្តមបណ្ឌិត **នាង ផាត** ប្រធានក្រុម បានដឹកនាំកិច្ចប្រជុំដូចខាងក្រោម៖



-កិច្ចប្រជុំផ្ទៃក្នុងក្រុមសមាជិកព្រឹទ្ធសភា (ក្រុមទី២) នាថ្ងៃទី៧ ខែមករា ឆ្នាំ២០២៦ ដើម្បីពិនិត្យពិភាក្សាលើសេចក្តីព្រាងច្បាប់ស្តីពី៖

១-អាកាសចរណ៍ស៊ីវិល នៃព្រះរាជាណាចក្រកម្ពុជា។

២-ការអនុម័តយល់ព្រមលើកិច្ចព្រមព្រៀងគ្រប់ជ្រុងជ្រោយស្តីពីការដឹកជញ្ជូនតាមផ្លូវអាកាស រវាងរដ្ឋសមាជិកសមាគមប្រជាជាតិអាស៊ីអាគ្នេយ៍ និងសហភាពអឺរ៉ុប និងរដ្ឋសមាជិករបស់ខ្លួន។

៣-ការអនុម័តយល់ព្រមលើពិធីសារទី៣ ស្តីពីការពង្រីកសិទ្ធិហោះហើរទី៥ រវាងភាគីចុះកិច្ចព្រមព្រៀង ក្រោមកិច្ចព្រមព្រៀងដឹកជញ្ជូនតាមផ្លូវអាកាស រវាងរដ្ឋាភិបាល នៃរដ្ឋសមាជិកសមាគមប្រជាជាតិអាស៊ីអាគ្នេយ៍ និងរដ្ឋាភិបាល នៃសាធារណរដ្ឋប្រជាមានិតចិន។

៤-ការអនុម័តយល់ព្រមលើពិធីសារអនុវត្តកញ្ចប់កិច្ចសន្យាទី១១ និងទី១២នៃសេវាកម្មដឹកជញ្ជូនតាមផ្លូវអាកាស ក្រោមកិច្ចព្រមព្រៀងក្របខ័ណ្ឌអាស៊ាន ស្តីពីសេវាកម្ម។

៥-បញ្ហាផ្សេងៗ។



-កិច្ចប្រជុំផ្ទៃក្នុងក្រុមសមាជិកព្រឹទ្ធសភា (ក្រុមទី២) នាព្រឹកថ្ងៃទី២០ ខែមករា ឆ្នាំ២០២៦ ដើម្បីពិនិត្យពិភាក្សានិងត្រៀមយោបល់លើសេចក្តីព្រាងច្បាប់ស្តីពី «ការអនុម័តយល់ព្រមលើអនុសញ្ញាអង្គការសហប្រជាជាតិស្តីពី នីតិសមុទ្រ» និងបញ្ហាផ្សេងៗ។

### ❈កិច្ចប្រជុំផ្ទៃក្នុងគណៈកម្មការទី៥ព្រឹទ្ធសភា ចំនួន២លើក៖

ឯកឧត្តម **ខាន់ ចំរើន** ប្រធានស្តីទីគណៈកម្មការ និងឯកឧត្តម **អ៊ុំ សារឹទ្ធ** ប្រធានគណៈកម្មការទី៥ព្រឹទ្ធសភា បានដឹកនាំកិច្ចប្រជុំផ្ទៃក្នុងដូចខាងក្រោម៖



-កិច្ចប្រជុំផ្ទៃក្នុងគណៈកម្មការ នាថ្ងៃទី៣០ និងថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២៥ ដើម្បីត្រៀមរបាយការណ៍និងពិនិត្យសិក្សាលើសេចក្តីព្រាងច្បាប់ចំនួន៣៖

១-កិច្ចព្រមព្រៀងគ្រប់ជ្រុងជ្រោយ ស្តីពីការដឹកជញ្ជូនតាមផ្លូវអាកាស រវាងរដ្ឋសមាជិកសមាគមប្រជាជាតិអាស៊ីអាគ្នេយ៍និងសហភាពអឺរ៉ុប និងរដ្ឋសមាជិករបស់ខ្លួន។

២-ពិធីសារទី៣ ស្តីពីការពង្រីកសិទ្ធិហោះហើរទី៥ រវាងភាគីចុះកិច្ចព្រមព្រៀងក្រោមកិច្ចព្រមព្រៀងដឹកជញ្ជូនតាមផ្លូវអាកាស រវាងរដ្ឋាភិបាល នៃរដ្ឋសមាជិក សមាគមប្រជាជាតិអាស៊ីអាគ្នេយ៍និងរដ្ឋាភិបាលនៃសាធារណ

រដ្ឋប្រជាមានិតចិន។

៣-ពិធីសារអនុវត្តកញ្ចប់កិច្ចសន្យាទី១១និងទី១២ នៃសេវាកម្មដឹកជញ្ជូនតាមផ្លូវអាកាស ក្រោមកិច្ចព្រម-ព្រៀងក្របខ័ណ្ឌអាស៊ានស្តីពី សេវាកម្ម (ជាសមត្ថកិច្ចរបស់គណៈកម្មការទាំងពីរ ដែលនឹងបញ្ជូនមកព្រឹទ្ធសភានាពេលខាងមុខ)។



-នាព្រឹកថ្ងៃពុធ ទី២១ ខែមករា ឆ្នាំ២០២៦ ឯកឧត្តម **ឆាយ ថណ្ណា** ប្រធានស្តីទីគណៈកម្មការ បានដឹកនាំកិច្ចប្រជុំផ្ទៃក្នុងគណៈកម្មការ ដើម្បីបោះឆ្នោតជ្រើសរើសប្រធានគណៈកម្មការ។ តាមរយៈលទ្ធផលនៃការបោះឆ្នោតផ្ទៃក្នុងគណៈកម្មការ ឯកឧត្តមបណ្ឌិត **ឈីវ យីស៊ាង** ត្រូវបានជាប់ឆ្នោតជាប្រធានគណៈកម្មការ ជំនួសឯកឧត្តមបណ្ឌិត **ចែម វីឌ្យា** ដែលត្រូវទៅកាន់មុខតំណែងថ្មី។

### ❈កិច្ចប្រជុំផ្ទៃក្នុងក្រុមសមាជិកព្រឹទ្ធសភា (ក្រុមទី៣) ចំនួន២លើក៖



-នាព្រឹកថ្ងៃទី៣០ ខែធ្នូ ឆ្នាំ២០២៥ លោកជំទាវបណ្ឌិត **ចាន់ សុទ្ធាវី** ប្រធានស្តីទីក្រុម បានដឹកនាំកិច្ចប្រជុំផ្ទៃក្នុងក្រុមសមាជិកព្រឹទ្ធសភា (ក្រុមទី៣) នៅសាលប្រជុំគណៈ-កម្មការទី៥ព្រឹទ្ធសភា ដើម្បីពិនិត្យ ពិភាក្សាលើ៖

១-សេចក្តីព្រាងច្បាប់ស្តីពី អាកាសចរណ៍ស៊ីវិល នៃព្រះរាជាណាចក្រកម្ពុជា។

២-សេចក្តីព្រាងច្បាប់ស្តីពី ការអនុម័តយល់ព្រមលើកិច្ច-ព្រមព្រៀងគ្រប់ជ្រុងជ្រោយ ស្តីពីការដឹកជញ្ជូនតាមផ្លូវអាកាស រវាងរដ្ឋសមាជិកសមាគមប្រជាជាតិអាស៊ី-អាគ្នេយ៍និងសហភាពអឺរ៉ុប និងរដ្ឋសមាជិករបស់ខ្លួន។

៣-សេចក្តីព្រាងច្បាប់ស្តីពី ការអនុម័តយល់ព្រមលើពិធីសារទី៣ ស្តីពីការពង្រីកសិទ្ធិហោះហើរទី៥ រវាងភាគីចុះកិច្ចព្រមព្រៀងក្រោមកិច្ចព្រមព្រៀងដឹកជញ្ជូនតាមផ្លូវអាកាសរវាងរដ្ឋាភិបាល នៃរដ្ឋសមាជិកសមាគមប្រជាជាតិអាស៊ីអាគ្នេយ៍និងរដ្ឋាភិបាល នៃសាធារណរដ្ឋប្រជាមានិតចិន។

៤-សេចក្តីព្រាងច្បាប់ស្តីពី ការអនុម័តយល់ព្រមលើពិធីសារអនុវត្តកញ្ចប់កិច្ចសន្យាទី១១និងទី១២ នៃសេវា-កម្មដឹកជញ្ជូនតាមផ្លូវអាកាសក្រោមកិច្ចព្រមព្រៀងក្របខ័ណ្ឌអាស៊ានស្តីពី សេវាកម្ម។

៥-បញ្ហាផ្សេងៗ។



-នារសៀលថ្ងៃទី២០ ខែមករា ឆ្នាំ២០២៦ ឯកឧត្តមបណ្ឌិត **ឈីវ យីស៊ាង** ប្រធានក្រុម បានដឹកនាំកិច្ចប្រជុំផ្ទៃក្នុងក្រុមសមាជិកព្រឹទ្ធសភា (ក្រុមទី៣) ដើម្បីពិនិត្យ ពិភាក្សា៖

១-ត្រៀមផ្តល់យោបល់លើសេចក្តីព្រាងច្បាប់ស្តីពីការអនុម័តយល់ព្រមលើអនុសញ្ញាអង្គការសហប្រជាជាតិស្តីពី នីតិសមុទ្រ។

២-បញ្ហាផ្សេងៗ។

### ❈កិច្ចប្រជុំជាមួយតំណាងរាជរដ្ឋាភិបាល ចំនួន១លើក



នាព្រឹកថ្ងៃពុធ ទី៣១ ខែធ្នូ ឆ្នាំ២០២៥ ឯកឧត្តម **ម៉ាន់ ចំរើន** ប្រធានស្តីទីគណៈកម្មការទី៥ព្រឹទ្ធសភា និង ឯកឧត្តម **អ៊ុំ សារឹទ្ធ** ប្រធានគណៈកម្មការទី៩ព្រឹទ្ធសភា បានដឹកនាំកិច្ចប្រជុំរវាងគណៈកម្មការនានារបស់ព្រឹទ្ធសភា ជាមួយតំណាងរាជរដ្ឋាភិបាល ដឹកនាំដោយឯកឧត្តម **ម៉ៅ ហាវណ្ណាល់** រដ្ឋមន្ត្រីទទួលបន្ទុករដ្ឋលេខាធិការដ្ឋានអាកាសចរណ៍ស៊ីវិល ដើម្បីពិនិត្យនិងពិភាក្សាលើសេចក្តីព្រាងច្បាប់ចំនួន៣ស្តីពី៖

១-ការអនុម័តយល់ព្រមលើកិច្ចព្រមព្រៀងគ្រប់ជ្រុងជ្រោយស្តីពី ការដឹកជញ្ជូនតាមផ្លូវអាកាសរវាងរដ្ឋសមាជិកសមាគមប្រជាជាតិអាស៊ីអាគ្នេយ៍និងសហភាពអឺរ៉ុប និងរដ្ឋសមាជិករបស់ខ្លួន។

២-ការអនុម័តយល់ព្រមលើពិធីសារទី៣ស្តីពី ការពង្រីកសិទ្ធិហោះហើរទី៥ រវាងភាគីចុះកិច្ចព្រមព្រៀងក្រោមកិច្ចព្រមព្រៀងដឹកជញ្ជូនតាមផ្លូវអាកាសរវាងរដ្ឋាភិបាលនៃរដ្ឋសមាជិកសមាគមប្រជាជាតិអាស៊ីអាគ្នេយ៍ និងរដ្ឋាភិបាល នៃសាធារណរដ្ឋប្រជាមានិតចិន។

៣-ការអនុម័តយល់ព្រមលើពិធីសារអនុវត្តកញ្ចប់កិច្ចសន្យាទី១១និងទី១២ នៃសេវាកម្មដឹកជញ្ជូនតាមផ្លូវអាកាសក្រោមកិច្ចព្រមព្រៀង ក្របខ័ណ្ឌអាស៊ានស្តីពី សេវាកម្ម។

### ❈គណៈកម្មការទី៥ព្រឹទ្ធសភា ជួបភ្ញៀវអន្តរជាតិ ចំនួន១លើក



នាព្រឹកថ្ងៃអង្គារ ទី១៣ ខែមករា ឆ្នាំ២០២៦ ឯកឧត្តម **ម៉ាន់ ចំរើន** ប្រធានស្តីទីគណៈកម្មការ បានទទួលជួបពិភាក្សាការងារជាមួយឯកឧត្តម Darius GAIDYS ឯកអគ្គរដ្ឋទូតវិសាមញ្ញនិងពេញសមត្ថភាព នៃសាធារណរដ្ឋលីទុយអានីប្រចាំព្រះរាជាណាចក្រកម្ពុជា (និវេសនដ្ឋាននៅប្រទេសសិង្ហបុរី)និងសហការី ដើម្បីផ្លាស់ប្តូរយោបល់លើការពង្រឹងកិច្ចសហប្រតិបត្តិការនានាដែលជាផលប្រយោជន៍រួមរវាងប្រទេសទាំងពីរ។

### ❈កិច្ចប្រជុំផ្ទៃក្នុងគណៈកម្មការទី៦ព្រឹទ្ធសភា ចំនួន១លើក



នាព្រឹកថ្ងៃទី១៩ ខែមករា ឆ្នាំ២០២៦ លោកជំទាវបណ្ឌិត **ចាន់ សុទ្ធាវី** ប្រធានគណៈកម្មការ បានដឹកនាំកិច្ចប្រជុំផ្ទៃក្នុងគណៈកម្មការ ដើម្បីពិនិត្យ ពិភាក្សាលើសេចក្តីព្រាងច្បាប់ស្តីពី ការអនុម័តយល់ព្រមលើអនុសញ្ញាអង្គការសហប្រជាជាតិស្តីពី នីតិសមុទ្រ។

### ❈កិច្ចប្រជុំជាមួយតំណាងរាជរដ្ឋាភិបាល ចំនួន១លើក



នារសៀលថ្ងៃទី១៩ ខែមករា ឆ្នាំ២០២៥ លោកជំទាវបណ្ឌិត **ចាន់ សុទ្ធាវី** ប្រធានគណៈកម្មការទី៦ព្រឹទ្ធសភា បានដឹកនាំកិច្ចប្រជុំរវាងគណៈកម្មការនានារបស់ព្រឹទ្ធសភា ជាមួយតំណាងរាជរដ្ឋាភិបាល ដឹកនាំដោយឯកឧត្តម **ប្រាក់ សុខុន** ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ ដើម្បីពិនិត្យសិក្សាលើសេចក្តីព្រាងច្បាប់ស្តីពី ការអនុម័តយល់ព្រមលើសន្ធិសញ្ញាអង្គការសហប្រជាជាតិស្តីពី នីតិសមុទ្រ។

### ❈កិច្ចប្រជុំផ្ទៃក្នុងគណៈកម្មការក្រមសីលធម៌សភារបស់សមាជិកព្រឹទ្ធសភា ចំនួន៣លើក៖

លោកជំទាវបណ្ឌិត **ចាន់ សុទ្ធាវី** ប្រធានគណៈកម្មការ បានដឹកនាំកិច្ចប្រជុំផ្ទៃក្នុងតាមកាលបរិច្ឆេទដូចខាងក្រោម៖



-នារសៀលថ្ងៃទី១៥ ខែមករា ឆ្នាំ២០២៦ ដើម្បីណែនាំដល់មន្ត្រីការិយាល័យ ក្នុងការរៀបចំសេចក្តីព្រាងរបាយការណ៍ប្រចាំឆ្នាំ២០២៥ របស់គណៈកម្មការក្រមសីលធម៌សភារបស់សមាជិកព្រឹទ្ធសភា និងបញ្ហាផ្សេងៗ។

-នាព្រឹកថ្ងៃទី១៦ ខែមករា ឆ្នាំ២០២៦ ដើម្បីពិនិត្យលើសេចក្តីព្រាងរបាយការណ៍បឋមរបស់គណៈកម្មការក្រមសីលធម៌សភារបស់សមាជិកព្រឹទ្ធសភា ប្រចាំឆ្នាំ២០២៥ និងបញ្ហាផ្សេងៗ។

-នាព្រឹកថ្ងៃទី២០ ខែមករា ឆ្នាំ២០២៦ គណៈកម្មការក្រមសីលធម៌សភារបស់សមាជិកព្រឹទ្ធសភា បានរៀបចំសេចក្តីព្រាងផែនការសកម្មភាពរបស់គណៈកម្មការក្រមសីលធម៌សភារបស់សមាជិកព្រឹទ្ធសភា និងបញ្ហាផ្សេងៗ។

### ❈កិច្ចប្រជុំផ្ទៃក្នុងគណៈកម្មការទី៧ព្រឹទ្ធសភា ចំនួន១លើក

នាថ្ងៃទី២១ ខែមករា ឆ្នាំ២០២៦ ឯកឧត្តម **ម៉ាន់ ឈឿន** ប្រធានស្តីទីគណៈកម្មការ បានដឹកនាំកិច្ចប្រជុំពិនិត្យនិងពិភាក្សាលើ៖



១-របាយការណ៍ស្តីពី លទ្ធផលការងាររបស់គណៈកម្មការប្រចាំខែមករានិងទិសដៅការងារខែកុម្ភៈ ឆ្នាំ២០២៦។

២-ការកំណត់កាលបរិច្ឆេទ និងកម្មវិធីសម្រាប់ចុះបំពេញបេសកកម្មនៅចន្លោះសម័យប្រជុំលើកទី៤ និងលើកទី៥។

៣-បញ្ហាផ្សេងៗ។

### ❈កិច្ចប្រជុំផ្ទៃក្នុងគណៈកម្មការទី៨ព្រឹទ្ធសភា ចំនួន១លើក

នារសៀលថ្ងៃទី១៦ ខែមករា ឆ្នាំ២០២៦ លោកជំទាវ **មាន សំអាន** ប្រធានគណៈកម្មការនិងលោកជំទាវ **ឃួន ឃុនឌី** លេខាធិការគណៈកម្មការ បានដឹកនាំប្រជុំជាមួយមន្ត្រីការិយាល័យជំនួយការគណៈកម្មការទី៨ និងមន្ត្រីការិយាល័យអមក្រុមសមាជិកាព្រឹទ្ធសភា ដើម្បីត្រៀមរៀបចំគ្រឿងឧបភោគ បរិភោគ និងសម្ភារៈប្រើប្រាស់សម្រាប់យកទៅប្រគល់ជូនវីរកងទ័ពជួរមុខ ប្រចាំនៅតំបន់អានសេះ ខេត្តព្រះវិហារ។

### ❈កិច្ចប្រជុំផ្ទៃក្នុងក្រុមសមាជិកព្រឹទ្ធសភា (ក្រុមទី៤) ចំនួន២លើក៖

លោកជំទាវ **មាន សំអាន** ប្រធានក្រុម បានដឹកនាំកិច្ចប្រជុំតាមកាលបរិច្ឆេទដូចខាងក្រោម៖



-នាព្រឹកថ្ងៃទី២ ខែមករា ឆ្នាំ២០២៦ បានប្រជុំពិនិត្យពិភាក្សាលើសេចក្តីព្រាងច្បាប់ស្តីពី៖

១-អាកាសចរណ៍ស៊ីវិលនៃព្រះរាជាណាចក្រកម្ពុជា។

២-ការអនុម័តយល់ព្រមលើកិច្ចព្រមព្រៀងគ្រប់ជ្រុងជ្រោយស្តីពីការដឹកជញ្ជូនតាមផ្លូវអាកាស រវាងរដ្ឋសមាជិកសមាគមប្រជាជាតិអាស៊ីអាគ្នេយ៍ និងសហភាពអឺរ៉ុប និងរដ្ឋសមាជិករបស់ខ្លួន។

៣-ការអនុម័តយល់ព្រមលើពិធីសារទី៣ស្តីពី ការពង្រីកសិទ្ធិហោះហើរទី៥ រវាងភាគីចុះកិច្ចព្រមព្រៀងក្រោមកិច្ចព្រមព្រៀងដឹកជញ្ជូនតាមផ្លូវអាកាសរវាងរដ្ឋាភិបាលនៃរដ្ឋសមាជិកសមាគមប្រជាជាតិអាស៊ីអាគ្នេយ៍ និងរដ្ឋាភិបាល នៃសាធារណរដ្ឋប្រជាមានិតចិន។

៤-ការអនុម័តយល់ព្រមលើពិធីសារអនុវត្តកញ្ចប់កិច្ចសន្យាទី១១ និងទី១២នៃសេវាកម្មដឹកជញ្ជូនតាមផ្លូវអាកាសក្រោមកិច្ចព្រមព្រៀងក្របខ័ណ្ឌអាស៊ានស្តីពី សេវាកម្ម។

៥-បញ្ហាផ្សេងៗ។



-នាថ្ងៃទី១៩ ខែមករា ឆ្នាំ២០២៦ បានប្រជុំពិនិត្យពិភាក្សាលើសេចក្តីព្រាងច្បាប់ស្តីពី ការអនុម័តយល់ព្រមលើសន្ធិសញ្ញាអង្គការសហប្រជាជាតិស្តីពី នីតិសមុទ្រ និងបញ្ហាផ្សេងៗ។

### ❈កិច្ចប្រជុំផ្ទៃក្នុងក្រុមសមាជិកាព្រឹទ្ធសភាចំនួន១លើក



នាថ្ងៃពុធ ទី២១ ខែមករា ឆ្នាំ២០២៦ លោកជំទាវ **មាន សំអាន** ប្រធានក្រុម បានដឹកនាំកិច្ចប្រជុំពិភាក្សាលើ៖

១-ផែនការចុះជួបប្រជុំជាមួយក្រុមប្រឹក្សាឃុំ សង្កាត់ជាស្ត្រី ដើម្បីឈ្វេងយល់អំពីវឌ្ឍនភាពការងារ ឆ្នាំ២០២៥ តម្រូវការការអនុវត្តគោលនយោបាយស្តីពីការលើកកម្ពស់សមភាពយេនឌ័រ ផែនការសកម្មភាពសម្រាប់ឆ្នាំ២០២៦ និងឆ្លុះបញ្ចាំងការអនុវត្តគោលនយោបាយអភិវឌ្ឍន៍ឃុំ សង្កាត់ ឆ្នាំ២០២២-២០២៧នៅភូមិភាគទី៨ (ខេត្តកំពង់ធំ ខេត្តព្រះវិហារ ខេត្តក្រចេះ ខេត្តស្ទឹងត្រែង ខេត្តរតនគិរី និងខេត្តមណ្ឌលគិរី)។

២-បញ្ហាផ្សេងៗ។

### ❈កិច្ចប្រជុំផ្ទៃក្នុងគណៈកម្មការទី៩ព្រឹទ្ធសភាចំនួន២លើក៖

ឯកឧត្តម **អ៊ុំ សារឹទ្ធ** ប្រធានគណៈកម្មការ បានដឹកនាំកិច្ចប្រជុំផ្ទៃក្នុងគណៈកម្មការដូចខាងក្រោម៖

-នាព្រឹកថ្ងៃទី៣០ ខែធ្នូ ឆ្នាំ២០២៥ ដើម្បីពិនិត្យសិក្សាលើ



សេចក្តីព្រាងច្បាប់ស្តីពី អាកាសចរណ៍ស៊ីវិល នៃព្រះរាជាណាចក្រកម្ពុជា។



-នាព្រឹកថ្ងៃទី៩ ខែមករា ឆ្នាំ២០២៦ ដើម្បីពិភាក្សាអំពីដំណើរបេសកកម្មរបស់គណៈកម្មការនៅចន្លោះសម័យប្រជុំលើកទី៤ និងលើកទី៥ព្រឹទ្ធសភា នីតិកាលទី៥ និងបញ្ហាផ្សេងៗ។

### ❈កិច្ចប្រជុំផ្ទៃក្នុងក្រុមសមាជិកព្រឹទ្ធសភា (ក្រុមទី៥) ចំនួន២លើក៖

ឯកឧត្តម **អ៊ុំ សារឹទ្ធ** ប្រធានក្រុម បានដឹកនាំកិច្ចប្រជុំដូចខាងក្រោម៖



-នារសៀលថ្ងៃទី៣០ ខែធ្នូ ឆ្នាំ២០២៥ នៅសាលប្រជុំគណៈកម្មការទី១០ព្រឹទ្ធសភា ដើម្បីពិនិត្យ ពិភាក្សានិងត្រៀមឱ្យយោបល់លើសេចក្តីព្រាងច្បាប់ស្តីពី៖

១-អាកាសចរណ៍ស៊ីវិល នៃព្រះរាជាណាចក្រកម្ពុជា។

២-ការអនុម័តយល់ព្រមលើកិច្ចព្រមព្រៀងគ្រប់ជ្រុងជ្រោយ ស្តីពី ការដឹកជញ្ជូនតាមផ្លូវអាកាសរវាងរដ្ឋសមាជិកសមាគមប្រជាជាតិអាស៊ីអាគ្នេយ៍និងសហភាពអឺរ៉ុប និងរដ្ឋសមាជិករបស់ខ្លួន។

៣-ការអនុម័តយល់ព្រមលើពិធីសារទី៣ ស្តីពីការពង្រីកសិទ្ធិហោះហើរទី៥រវាងភាគីចុះកិច្ចព្រមព្រៀង ក្រោមកិច្ចព្រមព្រៀងដឹកជញ្ជូនតាមផ្លូវអាកាសរវាងរដ្ឋាភិបាល នៃរដ្ឋសមាជិកសមាគមប្រជាជាតិអាស៊ីអាគ្នេយ៍ និងរដ្ឋាភិបាល នៃសាធារណរដ្ឋប្រជាមានិតចិន។

៤-ការអនុម័តយល់ព្រមលើពិធីសារអនុវត្តកញ្ចប់កិច្ចសន្យាទី១១និងទី១២ នៃសេវាកម្មដឹកជញ្ជូនតាមផ្លូវអាកាស ក្រោមកិច្ចព្រមព្រៀងក្របខ័ណ្ឌអាស៊ានស្តីពី សេវាកម្ម។



-នាព្រឹកថ្ងៃទី១៩ ខែមករា ឆ្នាំ២០២៦ នៅសាលប្រជុំគណៈកម្មការទី១០ព្រឹទ្ធសភា ដើម្បីពិនិត្យ ពិភាក្សានិងត្រៀមឱ្យយោបល់លើសេចក្តីព្រាងច្បាប់ស្តីពី៖

១-ការអនុម័តយល់ព្រមលើអនុសញ្ញាអង្គការសហប្រជាជាតិស្តីពី នីតិសមុទ្រ។

២-បញ្ហាផ្សេងៗ។

### ❋កិច្ចប្រជុំជាមួយតំណាងរាជរដ្ឋាភិបាល ចំនួន១លើក

នាព្រឹកថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២៥ ឯកឧត្តម **អ៊ុំ សារឹទ្ធ** ប្រធានគណៈកម្មការទី៩ព្រឹទ្ធសភា បានដឹកនាំកិច្ចប្រជុំរវាងគណៈកម្មការនានារបស់ព្រឹទ្ធសភា ជាមួយតំណាងរាជរដ្ឋាភិបាល ដឹកនាំដោយឯកឧត្តម **ម៉ៅ ហាវណ្ណាល់** រដ្ឋមន្ត្រីទទួលបន្ទុករដ្ឋលេខាធិការដ្ឋានអាកាសចរណ៍ស៊ីវិល ដើម្បីពិនិត្យសិក្សាលើសេចក្តីព្រាងច្បាប់ស្តីពី អាកាសចរណ៍ស៊ីវិលនៃព្រះរាជាណាចក្រកម្ពុជា នៅសាលប្រជុំពិសេស៣ វិមានព្រឹទ្ធសភា។



### ❋កិច្ចប្រជុំផ្ទៃក្នុងគណៈកម្មការទី១០ព្រឹទ្ធសភា ចំនួន១លើក



នាថ្ងៃទី១៩ ខែមករា ឆ្នាំ២០២៦ ឯកឧត្តម **ម៉ម ប៊ុននាង** ប្រធានគណៈកម្មការ បានដឹកនាំកិច្ចប្រជុំពិនិត្យសម្រេចលើសេចក្តីព្រាងរបាយការណ៍ស្តីពី លទ្ធផលការងារប្រចាំខែមករា ឆ្នាំ២០២៦ និងលើកទិសដៅការងារបន្ត។

### ❋កិច្ចប្រជុំផ្ទៃក្នុងក្រុមសមាជិកព្រឹទ្ធសភាប្រចាំភូមិភាគទី៥ ចំនួន១លើក



នាថ្ងៃទី៩ ខែមករា ឆ្នាំ២០២៦ ឯកឧត្តម **ឈួន ឆាម** ប្រធានស្តីទីក្រុម បានដឹកនាំកិច្ចប្រជុំពិនិត្យ ពិភាក្សាលើរបាយការណ៍ប្រចាំឆ្នាំ២០២៥ និងលើកទិសដៅអនុវត្តបន្ត ព្រមទាំងពិភាក្សាលើកម្មវិធីសំណេះសំណាលជាមួយក្រុមប្រឹក្សាឃុំ និងនាយប៉ុស្តិ៍នគរបាលឃុំនៃស្រុកបាទី ខេត្តតាកែវ និងបញ្ហាផ្សេងៗ៕

# សមាជិក សមាជិកាព្រឹទ្ធសភាបំពេញការងារនៅតាមបណ្ដាភូមិភាគទាំង៨



❋នាព្រឹកថ្ងៃអាទិត្យ ទី៤ ខែមករា ឆ្នាំ២០២៦ ឯកឧត្តម **យស ផានីត្ថា** ប្រធានគណៈកម្មការទី២ព្រឹទ្ធសភា បានអញ្ជើញនាំយកអំណោយជាសម្ភារៈ គ្រឿងឧបភោគ បរិភោគ និងថវិកាប្រគល់ជូនរដ្ឋបាលខេត្តព្រះវិហារ ជនភៀសសឹក និងវីរកងទ័ពកម្ពុជា នៅសាលាខេត្តព្រះវិហារ និងបានចែកអំណោយជូនជនភៀសសឹកចំនួន៥០០គ្រួសារ នៅវត្តគីឡូលេខ៨ ក្នុងខេត្តព្រះវិហារ។

❋ឯកឧត្តមបណ្ឌិត **ម៉ុង ឫទ្ធី** ប្រធានគណៈកម្មការទី៣ព្រឹទ្ធសភា បានអញ្ជើញ៖



-ជួបសំណេះសំណាល សួរសុខទុក្ខ និងនាំយកអំណោយចែកកុមារា កុមារី ភៀសសឹកមកពីឃុំអូរបីជាន់ ស្រុកអូរជ្រៅ ខេត្តបន្ទាយមានជ័យ និងនាំទស្សនាសួនសត្វ ជិះឡូរីកម្សាន្ត ដើម្បីបង្កបរិយាកាសរីករាយ និងជាការលើកទឹកចិត្តដល់ពួកគាត់ នៅឃុំសែនជ័យ ស្រុកសំរោងទង ខេត្តកំពង់ស្ពឺ នាថ្ងៃទី២៧-ទី២៨ ខែធ្នូ ឆ្នាំ២០២៥ និងថ្ងៃទី៩ ថ្ងៃទី១៧ ខែមករា ឆ្នាំ២០២៦។

-ដឹកនាំក្រុមការងារបច្ចេកទេសចុះមកពិនិត្យមើលសកម្មភាពក្រុមគ្រឿងចក្រស្ថាបនាគ្រឹះក្រោមផ្លូវថ្មីមួយខ្សែទៀត ប្រវែង២.៥០០ម៉ែត្រ ដោយចាក់ធម្មតាកម្រាស់១ម៉ែត្រ



ដីគ្រួសក្រហមកម្រាស់៥តឹក ក្នុងភូមិស្វាយជង្គុំ ឃុំស្គុះ ដែលតភ្ជាប់មកពីភូមិព្រៃស្បា ឃុំសែនដី មានប្រវែង៣.៥០០ម៉ែត្រនៅឃុំសែនដី ស្រុកសំរោងទង ខេត្តកំពង់ស្ពឺ នាព្រឹកថ្ងៃទី២៧ ខែធ្នូ ឆ្នាំ២០២៥។



-ដឹកនាំបុគ្គលិក កម្មករ រៀបចំវេចខ្ចប់សាច់ជ្រូកចំនួន ៨.២០០គីឡូក្រាម និងសាច់កែច្នៃផលិតដោយក្រុមសាច់ជ្រូកអស្វារ្យក្រោមឱវាទក្រុមហ៊ុន ម៉ុង ឫទ្ធីគ្រុប សម្រាប់យកទៅចែកជូនដល់វីរយុទ្ធជនជួរមុខ និងប្រជាពលរដ្ឋភៀសសឹកមួយចំនួន នាថ្ងៃទី២៩ ខែធ្នូ ឆ្នាំ២០២៥។



-ឧបត្ថម្ភបាយប្រអប់ចម្អិនដោយមិនចាំបាច់ប្រើប្រាស់ភ្លើងដើម្បីចម្អិនចំនួន១.០០០ប្រអប់ និងបាយមានម្ហូបស្រាប់ចំនួន៥.០០០ប្រអប់ សម្រាប់ត្រៀមចែកជូនវីរយុទ្ធជនការពារ

ទឹកដីនៅសមរភូមិមុខ នៅក្រុមហ៊ុនម៉ុង ឫទ្ធីគ្រុប រាជធានីភ្នំពេញ នាថ្ងៃទី៣០ ខែធ្នូ ឆ្នាំ២០២៥។



-រៀបចំចាត់ចែងក្រុមការងារដឹកជញ្ជូនមានបាយប្រអប់ រក្សាទុកបានយូរ និងសម្ភារៈមួយចំនួនទៀត សម្រាប់ប្រគល់ជូនវីរយុទ្ធជនជួរមុខ ព្រមទាំងវីរយុទ្ធជនដែលកំពុងសម្រាកព្យាបាលជំងឺ នាថ្ងៃទី៣០ ខែធ្នូ ឆ្នាំ២០២៥។



-ដឹកនាំក្រុមការងារផ្នែកបច្ចេកទេសសំណង់ ចុះពិនិត្យមើលសកម្មភាពក្រុមការងារគ្រឿងចក្រ ដែលកំពុងតែសម្រុកបើកការដ្ឋានផ្លូវមួយខ្សែថ្មី ដែលមានទទឹង១១ម៉ែត្រ និងបណ្តោយ៣៣.២៣០ម៉ែត្រ តភ្ជាប់មកពីភូមិសំរោងជើងភ្នំ ឃុំសែនដី ឆ្ពោះទៅភូមិដូនអាត់ ឃុំស្គុះ ស្រុកសំរោងទង ខេត្តកំពង់ស្ពឺ នាថ្ងៃទី២ និងថ្ងៃទី៩ ខែមករា ឆ្នាំ២០២៦។

-ចាត់ក្រុមការងារនាំយកអំណោយជាគ្រឿងឧបភោគបរិភោគ ខោអាវ តុក្កតា និងសម្ភារៈក្មេងៗ សម្រាប់ចែកជូនលោកគ្រូ អ្នកគ្រូ និងបុគ្គលិកពេទ្យ នៃមន្ទីរពេទ្យបង្អែក១៦មករា សរុបចំនួន២០២នាក់ ជូនដល់វីរកងទ័ព ដែលកំពុងសម្រាកព្យាបាលជំងឺ នៅមន្ទីរពេទ្យចំនួន១០៩នាក់ ព្រមទាំងកូនៗ និងគ្រួសារវីរកងទ័ព ជូនកងពលលេខ៩ នៅទិសមុំ៣ និងកងពលលេខ៧ នៅទិសភ្នំខ្មោច នៅមន្ទីរពេទ្យបង្អែក១៦មករា ខេត្តព្រះវិហារ នាថ្ងៃទី៧ ខែមករា ឆ្នាំ២០២៦។

-ឧបត្ថម្ភសាច់ជ្រូកចំនួន៨កេស ស្មើនឹង២៣៦គីឡូក្រាម រួមជាមួយសប្បុរសជនមួយចំនួនផ្សេងទៀត តាមរយៈ ភិក្ខុ-សច្ចភាណកោ **សែម សុនា** ព្រះចៅអធិការវត្តអង្គប្រីយ៍



បាននិមន្តនាំអំណោយទាំងនោះ សម្រាប់ឧបត្ថម្ភដល់វីរកងទ័ពដែលឈរជើងការពារទឹកដីនៅព្រំដែនទិសមុំបី ខេត្តព្រះវិហារ ចំនួន៨វរសេនាតូច នាថ្ងៃទី១២ ខែមករា ឆ្នាំ២០២៦។

-ដឹកនាំក្រុមការងារបច្ចេកទេស មកពិនិត្យសកម្មភាព



សាងសង់រោងចក្រផលិតជីធម្មជាតិ ដែលមានកម្លាំងផលិតបានប្រមាណជា១០០តោនក្នុងមួយថ្ងៃ នៅលើផ្ទៃដី៦៥.000 ម៉ែត្រក្រឡា រោងចក្រនេះចាប់ផ្តើមសាងសង់នៅដើមខែធ្នូ ឆ្នាំ២០២៥ និងអាចសាងសង់រួចរាល់ ព្រមទាំងចាប់ផ្តើមដំណើរការសាកល្បងនៅដើមខែកក្កដា ឆ្នាំ២០២៦ នៅភូមិស្វាយជង្គំ ឃុំស្គុះ ស្រុកសំរោងទង ខេត្តកំពង់ស្ពឺ នាថ្ងៃទី១៣ ខែមករា ឆ្នាំ២០២៦។

-ឧបត្ថម្ភថវិកាមួយចំនួនដល់លោកអនុសេនីយ៍ឯក **រស់ សារុន** អាយុ៥១ឆ្នាំ ជាមេបញ្ជាការផ្នែកសឹករងស្រុកឆែប ខេត្តព្រះវិហារ ដែលបានវះកាត់យកគ្រាប់កាំភ្លើងចេញពីដៃ នៅមន្ទីរពេទ្យ១៦មករា នៅខេត្តព្រះវិហារ បន្ទាប់ពីរងរបួសក្នុងសង្គ្រាមការពារទឹកដីតាំងពីថ្ងៃទី៩ ខែធ្នូ ឆ្នាំ២០២៥ ដល់ថ្ងៃទី១៣ ខែមករា ឆ្នាំ២០២៦។

-ជួបសំណេះសំណាលនិងសួរសុខទុក្ខប្រជាពលរដ្ឋ បុគ្គលិក កម្មករ កុមារា កុមារី ដែលរស់នៅក្នុងតំបន់អភិវឌ្ឍន៍



កែវផុស ប្រមាណជាង១០០នាក់ ព្រមទាំងបានជូនផ្លែឈើ និងអាវរងាដល់ពួកគាត់ នៅភូមិឫទ្ធី៥ និងភូមិឫទ្ធី៦ ឃុំកែវផុស ស្រុកស្ទឹងហាវ ខេត្តព្រះសីហនុ នារសៀលថ្ងៃទី១៦ ខែមករា ឆ្នាំ២០២៦។



-ឧបត្ថម្ភកានសម្រាប់ដាក់ទឹកដឹកតាមម៉ូតូចំណុះ២០លីត្រ ចំនួន១.០០០កាន តាមរយៈលោកជំទាវ **គាត កិច្ច** អនុប្រធានមន្ទីរពេទ្យបង្អែក១៦មករា ខេត្តព្រះវិហារ សម្រាប់ចែកជូនវីរយុទ្ធជនយកទៅប្រើប្រាស់នៅតាមបណ្តាលេណដ្ឋានប្រយុទ្ធ នាថ្ងៃទី១៦ ខែមករា ឆ្នាំ២០២៦។



-ចុះពិនិត្យមើលក្រុមការងារគ្រឿងចក្រ ដែលបាននិងកំពុងតែនាំគ្នាសម្រុកស្ថាបនាគ្រឹះក្រោមផ្លូវមួយខ្សែប្រវែង៣.៥០០ម៉ែត្រ ដែលតភ្ជាប់ពីភូមិសំរោងជើងភ្នំ ទៅដល់ភូមិមហាលំពាំង១ នៅភូមិសំរោងជើងភ្នំ ឃុំសែនជី ស្រុកសំរោងទង ខេត្តកំពង់ស្ពឺ នារសៀលថ្ងៃទី១៧ ខែមករា ឆ្នាំ២០២៦។



❈នាថ្ងៃទី២៣ ដល់ថ្ងៃទី២៥ ខែធ្នូ ឆ្នាំ២០២៥ គណៈកម្មការទី៨ព្រឹទ្ធសភា ដឹកនាំដោយលោកជំទាវ **មាន សំអាន** ប្រធានគណៈកម្មការ បានអញ្ជើញជួបសំណេះសំណាលសួរសុខទុក្ខ និងនាំយកស្បៀងចែកជូនជនភៀសសឹកចំនួន១.១៨០គ្រួសារ នៅមណ្ឌលសុវត្ថិភាពវត្តកំពង់សង្កែ ខេត្តព្រះវិហារ។

❈លោកជំទាវ **មាន សំអាន** ប្រធានគណៈកម្មការទី៨ព្រឹទ្ធសភា បានអញ្ជើញដឹកនាំក្រុមសមាជិកព្រឹទ្ធសភាប្រចាំភូមិភាគទី៦៖



-គោរពវិញ្ញាណក្ខន្ធលោកស្រី **គង់ សារឿន** អតីតប្រធានវីរនារីនៅអង្គភាពនារីចល័តដោះមីន នៅវត្តសំបួរ ក្នុងស្រុកស្វាយទាប ខេត្តស្វាយរៀង នាថ្ងៃទី៣០ ខែធ្នូ ឆ្នាំ២០២៥។



-គោរពវិញ្ញាណក្ខន្ធសពលោកវរសេនីយត្រី **ម៉ៅ កុសល្យ** ដែលបានពលីក្នុងសមរភូមិការពារបូរណភាពទឹកដីកម្ពុជា

នៅឃុំបាសាក់ ស្រុកស្វាយជ្រុំ ខេត្តស្វាយរៀង នាថ្ងៃទី៣០ ខែធ្នូ ឆ្នាំ២០២៥។

❈នាថ្ងៃទី២៨ ខែធ្នូ ឆ្នាំ២០២៥ ឯកឧត្តម **ឈួន ឡេង** អនុប្រធានគណៈកម្មការទី២ព្រឹទ្ធសភា បានអញ្ជើញចូលរួមក្នុងពិធីសំណេះសំណាល និងផ្តល់អំណោយជូនដល់ប្រជាពលរដ្ឋភៀសសឹក ព្រមទាំងគ្រួសារវីរយុទ្ធជន នៅវិទ្យាល័យស្មើសាមគ្គី ឃុំស្វាយភ្លោះ ស្រុកពាមជរ ខេត្តព្រៃវែង។



❈នាថ្ងៃទី១០ ខែមករា ឆ្នាំ២០២៦ ឯកឧត្តម **ឈួន ឆាម** អនុប្រធានគណៈកម្មការទី៣ព្រឹទ្ធសភា បានអញ្ជើញចូលរួមក្នុងពិធីសំណេះសំណាលនិងសួរសុខទុក្ខប្រជាពលរដ្ឋភៀសសឹក ចំនួន២០៨គ្រួសារ ដែលបានមកស្នាក់នៅក្នុងស្រុកគិរីវង់ ខេត្តតាកែវ។

❈ឯកឧត្តម **អោយ ខន** អនុប្រធានគណៈកម្មការទី៦ព្រឹទ្ធសភា បានអញ្ជើញ៖



-ចូលរួមពិធីបិទសន្និបាតបូកសរុបលទ្ធផលការងារឆ្នាំ២០២៥ និងលើកទិសដៅការងារឆ្នាំ២០២៦ របស់រដ្ឋបាលខេត្តកោះកុង ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់ឯកឧត្តមនាយឧត្តមសេនីយ៍ **ទៀ សីហា** ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងការពារជាតិ និងជាប្រធានក្រុមការងាររាជរដ្ឋាភិបាលចុះមូលដ្ឋានខេត្តកោះកុង នៅសាលមហោស្រពខេត្តកោះកុង នាព្រឹកថ្ងៃទី១៧ ខែមករា ឆ្នាំ២០២៦។

-ចូលរួមពិធីសំណេះសំណាលជាមួយសមាជិកសមាគមអតីតយុទ្ធជន និងនិវត្តជនកម្ពុជា ខេត្តកោះកុង នៅសាលមហោស្រពខេត្តកោះកុង នាព្រឹកថ្ងៃអាទិត្យ ទី១៨ ខែមករា ឆ្នាំ២០២៦។

❈នាថ្ងៃទី២៥ ខែធ្នូ ឆ្នាំ២០២៥ ឯកឧត្តម **ម៉ាន់ ឈឿន** អនុប្រធានគណៈកម្មការទី៧ព្រឹទ្ធសភា បានអញ្ជើញចូលរួមប្រជុំការងារស្តីពី សភាពការណ៍ទូទៅប្រចាំខែធ្នូនិងទិសដៅការងារបន្ត ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់សម្តេចវិបុលសេនាភក្តី **សាយ ឈុំ** ឧត្តមប្រឹក្សាផ្ទាល់ព្រះមហាក្សត្រ នៅសង្កាត់អូរបែកក្អម ខណ្ឌសែនសុខ រាជធានីភ្នំពេញ។

❈ឯកឧត្តម **ម៉ែន-ស៊ីផាន់** អនុប្រធានគណៈកម្មការទី៩ព្រឹទ្ធសភា និងឯកឧត្តមបណ្ឌិត **គឹម ឆា** លេខាធិការគណៈកម្មការទី៦ព្រឹទ្ធសភា បានអញ្ជើញ៖



-ចូលរួមគោរពវិញ្ញាណក្ខន្ធ និងបូជាសពលោកអនុសេនីយ៍ត្រី **ទូច តិរ័ត្ស** ជាវីរកងទ័ព នៃកងឯកភាពផ្នែកសឹករងជាំក្សាន្ត ដែលបានពលីជីវិតក្នុងបុព្វហេតុការពារទឹកដីក្នុងសមរភូមិមុខ នៅភូមិពោធិ៍បន្ទាយ ឃុំកណ្តៀងរាយ ស្រុកស្វាយទាប ខេត្តស្វាយរៀង នាថ្ងៃទី២៦ ខែធ្នូ ឆ្នាំ២០២៥ ។



-ជាអធិបតីក្នុងកម្មវិធីបើកដំណើរការថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់ ជំនាញរដ្ឋបាលសាធារណៈ និងបានធ្វើបាឋកថា ស្តីពី «សញ្ញាណនៃវិទ្យាសាស្ត្ររដ្ឋបាល» លើខ្លឹមសារយល់ដឹងអំពី

ព្រឹទ្ធសភា នៃព្រះរាជាណាចក្រកម្ពុជា កិច្ចការរដ្ឋបាល និងកិច្ច-ការនីតិកម្ម ដើម្បីផ្តល់ចំណេះដល់និស្សិតនូវជំនាញបន្ថែម ពីលើកម្មវិធីសិក្សានៅមហាវិទ្យាល័យសង្គមសាស្ត្រ នៅសាកលវិទ្យាល័យស្វាយរៀង នាថ្ងៃទី២៨ ខែធ្នូ ឆ្នាំ២០២៥។

❋ឯកឧត្តម **ម៉ែន-ស៊ីផាន់** អនុប្រធានគណៈកម្មការទី៩ ព្រឹទ្ធសភា បានអញ្ជើញ៖



-ជួបសំណេះសំណាលនិងសួរសុខទុក្ខអាណាព្យាបាល និងក្មេងកៀសសឹកចំនួន៦រូប ដែលកៀសខ្លួនពីខេត្តបន្ទាយ-មានជ័យមកស្នាក់នៅក្នុងភូមិព្រះពន្លា ព្រមទាំងបានឧបត្ថម្ភសម្ភារៈសិក្សាដល់ក្មេងកៀសសឹកទាំង៦រូប និងថវិកាមួយចំនួន នៅឃុំព្រះពន្លា ស្រុកកំពង់រោទិ៍ ខេត្តស្វាយរៀង នារសៀលថ្ងៃទី២៩ ខែធ្នូ ឆ្នាំ២០២៥។

-ជាគណៈអធិបតីក្នុងកិច្ចប្រជុំបូកសរុបលទ្ធផលការងារប្រចាំឆ្នាំ២០២៥និងទិសដៅអនុវត្តបន្តឆ្នាំ២០២៦ នៅឃុំព្រះពន្លា ស្រុកកំពង់រោទិ៍ ខេត្តស្វាយរៀង នាថ្ងៃទី១៧ ខែមករា ឆ្នាំ២០២៦។

❋ឯកឧត្តម **គិន ណែត** លេខាធិការគណៈកម្មការទី២ ព្រឹទ្ធសភា បានអញ្ជើញ៖

-ជាអធិបតីក្នុងកិច្ចប្រជុំបូកសរុបលទ្ធផលការងាររបស់ឃុំ និងបានឧបត្ថម្ភថវិកាមួយចំនួន នៅឃុំក្រពុំឈូក ស្រុកកោះអណ្តែត ខេត្តតាកែវ នាព្រឹកថ្ងៃទី២៨ ខែធ្នូ ឆ្នាំ២០២៥។



-ចូលរួមក្នុងពិធីជួបសំណេះសំណាលនិងចែកអំណោយជូនក្រុមគ្រួសាររីកងទ័ពជួរមុខចំនួន៩០គ្រួសារ ក្នុងមួយគ្រួសារទទួលបាន អង្ករ២០គីឡូក្រាម មី១កេស ត្រីខ១០កំប៉ុង ទឹកត្រី២ដប ទឹកស៊ីអ៊ីវ២ដប និងថវិកាមួយចំនួន នៅស្រុកកោះអណ្តែត ខេត្តតាកែវ នាព្រឹកថ្ងៃទី៣០ ខែធ្នូ ឆ្នាំ២០២៥។

❋ឯកឧត្តមបណ្ឌិត **គឹម ឆា** លេខាធិការគណៈកម្មការទី៦ព្រឹទ្ធសភា បានអញ្ជើញ៖



-ចុះសួរសុខទុក្ខដល់គ្រួសាររីកងទ័ព លោកអនុសេនីយ៍ត្រី **ទូច តិរ័ត្ន** នៅភូមិកណ្តៀងរាយ ឃុំកណ្តៀងរាយ ស្រុកស្វាយទៀប ខេត្តស្វាយរៀង និងលោកវរសេនីយ៍ត្រី **ម៉ៅ កុសល្យ** នៅភូមិព្រៃបាសាក់ ឃុំបាសាក់ ស្រុកស្វាយជ្រំ ខេត្តស្វាយរៀង នាថ្ងៃទី៦ ខែមករា ឆ្នាំ២០២៦។



-អមដំណើរសម្តេចកិត្តិសង្គហបណ្ឌិត **ម៉ែន សំអន** ឧត្តមប្រឹក្សាផ្ទាល់ព្រះមហាក្សត្រ នៃព្រះរាជាណាចក្រកម្ពុជា ជួបសំណេះសំណាលនិងចែកអំណោយជូនដល់ជនភៀសសឹក ព្រមទាំងក្រុមគ្រួសាររីកងទ័ព និងវីរនគរបាល ចំនួន៤៦៧គ្រួសារ នៅស្រុករមាសហែក ខេត្តស្វាយរៀង នាព្រឹកថ្ងៃទី៨ ខែមករា ឆ្នាំ២០២៦។

-ជួបសំណេះសំណាលសួរសុខទុក្ខក្រុមគ្រួសារកងទ័ពជួរមុខ លោក **នៃ សុវត្ថិ** ដែលត្រូវកងទ័ពថៃចាប់ខ្លួន



និងទើបបានដោះលែងមកប្រទេសកម្ពុជាវិញ និងបានសួរសុខទុក្ខភរិយារបស់លោកដែលបានសម្រាលបុត្រ ព្រមទាំងបានឧបត្ថម្ភថវិកា និងសម្ភារៈមួយចំនួនជូនដល់គ្រួសារវីរកងទ័ព និងអ្នកចូលរួម នៅភូមិព្រៃត្រុំ ឃុំញរ ស្រុកកំពង់រោទិ៍ ខេត្តស្វាយរៀង នាថ្ងៃទី១១ ខែមករា ឆ្នាំ២០២៦។

❈ឯកឧត្តម **ឈើយ ចាន់ណា** លេខាធិការគណៈកម្មការទី៧ព្រឹទ្ធសភា បានអញ្ជើញ៖



-នាំយកអំណោយម៉ាស៊ីនភ្លើងម៉ាក TAKASHIMA GS 12KVA Gold ចំនួន៥គ្រឿង របស់ឯកឧត្តម **កែ គឹមយ៉ាន** ឧត្តមប្រឹក្សាផ្ទាល់ព្រះមហាក្សត្រ ជូនដល់វីរកងទ័ពជួរមុខទិសសមរភូមិខេត្តបន្ទាយមានជ័យ នាថ្ងៃទី២៥ ខែធ្នូ ឆ្នាំ២០២៥។



-នាំយកអំណោយសប្បុរសធម៌របស់ក្រុមហ៊ុនចំនួន៧ ជាគ្រឿងឧបភោគបរិភោគ ជូនដល់ប្រជាពលរដ្ឋភៀសសឹក ចំនួន៨៧០គ្រួសារ កុមារចំនួន៧៣៨នាក់ និងវីរកងទ័ពជួរមុខទិសខេត្តបន្ទាយមានជ័យ នៅមណ្ឌលជនភៀសសឹកអនុវិទ្យាល័យសារង្គ ស្រុកស្វាយចេក ខេត្តបន្ទាយមានជ័យ នាថ្ងៃទី២៨ ខែធ្នូ ឆ្នាំ២០២៥។



-នាំយកអំណោយសប្បុរសធម៌របស់អ្នកភូមិបុរីអ័រគីដេទី២ រាជធានីភ្នំពេញនិងសប្បុរសជននានា ជាគ្រឿងឧបភោគបរិភោគ ជូនដល់វីរកងទ័ពជួរមុខអង្គភាពកាំភ្លើងធំអគ្គបញ្ជាការទិសសមរភូមិខេត្តបន្ទាយមានជ័យនិងវីរកងទ័ពជួរមុខអង្គភាពរថក្រោះ អគ្គបញ្ជាការប្រចាំទិសភូមិភាគទី៥ នាថ្ងៃទី១ ខែមករា ឆ្នាំ២០២៦។



-នាំយកអំណោយរបស់សប្បុរសជននានា ក្នុងប្រទេសនិងក្រៅប្រទេស តាមរយៈអង្គការកុមារមេគង្គជាគ្រឿងឧបភោគបរិភោគ ជូនប្រជាការពារជាអតីតយុទ្ធជនពិការនិងប្រជាពលរដ្ឋចំនួន១០០គ្រួសារ ដែលពុំបានចាកចេញពីផ្ទះសំបែងពេលផ្ទុះសង្គ្រាមនៅតាមបណ្តោយព្រំដែនកម្ពុជា-ថៃ នៅភូមិតេជោ និងភូមិចំការគ ស្រុកស្វាយចេក ខេត្តបន្ទាយមានជ័យ នាថ្ងៃទី២ ខែមករា ឆ្នាំ២០២៦។

❈លោកជំទាវ **ឃួន ឃុនឌី** លេខាធិការគណៈកម្មការទី៨ព្រឹទ្ធសភា បានអញ្ជើញ៖

-ចុះសួរសុខទុក្ខនិងលើកទឹកចិត្តដល់បងប្អូនវីរកងទ័ពសមរភូមិជួរមុខដែលកំពុងសម្រាកព្យាបាលជំងឺនៅមន្ទីរពេទ្យ



បង្អែកខេត្តកំពង់ធំ និងបាននាំយកគ្រឿងឧបភោគ បរិភោគ ប្រគល់ជូនមេបញ្ជាការតំបន់ប្រតិបត្តិការសឹករងខេត្តកំពង់ធំ នៅខេត្តកំពង់ធំ នាព្រឹកថ្ងៃទី២៨ ខែធ្នូ ឆ្នាំ២០២៥។

-ចុះសួរសុខទុក្ខនិងនាំយកគ្រឿងឧបភោគ បរិភោគ សម្ភារៈប្រើប្រាស់ និងថវិកាជូនលោកឧត្តមនីយ៍ទោ **ថនស៊ី សត្ថជា** ឈរជើងនៅទិសព្រះវិហារ ដែលកំពុងសម្រាកព្យាបាលជំងឺនៅគេហដ្ឋាន ក្នុងភូមិក្រចាប់ សង្កាត់អាចារ្យលាក់ ក្រុងស្ទឹង-សែន ខេត្តកំពង់ធំ នារសៀលថ្ងៃទី២៨ ខែធ្នូ ឆ្នាំ២០២៥។



-ចុះសួរសុខទុក្ខនិងចែកអំណោយដល់គ្រួសារកៀសសឹក ចំនួន៦៤៨គ្រួសារ នៅវត្តឧទុម្ពរ ឃុំស្រឡៅ ស្រុកតាំងគោក ខេត្តកំពង់ធំ នារសៀលថ្ងៃទី៣០ ខែធ្នូ ឆ្នាំ២០២៥។

-ជួបសំណេះសំណាលជាមួយនាយកសាលា ក្រុមប្រឹក្សាឃុំ នាយប៉ុស្តិ៍នគរបាលឃុំ ស្មៀនឃុំ មេភូមិ អនុភូមិ និងសមាជិកភូមិ នៅឃុំសាន់គរ ស្រុកកំពង់ស្វាយ ខេត្តកំពង់ធំ នាព្រឹកថ្ងៃទី៧ ខែមករា ឆ្នាំ២០២៦។

-គោរពវិញ្ញាណក្ខន្ធសព លោក **ហេង ម៉ៅ** អនុប្រធានភូមិអូរសោលា ឃុំកំពង់ស្វាយ ស្រុកកំពង់ស្វាយ ខេត្តកំពង់ធំ នារសៀលថ្ងៃទី១០ ខែមករា ឆ្នាំ២០២៦។

❈នាថ្ងៃទី២ ខែមករា ឆ្នាំ២០២៦ ឯកឧត្តម **ឡាន់ ឆន** លេខាធិការគណៈកម្មការទី១០ព្រឹទ្ធសភា បានអញ្ជើញជា



តំណាងដ៏ខ្ពង់ខ្ពស់របស់ឯកឧត្តម **អ៊ុច បូររិទ្ធ** អនុប្រធានទី១ព្រឹទ្ធសភា ដឹកនាំក្រុមសមាជិកព្រឹទ្ធសភាប្រចាំភូមិភាគទី២ គោរពវិញ្ញាណក្ខន្ធសពលោកវរសេនីយ៍ទោ **យ៉េន ថា** និងលោកនាយចំណង់ **សឿន សាលី** វីរយុទ្ធជនដែលបានពលីជីវិតក្នុងសមរភូមិប្រយុទ្ធជាមួយការឈ្លានពានរបស់ថៃ នៅស្រុកកងមាសនិងស្រុកព្រៃឈរ ខេត្តកំពង់ចាម។

❈ឯកឧត្តម **លី សារី** សមាជិកគណៈកម្មការទី១ព្រឹទ្ធសភា បានអញ្ជើញ៖



-ចុះសួរសុខទុក្ខនិងគោរពវិញ្ញាណក្ខន្ធសពប្រជាពលរដ្ឋ នៅសង្កាត់ត្រើយកោះ ក្រុងកំពត ខេត្តកំពត និងនៅសង្កាត់ព្រៃធំ ក្រុងកែប ខេត្តកែប នាថ្ងៃទី២៥និងថ្ងៃទី២៩ ខែធ្នូ ឆ្នាំ២០២៥។



-ចុះសួរសុខទុក្ខវីរកងទ័ពជួរមុខចំនួន៦នាក់ ដែលបានមកសម្រាកព្យាបាលនៅមន្ទីរពេទ្យបង្អែកខេត្តកំពតនិងបាន

ឧបត្ថម្ភថវិកាមួយចំនួនជូនវីរកងទ័ព នាថ្ងៃទី២៦ ខែធ្នូ ឆ្នាំ២០២៥។



-ចុះសួរសុខទុក្ខបងប្អូនប្រជាពលរដ្ឋនិងគោរពវិញ្ញាណក្ខន្ធសពប្រជាពលរដ្ឋភៀសសឹកមកពីខេត្តកោះកុង ដែលបានទទួលមរណភាពដោយរោគាពាធ នៅភូមិកំពង់កណ្ដាល ឃុំជុំគៀល ស្រុកទឹកឈូ ខេត្តកំពត នាល្ងាចថ្ងៃទី២៧ ខែធ្នូ ឆ្នាំ២០២៥។



-ចូលរួមប្រគល់និងទទួលអំណោយពីសប្បុរសជននានា ក្នុងភូមិម៉ាក់ប្រាង្គ ឃុំកំពង់ក្រែង ស្រុកទឹកឈូ ខេត្តកំពត ប្រគល់ជូនគណៈអ៊ីមុាំខេត្តកំពត ដើម្បីរៀបចំចាត់ចែងផ្ញើជូនថ្នាក់ដឹកនាំផ្ដល់ជូនជនភៀសសឹកនិងវីរកងទ័ព នាព្រឹកថ្ងៃទី២៨ ខែធ្នូ ឆ្នាំ២០២៥។



-ចូលរួមជាអធិបតីក្នុងពិធីប្រកាសសេចក្ដីសម្រេចស្ដីពីការតែងតាំងសមាសភាពគណៈអ៊ីមុាំម៉ាស្ជិតភូមិតាដិប (ចាមខាងជើង) សង្កាត់អណ្ដូងខ្មែរ ក្រុងកំពត ខេត្តកំពត នាថ្ងៃទី១៨ ខែមករា ឆ្នាំ ២០២៦។

❋នាថ្ងៃទី១ ខែមករា ឆ្នាំ២០២៦ ឯកឧត្តម **ញ៉ែម សុខ** សមាជិកគណៈកម្មការទី២ព្រឹទ្ធសភា បានអញ្ជើញគោរពវិញ្ញាណក្ខន្ធសព លោកវរសេនីយ៍ទោ **សាខន សារឹម** ដែលបានពលីជីវិតក្នុងសមរភូមិពេលប្រយុទ្ធតតាំងជាមួយពួកទាហានថៃឈ្លានពាននៅព្រំដែនកម្ពុជា-ថៃ នៅស្រុកក្រគរ ខេត្តពោធិ៍សាត់។

❋ព្រះអង្គម្ចាស់ **ស៊ីសុវត្ថិ ធម្មិកោ** សមាជិកគណៈ-កម្មការទី៣ព្រឹទ្ធសភា បានយាង៖

-ចុះសួរសុខទុក្ខ និងចែកអំណោយជូនបងប្អូនប្រជាពល-រដ្ឋភៀសសឹកចំនួន១៤៨គ្រួសារ កំពុងស្នាក់អាស្រ័យនៅវត្តបាលីដំរីក្រាប នៅឃុំត្បែង ស្រុកបន្ទាយស្រី ខេត្តសៀមរាប នាព្រឹកថ្ងៃទី២៥ ខែធ្នូ ឆ្នាំ២០២៥។

-ជួបសំណេះសំណាល និងសួរសុខទុក្ខប្រជាពលរដ្ឋ ព្រមទាំងពិនិត្យមើលគម្រោងសហគមន៍ដាំបន្លែលើដីនិងលើទឹក នៅភូមិបង្កោង ឃុំអំពិល ស្រុកប្រាសាទបាគង ព្រមទាំងរៀបចំស្រះចិញ្ចឹមត្រី នៅភូមិស្បែកកាំភ្លើង ឃុំចាន់ស ស្រុកសូទ្រនិគម ខេត្តសៀមរាប នាថ្ងៃទី២៨ ខែធ្នូ ឆ្នាំ២០២៥។

❋ព្រះអង្គម្ចាស់ **ស៊ីសុវត្ថិ ធម្មិកោ** សមាជិកគណៈ-កម្មការទី៣ព្រឹទ្ធសភា និងឯកឧត្តម **សត ណាឌី** សមាជិកគណៈកម្មការទី៤ព្រឹទ្ធសភា បានយាង/អញ្ជើញនាំយកព្រះរាជអំណោយដ៏ថ្លៃថ្លារបស់សម្ដេចព្រះមហាក្សត្រី ព្រះរាជមាតាជាតិខ្មែរ ចែកជូនគ្រួសារភៀសសឹក កំពុងស្នាក់នៅមណ្ឌលសុវត្ថិភាព ដើម្បីជួយសម្រួលក្នុងការដោះស្រាយ ជីវភាពប្រចាំថ្ងៃ នៅមណ្ឌលសុវត្ថិភាពវត្តអធ្វា សង្កាត់សៀមរាប ក្រុងសៀមរាប ខេត្តសៀមរាប នាថ្ងៃទី៣០ ខែធ្នូ ឆ្នាំ២០២៥។



❈នារសៀលថ្ងៃទី២ ខែមករា ឆ្នាំ២០២៦ លោកជំទាវ **ភេង សៅវ៉ែន** សមាជិកាគណៈកម្មការទី៣ព្រឹទ្ធសភា បានអញ្ជើញចុះពិនិត្យវឌ្ឍនភាព នៃការជីកស្តារស្រះទឹកទន្លេនាម ដែលមានទំហំបណ្តោយប្រវែង២១០ម៉ែត្រ ទទឹងប្រវែង ១៨០ម៉ែត្រ និងជម្រៅ៧ម៉ែត្រ នៅឃុំចំប៉ី ស្រុកអង្គរជ័យ ខេត្តកំពត។




❈នាព្រឹកថ្ងៃអង្គារ ទី១៣ ខែមករា ឆ្នាំ២០២៦ ឯកឧត្តម **សាយ បូរិន** សមាជិកគណៈកម្មការទី៥ព្រឹទ្ធសភា ឯកឧត្តម **អ៊ឹង លាងហ៊ួ** សមាជិកគណៈកម្មការទី៧ព្រឹទ្ធសភា និង លោកជំទាវ **ថាក់ ឡានី** សមាជិកាព្រឹទ្ធសភា បានអញ្ជើញជួបសំណេះសំណាលជាមួយក្រុមប្រឹក្សាឃុំពានី ដើម្បីឈ្វេង-យល់អំពីវឌ្ឍនភាពការងារ និងបញ្ហាប្រឈម សំណូមពររបស់ឃុំ និងជួយពង្រឹងការអនុវត្តតួនាទីរបស់ក្រុមប្រឹក្សាឃុំ នៅសាលាឃុំពានី ស្រុកកំពង់ត្រឡាច ខេត្តកំពង់ឆ្នាំង។

❈ឯកឧត្តម **ខៃ៉ត ចន្ថាទី** សមាជិកគណៈកម្មការទី៥ព្រឹទ្ធសភា បានអញ្ជើញ៖



-ចូលរួមជាកិត្តិយសក្នុងពិធីចម្រើនព្រះបរិត្ត ឡើងអគារទីស្នាក់ការថ្មីមន្ទីរសេដ្ឋកិច្ចនិងហិរញ្ញវត្ថុរាជធានីភ្នំពេញ នៅភូមិព្រែករាំង សង្កាត់ព្រែកតាសេក ខណ្ឌជ្រោយចង្វារ រាជធានីភ្នំពេញ នាព្រឹកថ្ងៃទី២៩ ខែធ្នូ ឆ្នាំ២០២៥ ដែលដីផ្តល់ដោយសាលារាជធានីភ្នំពេញនិងការសាងសង់អគារនេះ ជាថវិការបស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ។

-ចូលរួមគោរពវិញ្ញាណក្ខន្ធឯកឧត្តម **ល័ស រី** ទីប្រឹក្សាព្រឹទ្ធសភា នៅសង្កាត់ឃ្មួញ ខណ្ឌសែនសុខ រាជធានីភ្នំពេញ នារសៀលថ្ងៃទី២៩ ខែធ្នូ ឆ្នាំ២០២៥។

❈ឯកឧត្តម **អ៊ឹង លាងហ៊ួ** សមាជិកគណៈកម្មការទី៧ព្រឹទ្ធសភា បានអញ្ជើញ៖

-អមដំណើរឯកឧត្តមបណ្ឌិតសភាចារ្យ **អ៊ុក រ៉ាប៊ុន** ទេសរដ្ឋមន្ត្រី នាំយកអំណោយចែកជូនគ្រួសារកងទ័ពសមរ-ភូមិជួរមុខ ប្រជាពលរដ្ឋភៀសសឹក និងប្រជាពលរដ្ឋមានជីវភាពខ្វះខាត ចំនួន១៥០គ្រួសារ មកពីឃុំព្រៃមូល និងឃុំជើងគ្រាវ នៅវត្តប្រាសាទស្តាំ ភូមិព្រៃក្រោល ឃុំព្រៃមូល ស្រុករលាប្អៀរ ខេត្តកំពង់ឆ្នាំង នាថ្ងៃទី៤ ខែមករា ឆ្នាំ២០២៦។

-ចូលរួមសន្និបាតបូកសរុបលទ្ធផលការងារប្រចាំឆ្នាំ២០២៥ និងលើកទិសដៅបន្តឆ្នាំ២០២៦ របស់រដ្ឋបាលខេត្តកំពង់ឆ្នាំង ក្រោមអធិបតីភាពឯកឧត្តមបណ្ឌិតសភាចារ្យ **អ៊ុក រ៉ាប៊ុន** ទេសរដ្ឋមន្ត្រី នៅសាលាខេត្តកំពង់ឆ្នាំង នាថ្ងៃទី១០ ខែមករា ឆ្នាំ២០២៦។

-ជួបសំណេះសំណាលនិងសួរសុខទុក្ខក្រុមប្រឹក្សាស្រុក គណៈអភិបាលស្រុក ព្រមទាំងនាំយកគ្រឿងឧបភោគបរិភោគ និងថវិកាមួយចំនួនជូនដល់គ្រួសារវីរកងទ័ព និងគ្រួសារភៀសសឹកចំនួន១៥គ្រួសារ តាមបណ្តោយព្រំដែនកម្ពុជា-ថៃ នៅសាលាឃុំជលសា ស្រុកជលគីរី ខេត្តកំពង់ឆ្នាំង នាថ្ងៃទី១៧ ខែមករា ឆ្នាំ២០២៦។

-ចូលរួមពិធីប្រកាសដាក់ឱ្យអនុវត្តសាកល្បងលើការកែលម្អរថយន្តដឹកជញ្ជូនកម្មករនិយោជិតឱ្យកាន់តែមានផាសុកភាព សុវត្ថិភាព និងត្រួតពិនិត្យលក្ខណៈបច្ចេកទេសរថយន្តដឹកជញ្ជូនកម្មករនិយោជិត ក្រោមអធិបតីភាពឯកឧត្តម **ហេង សួរ** រដ្ឋមន្ត្រីក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ និងឯកឧត្តម **ប៉េង ពោធិ៍នា** រដ្ឋមន្ត្រីក្រសួងសាធារណការ និងដឹកជញ្ជូន ស្ថិតនៅភូមិជន្លាត់ដៃ ឃុំស្វាយ ស្រុកសាមគ្គី-មានជ័យ ខេត្តកំពង់ឆ្នាំង នាថ្ងៃទី២០ ខែមករា ឆ្នាំ២០២៦៕

# សមាជិក សមាជិកាព្រឹទ្ធសភាចូលរួមក្នុងពិធីផ្សេងៗ



❈នារសៀលថ្ងៃទី២០ ខែមករា ឆ្នាំ២០២៦ ឯកឧត្តមបណ្ឌិត **ម៉ុង ឫទ្ធី** ប្រធានគណៈកម្មការទី៣ព្រឹទ្ធសភា បានអញ្ជើញចូលរួមក្នុងពិធីបុណ្យសពលោក **ប្រាក់ ម៊ុនម៉េង** ឪពុកបង្កើតរបស់លោក **ម៉េង ថារ័ត្ន** ប្រធានការិយាល័យអមក្រុមភូមិភាគទី៧ នៅបុរីពិភពថ្មីចំការដូង។



❈នារសៀលថ្ងៃសុក្រ ទី២៦ ខែធ្នូ ឆ្នាំ២០២៥ ឯកឧត្តមបណ្ឌិត **ម៉ុង ឫទ្ធី** ប្រធានគណៈកម្មការទី៣ព្រឹទ្ធសភា និងលោកជំទាវបណ្ឌិត **អ៊ុក ម៉ាលី** សមាជិកាគណៈកម្មការទី២ព្រឹទ្ធសភា បានអញ្ជើញចូលរួមក្នុងកិច្ចប្រជុំប្រចាំឆ្នាំលើកទី៣ របស់គណៈកម្មាធិការកណ្តាលកាកបាទក្រហមកម្ពុជា អាណត្តិទី៧ ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់សម្តេចកិត្តិព្រឹទ្ធបណ្ឌិត **ប៊ុន រ៉ានី ហ៊ុនសែន** ប្រធានកាកបាទក្រហមកម្ពុជា នៅទីស្នាក់ការកណ្តាលកាកបាទក្រហមកម្ពុជា។

❈នាព្រឹកថ្ងៃទី៧ ខែមករា ឆ្នាំ២០២៦ លោកជំទាវបណ្ឌិត **ចាន់ សុទ្ធាវី** ប្រធានគណៈកម្មការទី៦ព្រឹទ្ធសភា បានអញ្ជើញជាកិត្តិយសក្នុងពិធីចម្រើនព្រះបរិត្តពុទ្ធជ័យមង្គលឡើងអគារទីស្តីការក្រសួងយុត្តិធម៌ ក្រោមអធិបតីភាពឯកឧត្តម **កើត រិទ្ធ** ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងយុត្តិធម៌ និងលោកជំទាវ។





❈នាព្រឹកថ្ងៃទី១៦ ខែមករា ឆ្នាំ២០២៦ លោកជំទាវ **មាន សំអាន** ប្រធានគណៈកម្មការទី៨ព្រឹទ្ធសភា បានអញ្ជើញចុះសួរសុខទុក្ខលោកស្រី **គង់ សារីយ៉ា** អតីតនាយិកាសាខាកាកបាទក្រហមកម្ពុជាខេត្តកណ្តាល កំពុងសម្រាក ព្យាបាលជំងឺ នៅមន្ទីរពេទ្យកាល់ម៉ែត្រ រាជធានីភ្នំពេញ។



❈នាព្រឹកថ្ងៃទី១៦ ខែមករា ឆ្នាំ២០២៦ លោកជំទាវ **មាន សំអាន** ប្រធាននិងលោកជំទាវ **ឃួន ឃុនឌី** លេខាធិការគណៈកម្មការទី៨ព្រឹទ្ធសភា បានអញ្ជើញចុះសួរសុខទុក្ខលោកជំទាវកិត្តិនីតិកោសលបណ្ឌិត **ឌី មូរ៉ាស៊ី** ទីប្រឹក្សាសម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** ប្រធានព្រឹទ្ធសភា នៅគេហដ្ឋាន សង្កាត់បឹងកេងកង ខណ្ឌចំការមន

រាជធានីភ្នំពេញ។




❈នាព្រឹកថ្ងៃទី១៧ ខែមករា ឆ្នាំ២០២៦ ឯកឧត្តម **ម៉ម ប៊ុននាង** ប្រធានគណៈកម្មការទី១០ព្រឹទ្ធសភា បានអញ្ជើញទទួលអំណោយមនុស្សធម៌លើកទី១៦ របស់មូលនិធិចែករំលែកសង្គ្រោះជីវិតសកល នៃសាធារណរដ្ឋកូរ៉េ រួមមាន៖ ឱសថ សម្ភារៈវេជ្ជសាស្ត្រ និងសម្ភារៈប្រើប្រាស់ប្រចាំថ្ងៃ នៅវិមានព្រឹទ្ធសភា។



❈នាថ្ងៃទី៥ ខែមករា ឆ្នាំ២០២៦ ឯកឧត្តម **ម៉ាន់ ឈឿន** អនុប្រធាន ឯកឧត្តម **ឈើយ ចាន់ណា** លេខាធិការ និង ឯកឧត្តម **អ៊ឹង លាងហ៊ួ** សមាជិកគណៈកម្មការទី៧ព្រឹទ្ធសភា បានអញ្ជើញសួរសុខទុក្ខឯកឧត្តម **ឈិត សុខុន** ប្រធានគណៈកម្មការទី៧ព្រឹទ្ធសភា ដែលកំពុងសម្រាកថែទាំសុខភាព នៅមន្ទីរពេទ្យជប៉ុនសាន់រ៉ាយស៍ រាជធានីភ្នំពេញ។

❈លោកជំទាវបណ្ឌិត **អ៊ុក ម៉ាលី** សមាជិកាគណៈកម្មការទី២ព្រឹទ្ធសភា បានអញ្ជើញ៖



-ជាតំណាងដ៏ខ្ពង់ខ្ពស់សម្តេចកិត្តិព្រឹទ្ធបណ្ឌិត **ប៊ុន រ៉ានី ហ៊ុនសែន** ប្រធានកាកបាទក្រហមកម្ពុជា ចុះសួរសុខទុក្ខ និងនាំយកនូវអំណោយមនុស្សធម៌ ព្រមទាំងថវិកាមួយចំនួនជូនដល់វីរយុទ្ធជនដែលរងរបួសកំពុងសម្រាកព្យាបាល នៅមន្ទីរពេទ្យមិត្តភាពខ្មែរ-សូវៀត និងមន្ទីរពេទ្យមិត្តភាពកម្ពុជា-ចិន ព្រះកុសុមៈ នៅរាជធានីភ្នំពេញ នាថ្ងៃទី២៨ ខែធ្នូ ឆ្នាំ២០២៥។



-អមដំណើរសម្តេចកិត្តិព្រឹទ្ធបណ្ឌិត **ប៊ុន រ៉ានី ហ៊ុនសែន** ប្រធានកាកបាទក្រហមកម្ពុជា ចូលរួមរំលែកទុក្ខនិងនាំយកគ្រឿងឧបភោគ បរិភោគ ព្រមទាំងថវិកាមួយចំនួនជូនក្រុមគ្រួសារសព វរសេនីយ៍ទោ **ចាន់ សុវត្ថា** ដែលបានពលីក្នុងសមរភូមិ ហើយបច្ចុប្បន្នក្រុមគ្រួសារសពកំពុងស្នាក់នៅក្នុងខេត្តពោធិ៍សាត់ នាព្រឹកថ្ងៃទី២៩ ខែធ្នូឆ្នាំ២០២៥។



-អមដំណើរសម្តេចកិត្តិព្រឹទ្ធបណ្ឌិត **ប៊ុន រ៉ានី ហ៊ុនសែន** ប្រធានកាកបាទក្រហមកម្ពុជា ចុះសួរសុខទុក្ខ និងនាំយកអំណោយមនុស្សធម៌ជូនវីរយុទ្ធជនការពារបូរណភាពទឹកដីដ៏អង់អាចក្លាហាន ដែលរងរបួសនិងពុលផ្សែងក្នុងសមរភូមិ ដែលកំពុងសម្រាកព្យាបាលនៅមន្ទីរពេទ្យបង្អែកខេត្តពោធិ៍សាត់ នាព្រឹកថ្ងៃទី២៩ ខែធ្នូ ឆ្នាំ២០២៥។

-អមដំណើរសម្តេចកិត្តិព្រឹទ្ធបណ្ឌិត **ប៊ុន រ៉ានី ហ៊ុនសែន** ប្រធានកាកបាទក្រហមកម្ពុជា រៀបចំថ្វាយទៀន ធូប ផ្កាភ្ញី និងគ្រឿងរណ្តាប់បូជាជូនទេពឧកញ៉ា **ឃ្លាំង មឿង** និង

ជំទាវ **ខាន់ ខៀវ** ទៅតាមគន្លងព្រះពុទ្ធសាសនា និង ព្រហ្មញ្ញសាសនា បន់ស្រន់សុំសេចក្តីសុខ សេចក្តីចម្រើន និងសុខសន្តិភាពជូនជាតិមាតុភូមិកម្ពុជា នៅបូជនីយដ្ឋាន ទេពឧកញ៉ា ស្រុកបាកាន ខេត្តពោធិ៍សាត់ នារសៀល ថ្ងៃទី២៩ ខែធ្នូ ឆ្នាំ២០២៥។



-ចូលរួមក្នុងពិធីប្រគល់-ទទួលថវិកាចំនួន១.០០៥.០០០ ដុល្លារអាម៉េរិក និងទឹកបរិសុទ្ធ៥០០កេស ពីសមាគមឧកញ៉ាកម្ពុជា ប្រគល់ជូនកាកបាទក្រហមកម្ពុជា សម្រាប់ជួយដល់គ្រួសារវីរយុទ្ធជននិងជនភៀសសឹក ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់លោកជំទាវបណ្ឌិត **ពេជ ចន្ទមុន្នី ហ៊ុនម៉ាណែត** អនុប្រធានអចិន្ត្រៃយ៍កាកបាទក្រហមកម្ពុជា នៅទីស្នាក់ការកណ្តាលកាកបាទក្រហមកម្ពុជា នារសៀលថ្ងៃទី១៥ ខែមករា ឆ្នាំ២០២៦។



-អមដំណើរសម្តេចកិត្តិព្រឹទ្ធបណ្ឌិត **ប៊ុន រ៉ានី ហ៊ុនសែន** ប្រធានកាកបាទក្រហមកម្ពុជា ចុះសួរសុខទុក្ខនិងនាំយកអំណោយមនុស្សធម៌ជូនវីរយុទ្ធជនដែលរងរបួស និងពលផ្សេងក្នុងសមរភូមិ ដែលកំពុងសម្រាកព្យាបាលនៅមន្ទីរពេទ្យបង្អែកខេត្តសៀមរាបនិងមន្ទីរពេទ្យយោធភូមិភាគទី៤ នាថ្ងៃទី១៦ ខែមករា ឆ្នាំ២០២៦។

-អមដំណើរសម្តេចកិត្តិព្រឹទ្ធបណ្ឌិត **ប៊ុន រ៉ានី ហ៊ុនសែន** ប្រធានកាកបាទក្រហមកម្ពុជា ជួបសំណេះសំណាលសួរសុខ-ទុក្ខជាលើកទី៣និងផ្តល់អំណោយមនុស្សធម៌ជូនប្រជាជន



ភៀសសឹកចំនួន២.២០៥គ្រួសារ (ស្មើនឹង៦.៧៤៦នាក់) ដែលស្នាក់នៅបណ្តោះអាសន្នតាមមណ្ឌលសុវត្ថិភាពចំនួន ១៣ និងតាមផ្ទះសាច់ញាតិ ស្ថិតក្នុងស្រុកក្រឡាញ់ ខេត្តសៀមរាប ព្រមទាំងបានអញ្ជើញចូលបូជាទៀន ធូប ផ្កាភ្ញី ថ្វាយព្រះរតនត្រ័យ ធ្វើបទនមស្ការ និងប្រគេនទេយ្យទាន ដល់ព្រះសង្ឃគង់នៅក្នុងវត្តបូទុម្ពរតនញ្ញាណ (ហៅវត្តស្រណាល) ខេត្តសៀមរាប នាព្រឹកថ្ងៃទី១៧ ខែមករា ឆ្នាំ២០២៦។



❋នាថ្ងៃពុធ ទី១៣ ខែមករា ឆ្នាំ២០២៦ លោកជំទាវ **មុំ សណ្តាប់** សមាជិកាគណៈកម្មការទី៦ព្រឹទ្ធសភា បានអញ្ជើញចូលរួមកិច្ចប្រជុំផ្ទៃក្នុងក្រុមការងារជួយគាំទ្រស្ត្រីរាជធានីភ្នំពេញ ក្រោមអធិបតីភាពលោកជំទាវ **ឡោក ខេង** ប្រធានគណៈកម្មការទី៨រដ្ឋសភា នៅសាលគណៈកម្មការទី៨រដ្ឋសភា។

❋សម្តេចរាជបុត្រីព្រះអនុជ **នរោត្តម អរុណរស្មី** សមាជិកាគណៈកម្មការទី១០ព្រឹទ្ធសភា បានយាង៖



-ព្រះរាជទានអង្ករចំនួន៤តោន ព្រមទាំងគ្រឿងឧបភោគបរិភោគ និងសម្ភារៈប្រើប្រាស់ប្រចាំថ្ងៃប្រគល់ជូនឯកឧត្តម **អ៊ឹម ស៊ីថុល** រដ្ឋលេខាធិការប្រចាំការ និងជាតំណាងដ៏ខ្ពង់ខ្ពស់ឯកឧត្តម **ឌិត ទីណា** រដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ សម្រាប់ផ្គត់ផ្គង់ប្រជាពលរដ្ឋភៀសសឹក ដែលកំពុងស្នាក់នៅក្នុងខេត្តបន្ទាយមានជ័យ នាព្រឹកថ្ងៃទី១៩ និងថ្ងៃទី២៦ ខែធ្នូ ឆ្នាំ២០២៥។

-ទទួលវីរកងទ័ពកម្ពុជាទាំង១៨រូប ក្រោយភាគីថៃដោះលែងប្រគល់ឱ្យកម្ពុជាវិញ នៅអាកាសយានដ្ឋានអន្តរជាតិភ្នំពេញ នាថ្ងៃទី៣០ ខែធ្នូ ឆ្នាំ២០២៥។

-អមព្រះករុណាជាអម្ចាស់ជីវិតលើត្បូង ព្រះបាទសម្ដេចព្រះបរមនាថ **នរោត្តម សីហមុនី** ព្រះមហាក្សត្រ នៃព្រះរាជាណាចក្រកម្ពុជា និងសម្ដេចព្រះមហាក្សត្រី **នរោត្តម មុនិនាថ សីហនុ** ព្រះវររាជមាតាជាតិខ្មែរ សព្វព្រះរាជហឫទ័យប្រោសព្រះរាជទានកងទ័ពទាំង១៨រូប ដែលបាននិវត្តន៍មកកាន់មាតុប្រទេសវិញ ប្រកបដោយសុខសុវត្ថិភាពខ្ពស់ ក្រោយពីស្ថិតក្នុងការឃុំគ្រងរបស់ភាគីថៃអស់រយៈពេល ១៥៥ថ្ងៃ ចូលក្រាបថ្វាយបង្គំគាល់ នៅព្រះរាជដំណាក់សិរីមង្គល ព្រះបរមរាជវាំង នាថ្ងៃទី១ ខែមករា ឆ្នាំ២០២៦។

## សមាជិក សមាជិកាព្រឹទ្ធសភាបំពេញបេសកកម្មក្រៅប្រទេស




❈ចាប់ពីថ្ងៃទី២៣ ដល់ថ្ងៃទិ២៩ ខែមករា ឆ្នាំ២០២៦ ឯកឧត្តម **ឌី ច័ន្ទផល** ប្រធានគណៈកម្មការទី១ព្រឹទ្ធសភា បានអញ្ជើញចូលរួមមហាសន្និបាតសភាតំបន់អាស៊ីលើកទី១៦ (16th APA Plenary Session) នៅទីក្រុងម៉ាណាម៉ា ព្រះរាជាណាចក្របារ៉ែន។

❈ចាប់ថ្ងៃទី៦ ដល់ថ្ងៃទី១៦ ខែមករា ឆ្នាំ២០២៦ សម្ដេចរាជបុត្រីព្រះអនុជ **នរោត្តម អរុណរស្មី** សមាជិកាគណៈកម្មការទី១០ព្រឹទ្ធសភា បានយាងជាព្រះរាជតំណាងដ៏ខ្ពង់ខ្ពស់បំផុតរបស់ព្រះករុណាជាអម្ចាស់ជីវិតលើត្បូង ព្រះមហាក្សត្រ នៃព្រះរាជាណាចក្រកម្ពុជា ក្នុងពិធីសម្ពោធឈ្មោះសួនច្បារ **នរោត្តម សីហនុ** នៅសាធារណរដ្ឋបារាំង។

## ការទទួលពាក្យបណ្ដឹង

❈ក្នុងខែមករា ឆ្នាំ២០២៦ គណៈកម្មការទី១ព្រឹទ្ធសភា បានទទួលពាក្យបណ្ដឹងចូលចំនួន៨បណ្ដឹង រំលឹកដំរុញការដោះស្រាយពាក្យបណ្ដឹងចំនួន៤បណ្ដឹង កំពុងពិនិត្យសិក្សាចំនួន១០បណ្ដឹង (សល់ពីឆ្នាំ២០២៥ ចំនួន២បណ្ដឹង) ធ្វើកំណត់បង្ហាញគោរពរាយការណ៍ជូនសម្ដេចតេជោប្រធានព្រឹទ្ធសភា អំពីលទ្ធផលនៃការដោះស្រាយពាក្យបណ្ដឹងរបស់គណៈកម្មការចំនួន៣បណ្ដឹង ទទួលលិខិតឆ្លើយតបពីការដោះស្រាយពីស្ថាប័នពាក់ព័ន្ធចំនួន៣បណ្ដឹង ទទួលឯកសារជូនជ្រាបពីក្រសួងស្ថាប័នពាក់ព័ន្ធចម្លងជូនមកគណៈកម្មការចំនួន២បណ្ដឹង៕

# ឯកឧត្តម ឡាយ សំកុល អំពាវនាវមន្ត្រីរាជការរួបរួមសាមគ្គីគ្នា ដើម្បីបុព្វហេតុជាតិមាតុភូមិ «សាមគ្គីរស់ បែកបាក់សាមគ្គីស្លាប់»



ឯកឧត្តម អោក បូរ៉ា ឯកឧត្តម ឡាយ សំកុល ឯកឧត្តម ឡោក ឆាយ ឯកឧត្តម ឌី បញ្ញា

ក្នុងឱកាសដឹកនាំកិច្ចប្រជុំបូកសរុបលទ្ធផលការងាររបស់អគ្គលេខាធិការដ្ឋានព្រឹទ្ធសភាប្រចាំខែធ្នូ ឆ្នាំ២០២៥ និងកំណត់ទិសដៅការងារខែមករា ឆ្នាំ២០២៦ នាព្រឹកថ្ងៃសុក្រ ទី៩ ខែមករា ឆ្នាំ២០២៦ ឯកឧត្តម **ឡាយ សំកុល** អគ្គលេខាធិការព្រឹទ្ធសភា បានជម្រាបជូនអង្គប្រជុំអំពីសភាពការណ៍វិវត្តថ្មីៗ នៅលើពិភពលោកនិងអំពីមហិច្ឆតាឈ្លានពានរបស់ថៃមកលើកម្ពុជា ព្រមទាំងបានអំពាវនាវដល់មន្ត្រីរាជការទាំងអស់ ត្រូវរួបរួមសាមគ្គីគ្នាជាធ្លុងមួយ ដើម្បីគាំទ្រដល់សម្តេចតេជោ **ហ៊ុន សែន** និងរាជរដ្ឋាភិបាលដែលមានសម្តេចធិបតី **ហ៊ុន ម៉ាណែត** ជាប្រមុខ ព្រមទាំងវីរកងទ័ពយើង ក្នុងការការពារបូរណភាពទឹកដី អធិបតេយ្យជាតិ ពីការឈ្លានពានរបស់ថៃ ដូចពំនោលពីបុរាណថា «សាមគ្គីរស់ បែកបាក់សាមគ្គីស្លាប់»។

ក្នុងឱកាសនោះ **ឯកឧត្តមអគ្គលេខាធិការ** បានថ្លែងអំណរគុណចំពោះថ្នាក់ដឹកនាំនិងមន្ត្រីរាជការទាំងអស់ ដែលបានខិតខំបំពេញការងារដោយទទួលបានលទ្ធផលយ៉ាងគាប់ប្រសើរ ជាឧត្តមប្រយោជន៍សម្រាប់ស្ថាប័ននិងប្រទេសជាតិ។

ចំពោះទិសដៅការងារនាពេលខាងមុខ **ឯកឧត្តមអគ្គលេខាធិការ** បានណែនាំដល់អគ្គនាយកដ្ឋានសេវាច្បាប់ និងសមូហភាពដែនដី និងអង្គភាពពាក់ព័ន្ធ ត្រៀមរៀបចំកិច្ចប្រជុំរបស់ព្រឹទ្ធសភា ដើម្បីពិនិត្យហើយឱ្យយោបល់លើសេចក្តីព្រាងច្បាប់ស្តីពី ការអនុម័តយល់ព្រមលើអនុសញ្ញាអង្គការសហប្រជាជាតិស្តីពី នីតិសមុទ្រ និងការបោះឆ្នោតជ្រើសរើសសមាជិកគណៈកម្មការទី៥ព្រឹទ្ធសភា ក្នុងសម័យប្រជុំព្រឹទ្ធសភា នាពេលខាងមុខ។ ក្នុងអំឡុងពេលនៃចន្លោះសម័យប្រជុំព្រឹទ្ធសភា **ឯកឧត្តមអគ្គលេខាធិការ**បានណែនាំដល់អង្គភាពពាក់ព័ន្ធ ត្រៀមផ្តល់សេវាជូនគណៈកម្មការនានា



ឯកឧត្តម ឡាយ សំកុល អញ្ជើញមានប្រសាសន៍ក្នុងកិច្ចប្រជុំបូកសរុប

របស់ព្រឹទ្ធសភា ក្នុងការចុះឈ្វេងយល់និងប្រមូលព័ត៌មាន អំពីវិស័យជាសមត្ថកិច្ចរបស់ខ្លួន នៅតាមក្រសួង ស្ថាប័ន និងមូលដ្ឋាន ឱ្យបានរលូននិងគ្រប់ជ្រុងជ្រោយ។

ទន្ទឹមនឹងនេះ **ឯកឧត្តមអគ្គលេខាធិការ** បានណែនាំដល់អគ្គនាយកដ្ឋានពិធីការនិងទំនាក់ទំនងអន្តរជាតិ រៀបចំឯកសារ បែបបទ និងកិច្ចការផ្សេងៗ ក្នុងការរៀបចំទទួលដំណើរទស្សនកិច្ចរបស់គណៈប្រតិភូជាន់ខ្ពស់នៃប្រទេសប៉ាគីស្ថាននិងប្រទេសរុស្ស៊ី មកកាន់កម្ពុជា ព្រមទាំងការអញ្ជើញទៅចូលរួមរបស់ថ្នាក់ដឹកនាំព្រឹទ្ធសភា ក្នុងកិច្ចប្រជុំសភាប្រើភាសាបារាំងAPF នៅប្រទេសម៉ុងតេណេក្រូ។

ចំពោះការអភិវឌ្ឍស្ថាប័ន **ឯកឧត្តមអគ្គលេខាធិការ** បានស្នើឱ្យគ្រប់អគ្គនាយកដ្ឋាន រៀបចំរបាយការណ៍បូកសរុបលទ្ធផលការងារប្រចាំឆ្នាំ២០២៥ ដើម្បីរាយការណ៍ក្នុងកិច្ចប្រជុំបូកសរុបប្រចាំឆ្នាំ ដែលនឹងរៀបចំនៅខែកុម្ភៈ ឆ្នាំ២០២៦។ ជាមួយគ្នានេះ ការត្រៀមរៀបចំពិធីសូត្រមន្ត ក្រុងពាលី សុំសិរីសួស្តី ជូនថ្នាក់ដឹកនាំព្រឹទ្ធសភាចូលបំពេញការងារនៅអគារថ្មី និងពិធីសម្ពោធអគារថ្មី នាពេលខាងមុខ ព្រមទាំងរៀបចំកិច្ចប្រជុំចង្អៀតរបស់ថ្នាក់ដឹកនាំអគ្គលេខាធិការដ្ឋានព្រឹទ្ធសភា និងអគ្គនាយកដ្ឋាន ក្នុងពេលឆាប់ៗ។

ជាចុងបញ្ចប់ **ឯកឧត្តមអគ្គលេខាធិការ** បានណែនាំដល់ថ្នាក់ដឹកនាំ និងមន្ត្រីរាជការទាំងអស់ បន្តខិតខំយកចិត្តទុកដាក់ខ្ពស់ក្នុងការផ្តល់សេវាឱ្យបានទាន់ពេលវេលានិងគ្រប់ជ្រុងជ្រោយជូនស្ថាប័ន៕

អត្ថបទ និងរូបភាព៖ នាយកដ្ឋានព័ត៌មាន







*ទិដ្ឋភាពក្នុងពិធីប្រជុំបូកសរុបលទ្ធផលការងារប្រចាំខែធ្នូ និងកំណត់ទិសដៅការងារខែមករា ឆ្នាំ២០២៦*

# សកម្មភាពថ្នាក់ដឹកនាំអគ្គលេខាធិការដ្ឋានព្រឹទ្ធសភាចូលរួមពិធីផ្សេងៗ




❋នាព្រឹកថ្ងៃសុក្រ ទី២៦ ខែធ្នូ ឆ្នាំ២០២៥ ឯកឧត្តម **ឡាយ សំកុល** អគ្គលេខាធិការព្រឹទ្ធសភា បានអញ្ជើញនាំយកគ្រឿងឧបភោគ បរិភោគ សម្លៀកបំពាក់កូនក្មេង សម្ភារៈផ្សេងៗ និងថវិកាចំនួន១០លានរៀល សម្រាប់យកប្រគល់ជូនវីរកងទ័ពជួរមុខ និងប្រជាជនភៀសសឹក នៅវិមាន៧មករា។

❋នាព្រឹកថ្ងៃទី៣០ ខែធ្នូ ឆ្នាំ២០២៥ និងថ្ងៃទី៥ ទី២១ ខែមករា ឆ្នាំ២០២៦ ឯកឧត្តម **ឡាយ សំកុល** អគ្គលេខាធិការ និងឯកឧត្តម **ខេង សិទ្ធិគុណ** អគ្គលេខាធិការរងព្រឹទ្ធសភា បានអមដំណើរឯកឧត្តម **ប្រាក់ សុខុន** ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ និងជាប្រធានគណៈកម្មការសាងសង់អគារថ្មី នៃព្រឹទ្ធសភា អញ្ជើញចុះពិនិត្យមើលវឌ្ឍនភាពនៃដំណើរការសាងសង់វិមានសាមគ្គីភាព។





❋នារសៀលថ្ងៃពុធ ទី៣១ ខែធ្នូ ឆ្នាំ២០២៥ ឯកឧត្តម **ឡាយ សំកុល** អគ្គលេខាធិការព្រឹទ្ធសភា និងជាសមាជិកក្រុមប្រឹក្សាជាតិប្រឆាំងអំពើពុករលួយ បានអញ្ជើញចូលរួមក្នុងកិច្ចប្រជុំក្រុមប្រឹក្សាជាតិប្រឆាំងអំពើពុករលួយ (ក.ជ.ប.ព.) លើកទី៥ អាណត្តិទី៤ ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់របស់សម្តេចកិត្តិសង្គហបណ្ឌិត **ម៉ែន សំអន** ប្រធាន ក.ជ.ប.ព. នៅអង្គភាពប្រឆាំងអំពើពុករលួយ។

# សកម្មភាពថ្នាក់ដឹកនាំអគ្គលេខាធិការដ្ឋានព្រឹទ្ធសភាចូលរួមពិធីផ្សេងៗ

❈នារសៀលថ្ងៃចន្ទ ទី៥ ខែមករា ឆ្នាំ២០២៦ ឯកឧត្តម **ឡាយ សំកុល** អគ្គលេខាធិការព្រឹទ្ធសភា បានជួបប្រជុំជាមួយអ្នកឧកញ៉ាកត្តីព្រះស្តេច **ហេង គឹមគុណា** ត្រៀមរៀបចំពិធីក្រុងពាលី និងចម្រើនព្រះបរិត្តឡើងវិមានសាមគ្គីភាព។





❈នារសៀលថ្ងៃចន្ទ ទី៥ ខែមករា ឆ្នាំ២០២៦ ឯកឧត្តម **ឡាយ សំកុល** អគ្គលេខាធិការ និងឯកឧត្តម **ខេង សិទ្ធិគុណា** អគ្គលេខាធិការរងព្រឹទ្ធសភា បានអញ្ជើញសួរសុខទុក្ខឯកឧត្តម **ឈិត សុខុន** ប្រធានគណៈកម្មការទី៧ព្រឹទ្ធសភា ដែលកំពុងសម្រាកថែទាំសុខភាព នៅមន្ទីរពេទ្យជប៉ុនសាន់រ៉ាយស៍ រាជធានីភ្នំពេញ។

❈នារសៀលថ្ងៃព្រហស្បតិ៍ ទី៨ ខែមករា ឆ្នាំ២០២៦ ឯកឧត្តម **ឡាយ សំកុល** អគ្គលេខាធិការព្រឹទ្ធសភា បានទទួលជួបពិភាក្សាការងារជាមួយឯកឧត្តម Marcos dos Reis da Costa ឯកអគ្គរដ្ឋទូត នៃសាធារណរដ្ឋប្រជាធិបតេយ្យទីម័រឡេស្តេ និងសហការី នៅបន្ទប់ប្រជុំឯកឧត្តមអគ្គលេខាធិការព្រឹទ្ធសភា។





❈នាព្រឹកថ្ងៃសុក្រ ទី៩ ខែមករា ឆ្នាំ២០២៦ ឯកឧត្តម **ឡាយ សំកុល** អគ្គលេខាធិការព្រឹទ្ធសភា និងថ្នាក់ដឹកនាំនៃអគ្គលេខាធិការដ្ឋានព្រឹទ្ធសភា បានអញ្ជើញរៀបចំពិធីក្រុងពាលីបួងសួង សុំសេចក្តីសុខ សេចក្តីចម្រើន សុំការអនុញ្ញាតដំឡើងទីសក្ការៈបូជាពានទេវតាថ្មី ថ្វាយដល់ទសបារមី វត្ថុស័ក្តិសិទ្ធិ ម្ចាស់ទឹក ម្ចាស់ដី ដែលថែរក្សាទឹកដី ជ័យភូមិវិមានសាមគ្គីភាព នៃព្រឹទ្ធសភា។

# សកម្មភាពថ្នាក់ដឹកនាំអគ្គលេខាធិការដ្ឋានព្រឹទ្ធសភាចូលរួមពិធីផ្សេងៗ

❈នារសៀលថ្ងៃទី២៣ ខែមករា ឆ្នាំ២០២៦ ឯកឧត្តម **ឡាយ សំកុល** អគ្គលេខាធិការព្រឹទ្ធសភា បានអញ្ជើញដឹកនាំកិច្ចប្រជុំជាមួយតំណាងក្រសួងនិងស្ថាប័នពាក់ព័ន្ធ ដើម្បីពិភាក្សាលើការរៀបចំទទួលដំណើរទស្សនកិច្ចផ្លូវការរបស់ឯកឧត្តមប្រធានព្រឹទ្ធសភាប៉ាគីស្ថាន នៅព្រះរាជាណាចក្រកម្ពុជា នៅសាលប្រជុំពិសេស៣ វិមានព្រឹទ្ធសភា។





❈នាព្រឹកថ្ងៃសុក្រ ទី១៦ ខែមករា ឆ្នាំ២០២៦ ឯកឧត្តម **ខេង សិទ្ធិគុណ** និងឯកឧត្តម **អោក ប៊ូរ៉ា** អគ្គលេខាធិការរងព្រឹទ្ធសភា បានអញ្ជើញទទួលម៉ាស៊ីនស្កេនពីក្រុមហ៊ុន PRIMEX INTERNATIONAL CO.,LTD នៅវិមានព្រឹទ្ធសភា។

❈នារសៀលថ្ងៃទី២០ ខែមករា ឆ្នាំ២០២៦ ឯកឧត្តម **ខេង សិទ្ធិគុណ** អគ្គលេខាធិការរងព្រឹទ្ធសភា តំណាងរបស់ឯកឧត្តម **ឡាយ សំកុល** អគ្គលេខាធិការព្រឹទ្ធសភា បានអញ្ជើញនាំយកអំណោយរបស់អគ្គលេខាធិការដ្ឋានព្រឹទ្ធសភានិងថវិកាមួយចំនួនរបស់ឯកឧត្តមអគ្គលេខាធិការ និងក្រុមការងារ ប្រគល់ជូនរដ្ឋបាលសង្កាត់ព្រែកតាសេក ដើម្បីឧបត្ថម្ភដល់វីរកងទ័ពជួរមុខ និងប្រជាពលរដ្ឋភៀសសឹក នៅសាលាសង្កាត់ព្រែកតាសេក ខណ្ឌជ្រោយចង្វារ រាជធានីភ្នំពេញ។





❈នារសៀលថ្ងៃអង្គារ ទី៦ ខែមករា ឆ្នាំ២០២៦ ឯកឧត្តម **ឌី បញ្ញា** អគ្គលេខាធិការរងព្រឹទ្ធសភា បានអញ្ជើញនាំយកអំណោយផ្ទាល់ខ្លួនរបស់ឯកឧត្តមនិងក្រុមគ្រួសារ ព្រមទាំងសប្បុរសជននានា ប្រគល់ជូនអគ្គលេខាធិការដ្ឋានព្រឹទ្ធសភា សម្រាប់ចែកជូនវីរកងទ័ពនិងប្រជាពលរដ្ឋភៀសសឹក នៅតាមព្រំដែនកម្ពុជា-ថៃ នៅវិមានព្រឹទ្ធសភា។

# សកម្មភាពថ្នាក់ដឹកនាំអគ្គលេខាធិការដ្ឋានព្រឹទ្ធសភាចូលរួមពិធីផ្សេងៗ



❋នាព្រឹកថ្ងៃសុក្រ ទី២៦ ខែធ្នូ ឆ្នាំ២០២៥ ឯកឧត្តមបណ្ឌិត **ឈឹម ឃីស៊ាង** នាយកខុទ្ទកាល័យសម្តេចតេជោប្រធានព្រឹទ្ធសភា បានអញ្ជើញផ្តល់បាឋកថាស្តីពី «ទស្សនាទាននៃវិធីសាស្ត្រស្រាវជ្រាវនិងការងារនិងការប្រើប្រាស់បច្ចេកវិទ្យាព័ត៌មានវិទ្យា-បញ្ញាសិប្បនិម្មិត» ក្នុងការរៀបចំឯកសារសុន្ទរកថា បទអន្តរាគមន៍ សេចក្តីថ្លែងការណ៍ សេចក្តីប្រកាសព័ត៌មាន និងជំនួយស្មារតី ជូនសមាជិកខុទ្ទកាល័យសម្តេចប្រធានព្រឹទ្ធសភា ខុទ្ទកាល័យអនុប្រធានទី១ព្រឹទ្ធសភា និងមន្ត្រីរាជការ នៃអគ្គលេខាធិការដ្ឋានព្រឹទ្ធសភា នៅវិមានព្រឹទ្ធសភា។



❋នារសៀលថ្ងៃសុក្រ ទី២៦ ខែធ្នូ ឆ្នាំ២០២៥ ឯកឧត្តមបណ្ឌិត **គួត ហ៊ីដេវ៉ូ** នាយករងខុទ្ទកាល័យសម្តេចតេជោប្រធានព្រឹទ្ធសភា និងសហការី បានអញ្ជើញគោរពវិញ្ញាណក្ខន្ធសពលោកជំទាវនាយឧត្តមសេនីយ៍ **ម៉ី មនដារី** អគ្គមេបញ្ជាការរងនៃកងយោធពលខេមរភូមិន្ទ នៅសង្កាត់បឹងកេងកងទី២ ខណ្ឌទួលគោក រាជធានីភ្នំពេញ។



❋នាព្រឹកថ្ងៃពុធ ទី៧ ខែមករា ឆ្នាំ២០២៦ ឯកឧត្តមបណ្ឌិត **គួត ហ៊ីដេវ៉ូ** នាយករងខុទ្ទកាល័យសម្តេចតេជោប្រធានព្រឹទ្ធសភានិងសហការី បានអញ្ជើញគោរពវិញ្ញាណក្ខន្ធសព ឧបាសិកា **ស៊ន់ គា** ម្តាយបង្កើតរបស់អ្នកឧកញ៉ា **ម៉ក់ គីមហុង** នៅសង្កាត់សួង ក្រុងសួង ខេត្តត្បូងឃ្មុំ។



❋នៅរសៀលថ្ងៃទី២០ ខែមករា ឆ្នាំ២០២៦ គណៈកម្មការមូលដ្ឋានអគ្គលេខាធិការដ្ឋានព្រឹទ្ធសភា នៃសមាគមសង្គហៈមន្ត្រីរាជការនៃក្រុមនីតិប្បញ្ញត្តិ បានអញ្ជើញគោរពវិញ្ញាណក្ខន្ធសពលោក **ប្រាក់ ប៊ុនម៉េង** និវត្តជន នៃអគ្គលេខាធិការដ្ឋានព្រឹទ្ធសភា នៅសង្កាត់ដង្កោ ខណ្ឌដង្កោ រាជធានីភ្នំពេញ៕

សូមស្កេន QR Code

ដើម្បីចូលទៅកាន់បណ្ដាញសង្គមព្រឹទ្ធសភា

**Senate of Cambodia**

វិមានរដ្ឋចំការមន មហាវិថីព្រះនរោត្តម រាជធានីភ្នំពេញ

ទូរសព្ទ៖ (855) 23 211 411, 211 422, 211 443

ទូរសារ៖ (855) 23 211 446

E-mail: secretariat@senate.gov.kh